ឧបសៅសង្ហា

# អរិយធម៌ នៅ ឥណ្ឌូចិន




## មាតិការឿង

អារម្ភកថា ....................................................................... 2
ធម្មជាតិ នៃ អរិយធម៌ ........................................................... 3
ការផ្សំកាត់ រវាង ចិន និង ឥណ្ឌា ........................................... 11
សតវត្សរ៍ទី១៩ មកដល់ សព្វថ្ងៃ ............................................. 12
ការប៉ះទង្គិច រវាង អរិយធម៌ ................................................. 16
អរិយធម៌យួន ..................................................................... 17
អរិយធម៌ខ្មែរ .................................................................... 21
អរិយធម៌ ខ្មែរ និង យួន : ការប្រទល់មុខគ្នា ................................ 62
សៀវភៅ និង ឯកសារជំនួយ និង ដកស្រង់ ................................. 109

# អារម្ភកថា

វចនានុក្រមខ្មែរ ទុកជា ប្រភព នៃ ពាក្យ អក្ខរាវិរុទ្ធ យកមកប្រើ នៅទីនេះ គឺ : វចនានុក្រមនៃ ពុទ្ធសាសនាបណ្ឌិត្យ ហៅថា វចនានុក្រមសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជួន ណាត ជោតញ្ញាណោ, វចនានុក្រម ខ្មែរ-បារាំង របស់លោក Alain Daniel, ពាក្យខ្មែរ រៀបរៀងដោយ លោក E. Mentrier, វចនានុក្រម បារាំង-ខ្មែរ Larousse។ បើមានពាក្យណាមួយ ដែលខ្ញុំ បង្កើត ឬ តាមការផ្សំពាក្យ ខ្មែរ ឬ បាលី ឬ សំស្ក្រឹត តាមក្បួន របស់លោក អៀវ កើស គឺខ្ញុំដាក់សញ្ញា * ពីខាងមុខពាក្យ។ ឈ្មោះ របស់ បុគ្គល, ប្រទេស ឬ ដំបន់ ភាគច្រើនខ្ញុំ សេសេរ ជា អក្សរបារាំងសែស ដោយខ្ញុំ គ្មានការចេះដឹងគ្រប់គ្រាន់ នឹងអាច ផ្សំ ជា អក្សរខ្មែរ ឬ រកមិនទាន់ឃើញ នូវពាក្យនោះ ជាអក្សរខ្មែរ ដែលមាន អ្នកប្រាជ្ញ ឬ អ្នកនិពន្ធខ្មែរ ធ្លាប់សេសេររួចហើយ។ ដូចនេះបើប្រថុតសរសេរវាអាចនាំ៱ អ្នកអាន ពិបាកនឹងអាន។

ឥណ្ឌូចិន ជាឈ្មោះ ដែលជនជាតិ ដាណឺម៉ាក ម្នាក់ ឈ្មោះ Malte-Brun ជា ភូមិសាស្ត្រិន ដាក់អោយ។ ទឹកដី ឥណ្ឌូចិន ជា ប្រជុំទឹកដី នៅ អាស៊ី ភាគអាគ្នេយ៍ ផ្តុំ ជាឧបទ្វីប មានភ្នំខ្ពស់ៗ និង ជ្រលងភ្នំ លាតត្រដាង ពីជើង ស្តួចវែង ទៅត្បូង ដែលជា ឧបទ្វីប មាឡេ។ ខាង កើត និង លិច ទល់នឹងសមុទ្រ។ ទោះបី ជា ទឹកដី មាន កម្រាស់ ជាទ្វីប ក៏ដោយ តែ ជា ផ្លូវឆ្លង នៃ វិក្ស័យ គ្រប់បែបយ៉ាង ជាដរាបតាំងពី បុព្វប្រវត្តិសាស្ត្រ។ ដូចនេះ ពួកអ្នកប្រវត្តិសាស្ត្រ រក

ឃើញស្នាម ពូជសាសន៍មនុស្ស ជាច្រើន : អូស្ត្រាលី, មាឡានេស៊ី, ម៉ុងហ្គោល (australiennes, mélanésiennes, mongoloïdes) (ពូជសាសន៍នេះ មានកំណើតនៅស្រុកចិន)។ ពូជសាសន៍ ទាំងនោះ រួមជា មូលដ្ឋានគ្រឹះ (fonds) នៃ ប្រជាជន សព្វថ្ងៃ ដូចយ៉ាង ប្រភេទ មាឡានេស៊ី ជាជនជាតិភ្នំ មានរបៀបរស់នៅជាជនជាតិដើមនៅឡើយ។

តាមដំណើរ នៃ ពេលវេលា ប្រវត្តិសាស្ត្រ មាន ចរភាព (mouvement) នៃមនុស្ស ជំបួន ធ្វើដំណើរមកដល់ ឥណ្ឌូចិន : ទី១ ជាកម្លាំងទ័ពមួយ មកពីប្រទេសចិន មួយទៀត តាមផ្លូវសមុទ្រ ក្រោមសញ្ញា សន្តិភាព មកពី ឥណ្ឌា។ បន្ទាប់មក មាន ចរភាព សមុទ្រ ពីរទៀត គឺ អ៊ីស្លាម មកពី ឧបទ្វិប មាឡេស៊ី និង មកពី អ៊ឺរ៉ុប (បារាំង-អង់គ្លេស) នៅ សតវត្សទី១៩ រុករាន ទឹកដី ឥណ្ឌូចិន។

## ធម្មជាតិ នៃ អរិយធម៌

ប្រវត្តិសាស្ត្រ នៃ មនុស្សលោក គឺជា ប្រវត្តិសាស្ត្រ នៃ អរិយធម៌។ ដូចនេះ វា ពុំអាចយល់បាន អំពី ការវិវត្តន៍ នៃ អរិយធម៌ នៃ មនុស្សជាតិ តាំងពី អរិយធម៌បុរាណ ដូចជា អរិយធម៌ នៃ ជនជាតិ សុហ្មៈ (Suhma), ជនជាតិ អេស៊ីប រហូតមកដល់ អរិយធម៌ នៃ សាសនាគ្រិស្ត និង សាសនាអ៊ីស្លាម ឆ្លងកាត់ តាម អរិយធម៌ បរេណី និង មេសូ-អាមេរិកាំង (méso-américaine) និង បន្ត រហូតមកដល់ អរិយ

ធម៌ចិន និង ឥណ្ឌូ តាមទម្រង់ប្លែកៗគ្នា ដោយពុំបាន អាន និង សិក្សា ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ នោះឡើយ។ អរិយធម៌ ទាំងឡាយនោះហើយ ដែលផ្តល់អោយមនុស្ស លោក នូវ លក្ខណវិនិច្ឆ័យសំខាន់ សំរាប់សំគាល់ខ្លួន តាម ដំណើរ នៃ ប្រវត្តិសាស្ត្រ នៃ មនុស្សជាតិ។ ប្រវត្តិវិទូ ជាច្រើន បានសិក្សាជាជម្រៅ អំពី អរិយធម៌ និមួយៗ ហើយយក មកប្រៀបធៀបគ្នា ទុកជា ចំណេះចេះដឹង សំរាប់មនុស្ស ជាតិ។ ក៏ប៉ុន្តែ អ្នកប្រាជ្ញទាំងនោះ មាន ការព្រមព្រៀង រវាងគ្នា អំពី គោលការណ៍សំខាន់មួយចំនួន ស្តីពី ធម្ម ជាតិ, អត្តសញ្ញាណ និង ថាមវន្ត នៃ អរិយធម៌។ ជាបឋម គឺ ការបែងចែក ពាក្យ អរិយធម៌ (civilisation) ក្នុងន័យ ឯកវចនៈ និង អរិយធម៌ទាំងឡាយ (civilisations)[1] ក្នុង ន័យ ពហុវចនៈ។ គំនិត នៃ អរិយធម៌ ត្រូវបាន ចិត្ត បណ្ឌិត បារាំងសែស (penseurs français) មួយចំនួន យក មកប្រើក្នុង សតវត្សទី១៨ ក្នុងទស្សនៈ ផ្ទុយនឹង ពាក្យ អមនុស្សធម៌។ តាម ទស្សនៈ របស់ចិត្តបណ្ឌិត ទាំងឡាយ នោះ សង្គមអារ្យធម៌ ខុសពី សង្គមអនារ្យធម៌ ស្ថិតនៅលើ ស្ថាប័ន មានការជឿនលឿន ក្នុងបូរី និង កំរិត នៃ ការ អប់រំ របស់ប្រជាជន។ មនុស្ស មានអារ្យធម៌ ជាមនុស្សល្អ, មនុស្ស គ្មានអារ្យធម៌ ជាមនុស្សមិនល្អ។ ទស្សនៈ នេះ ផ្តល់

---

[1] ដើម្បី សំរួលក្នុងការសរសេរ របស់យើង នៅទីនេះ យើង សន្មតប្រើពាក្យ អរិយធម៌ (civilisation) ក្នុងន័យ ឯកវចនៈ និង អរិយធម៌ទាំងឡាយ (civilisations) ក្នុងន័យ ពហុវចនៈ។

នូវ បទដ្ឋាន ហើយនៅអំឡុង សតវត្សទី១៩ ពួកជនជាតិ អ៊ឺរ៉ុប ធ្វើសមារម្ភ ដោយប្រើថាមពល បញ្ញា, ទូត និង នយោបាយ ជាច្រើន ដើម្បី យក បទដ្ឋាននោះ សំរាប់វាយ តម្លៃថា សង្គមណា ពុំមែនជាសង្គមមស្ទីម ហើយ មិនសូវ មាន អរិយធម៌ តើអាចទុកបានជា សមាជិក ក្នុងប្រព័ន្ធ អន្តរជាតិ គ្រប់គ្រងដោយទ្វិបអ៊ឺរ៉ុប បានដែរឬទេ ? គួរ កត់សំគាល់ថា បទដ្ឋាននោះដែរ ដែលមស្ទីមប្រទេស យក ទៅផ្សាយ នៅប្រទេសអាណានិគម ក្នុងបេសកកម្ម នៃ អរិយ្យធម៌ របស់ខ្លួន គឺថា ទុក អរិយធម៌មស្ទីម ជា អរិយ ធម៌ខ្ពង់ខ្ពស់ ដោយប្រៀបធៀបនឹង អរិយធម៌ ដទៃទៀត នៅក្នុងលោកិយនេះ។ ក្រោយមក ពួកចិត្តបណ្ឌិតមស្ទីម ចាប់ផ្តើម និយាយបន្តិចម្តងៗ អំពី អរិយធម៌ទាំងឡាយ ក្នុងន័យ ពហុវចនៈ គឺថា ចាប់ផ្តើមទទួលស្គាល់ នូវ អត្ត តម្លៃ នៃ អរិយធម៌ និមួយៗ។ នៅក្នុង ទស្សនៈថ្មីនេះ គឺ ពួកគេ សន្មត បោះបង់ចោល នូវ គំនិត ទុក អរិយធម៌ ជា ឧត្តមគតិ តែមួយគត់ តែជា ឧត្តមគតិទូទៅ ហើយ ក៏ ឈប់យល់ឃើញថា អរិយធម៌ មាន បទដ្ឋាន តែមួយគត់ ដែរ សំរាប់តែ ប្រជាពលរដ្ឋ មួយចំនួនតូច ឬ សំរាប់តែ ក្រុមមួយ ដែលទុកជា ‹វេជី នៃ មនុស្សជាតិ[2]› តាម រូប មន្ត របស់ លោក Braudel ជា ប្រវត្តិវិទូ បារាំងសែស។ ម្លោះ

[2] វេជី នៃ មនុស្សជាតិ ; élite de l'humanité។

ហើយ គំនិត ថាមាន អរិយធម៌សាកលតែមួយ គេមិនអាច ការពារវា បានទៀតឡើយ។

តែ ពួកចិត្តបណ្ឌិត អាលឺម៉ង់ នៅសតវត្សទី១៩ យល់ឃើញថា អរិយធម៌ ជា អង្គភាពមួយ របស់វប្បធម៌។ ក្នុងទស្សនៈពួកគេ ចែកដាច់ អរិយធម៌ ពី វប្បធម៌ គឺថា អរិយធម៌ គឺរាប់បញ្ចូលតែ យន្តសាស្ត្រ, បច្ចេកវិជ្ជា និង កត្តា នៃសម្ភារៈដទៃទៀត, ចំណែក វប្បធម៌ គឺ ពាក់ព័ន្ធនឹងតម្លៃ, ឧត្តមគតិ, គុណភាព នៃបញ្ញា និង សីលធម៌ របស់ សង្គមមួយ។ ទស្សនៈនេះ ស្ថិត នៅក្នុង គំនិត អាលឺម៉ង់ រហូតមកដល់សព្វថ្ងៃនេះ តែ ជា ទស្សនៈមួយ គ្មានការយល់ព្រម ជាទូទៅនោះឡើយ។ រហូតដល់មាន ពួកនរវិទូខ្លះ យកវា មកបកស្រាយបញ្ជាក់ថា សង្គមនៅសម័យដើមមួយ មានស្ថិរភាព តែ គ្មានទីក្រុង គឺជា សង្គម បង្ហាញចរិកលក្ខណៈរបស់ខ្លួន តាម វប្បធម៌, ចំណែក សង្គម ដែលរួមបញ្ចូលរបស់ជាច្រើន[3], មានការជឿនលឿន, មានទីក្រុង ហើយជា សង្គម ថាមវន្ត គឺជា សង្គម ផ្សំផ្គុំ នូវ អរិយធម៌ ផ្សេងៗជាច្រើន។ ដូច្នេះ អរិយធម៌ វាជា សារព័ន នៃ ភីយ្យោភាពរបស់សង្គម។ តាមគំនិត របស់លោក Fernand Braudel បំណង ចង់ចែក វប្បធម៌ ពី អរិយធម៌ គ្រាន់តែជា គំនិតចង់បំភាន់ (idée illusoire) តែប៉ុណ្ណោះ។

[3] សង្គម ដែលរួមបញ្ចូលរបស់ជាច្រើន ; société plus complexe។

អរិយធម៌ និង វប្បធម៌ យកតាម របៀបរស់នៅ ជាទូទៅ គឺ អរិយធម៌ ជា វប្បធម៌ រីកសាយន័យ តែប៉ុណ្ណោះ។ ន័យ ទាំងពីរនោះ បញ្ចូល នូវ ‹តម្លៃ, បទដ្ឋាន, ស្ថាប័ន និង វិធី នៃ គំនិត ដែល មនុស្សលោក ពី ទំនាន់ មួយទៅ ទំនាន់ មួយទៀត រស់នៅ ដោយជាប់ចិត្តជាខ្លាំង នៅក្នុងសង្គម ដែលរៀងៗខ្លួន កំពុងរស់នៅ។ តាម លោក Braudel អរិយធម៌ ជា « ផែនដី (un espace) នៃ ‹ដំបន់ វប្បធម៌មួយ› និង ការប្រមូលរួម នៃ លក្ខណ: និង បាតុភូត នៃវប្បធម៌ មួយចំនួន »។ តាម លោក Wallerstein វិញ អរិយធម៌ គឺ ការប្រមូលរួម ជាកំណត់ច្បាស់លាស់ នៃ ចក្ខុវិស័យ នៃ លោក[4] ដូចយ៉ាង ទំនៀមទំនាប់, រចនាសម្ព័ន្ធ និង វប្បធម៌ ក្នុងន័យ សម្ភារ: ក៏ដូច ក្នុងន័យ ខ្ពង់ខ្ពស់ ដែល ផ្សំផ្គុំ ជា ប្រភេទមួយ នៃប្រវត្តិសាស្ត្រ ហើយ រួមរស់ (ទោះបី នៅក្នុង ពេលវេលាខុសគ្នាក្តី) ជាមួយ បាតុភូត ផ្សេងៗទៀត។ តាម លោក Dawson អរិយធម៌ ជាផល នៃអភិក្រមដើម (processus original) នៃ ការបង្កើតដំបូង នៃវប្បធម៌ ដែលជាស្នាដៃ ផ្ទាល់ខ្លួន នៃ ប្រជាពលរដ្ឋមួយ។ ចំណែក លោក Durkheim និង Mauss វិញ លោក មាន ទស្សន: ថា អរិយធម៌ ជា ប្រការមួយ នៃ មជ្ឈដ្ឋាន សីលធម៌ រួមបញ្ចូល នៃ ប្រជាជាតិខ្លះ, វប្បធម៌ជាតិនិមួយៗ គ្រាន់តែ

[4] ប្រមូលរួម ជាកំណត់ច្បាស់លាស់ នៃ ចក្ខុវិស័យ នៃ លោក ; concaténation bien déterminée de vision du monde។

ជា ទម្រង់ពិសេស បូករួមចូលគ្នាតែមួយ។ តាម លោក Spengler អរិយធម៌ គឺជា វាសនា មិនអាចជៀសបាន នៃ វប្បធម៌, ជា កំរិត នៃ ការជឿនលឿនជាងគេ ខាងក្រៅ និង សិប្បនិម្មិតជាងគេ ដែល មនុស្សជាតិ អាចធ្វើបាន, ជា សេចក្តីសន្និដ្ឋាន, ជាផលា នៃ ការបង្កើតផល។ វប្បធម៌ ជា វត្ថុធាតុរូប តាមគ្រប់និយមន័យ អ្វីអាចមានបាន នៃ អរិយធម៌។

អរិយធម៌ទាំឡាយ គ្មានព្រំដែន ច្បាស់លាស់នោះឡើយ, គ្មាន ដើម គ្មាន ចុង ពិតប្រាកដ។ គេអាចអោយនិយមន័យជាថ្មី អំពី អត្តសញ្ញាណ នៃ អរិយធម៌ទាំងឡាយ លុះត្រាតែ ការផ្សំ និង ទម្រង់ របស់វា ដូរ តាម ខ្សែ នៃពេលវេលា។ វប្បធម៌ទាំងឡាយ ធ្វើអន្តរប្រតិកម្ម រវាងគ្នា និង គងលើគ្នា ហើយ ភាពខុសគ្នា និង ភាពដូចគ្នា រវាងវប្បធម៌ ដែលជារបស់ អរិយធម៌ផ្សេងៗគ្នា វាអាចផ្លាស់ប្តូរបាន។ អរិយធម៌ទាំងឡាយ ក៏ដូចជា អង្គភាពទាំងឡាយ ដែលមានន័យជាក់លាក់ ទុកណាជា ព្រំដែន រវាងគ្នា កម្រមានសីមាច្បាស់លាស់ ក៏ វា នៅមាន អត្តភាពនិមួយៗ របស់វា ពិតប្រាកដ។

អរិយធម៌ទាំងឡាយ ទំនងជា អាចនឹងស្លាប់ តែ វាមាន ជីវិតពិបាកក្រៃ ក្នុងដំណើរជីវិតរបស់វា វាវិវត្ត, សម្រួលខ្លួនឯង ហើយ បង្កបង្កើត គ្រប់របៀប នៃ នរសមាគម ដ៏

រឹងប៉ឹងបំផុត។ គឺ របស់ពិត នៃ អរិយធម៌ទាំងឡាយ ដែលមាន រយៈពេលដ៏យូរនោះឯង ជា អត្ថរស់ទោល និង ពិស្តា របស់វា នៅក្នុង និរន្តរភាព នៃប្រវត្តិសាស្ត្រ ដ៏យូរអង្វែង។ អរិយធម៌ទាំងឡាយ គឺ តាមការណ៍ពិត ជា ប្រវត្តិសាស្ត្រ ដ៏វែងឆ្ងាយ នោះឯង។ រាជាធិរាជាណាចក្រ កើតស្លាប់, របបដឹកនាំជាតិ ប្តូរ និង វិលត្រឡប់មកវិញ តែ អរិយធម៌ ឋិតនៅដដែល ហើយ រស់នៅជានិច្ច ក្រោយពីកើតមាន អំពើមិនទៀង នៃនយោបាយ, នៃសង្គម, នៃសេដ្ឋកិច្ច ហើយនឹង អំពើ នៃមនោគមវិជ្ជា ដែរ។ ម្លោះហើយ អរិយធម៌ធំចម្បងទាំងឡាយ នៅក្នុងសតវត្សទី២១នេះ មានតាំងពីច្រើន សហស្សវត្សមកម្លេះ ដូចយ៉ាង អរិយធម៌ ចិន, ជប៉ុន, ឥណ្ឌូ, អ៊ីស្លាម (musulmane), មស្ចឹមប្រទេស, អាមេរិឡាទិន ជាអាថ៌។

អរិយធម៌ទាំងឡាយ ជា អង្គភាព នៃសីលធម៌, វាមិនមែនជា អង្គភាព នៃនយោបាយនោះឡើយ។ ម្លោះហើយ វាគ្មានមុខងារ ជា សារវ័ត្រ[5], អ្នកច្បាប់, ភ្នាក់ងារទារពន្ធ, អ្នកដឹកនាំសង្គ្រាម, មន្ត្រីទូត និង អ្នករដ្ឋការ នោះឡើយ។ ការផ្សំ នៃនយោបាយ នៃ អរិយធម៌ទាំងឡាយ ប្រែប្រួល រវាងគ្នា និង ទៅតាមពេលវេលា។ អរិយធម៌មួយ អាចប្រមូលអង្គភាព នៃនយោបាយ តែមួយ ឬ ជាច្រើន ដូចយ៉ាង ជា

---

[5] សារវ័ត្រ ; responsable de l’ordre ou maintien de l’ordre។

បូរី, រដ្ឋ, រាជាធិរាជាណាចក្រ, សហព័ន្ធ, សម្ព័ន្ធ, រដ្ឋ-ប្រជាជាតិ ឬ រដ្ឋ-ពហុប្រជាជាតិ ហើយ អង្គភាពទាំងនោះ រើសយក សណ្ឋាន នៃ ការដឹកនាំ ផ្សេងៗគ្នា។ លុះចំណេរមក ធម្មជាតិ នៃ អង្គភាព នៃនយោបាយ ដែលផ្សំក្នុង អរិយធម៌ អាចដូរ។ បញ្ជ្រោះ (à la limite) ថា អរិយធម៌ និង អង្គភាព នៃនយោបាយ វាអាច ជាប់គ្នា។ សម័យអង្គរ វាជា អរិយធម៌ ដែលជា រដ្ឋ, ចំណែក ប្រទេសជប៉ុន វិញ ក៏ជា អរិយធម៌ ដែលជា រដ្ឋ នោះដែរ។

ប្រវត្តវិទូម្នាក់ រកឃើញ ចំនួន អរិយធម៌ ធំចម្បង សព្វថ្ងៃ និង អតីតកាល ខុសគ្នា ដូចយ៉ាង លោក Braudel ថា មាន ៧ អរិយធម៌ធំៗ, លោក Toynbee ថាមាន រហូតដល់ទៅ ២៣ តែ ប្រវត្តិវិទូទាំងឡាយនោះ មាន ទស្សនៈស្របគ្នា ថាពិតជាមាន អរិយធម៌ ធំចម្បង និង បរិមណ្ឌល (périphérique) នៅក្នុងលោកនេះ។ ដូចនេះ អរិយធម៌ធំទាំងឡាយ តាមលោក Braudel មានដូចខាងក្រោមនេះ៖ អរិយធម៌ អ៊ីស្លាម, ខ្មែរ, ទ្វីបអាហ្វ្រិកខ្មៅ, ចុងបូព៌ាប្រទេស (ចិនបុរាណ និង ចិនសព្វថ្ងៃ, ឥណ្ឌា បុរាណ និង សព្វថ្ងៃ), ចុងបូព៌ាប្រទេស នៃសមុទ្រ (ឥណ្ឌូចិន, ឥណ្ឌូណេស៊ី, ហ្វីលីពិន, កូរ៉េ និង ជប៉ុន), អ៊ឺរ៉ុប, អាមេរិក, អ៊ឺរ៉ុបដទៃទៀត (មូស្គូវី, រុស្ស៊ី, សហភាពសូវៀត)។

# ការផ្សំកាត់ រវាង ចិន និង ឥណ្ឌា

អរិយធម៌ ចិន ចូលមកដល់ តុងកឹង និង អាណាម តាម ការឈ្លានពាន ដោយកម្លាំងយោធា អស់រយៈពេល ដប់ សតវត្សរ៍។ គឺជា អាណានិគមនិយម ត្រួតត្រា តាម មធ្យោបាយ យោធា, រដ្ឋបាល និង សាសនា (កុងជឺនិយម, តាវនិយម និង ពុទ្ធសាសនា) ទុកជា រឹម នៃ ដែនដី ទូលំទូលាយ ខាងត្បូង ដែលចិនកាន់កាប់ មាននៅក្នុង ប្រវត្តិសាស្ត្រខ្លួន។ ប្រជាជន មានកំណើត នៅក្នុង ដែនដីនោះ ជួនកាល ត្រូវចិន វាយប្រាទចេញ ពីស្រុកកំណើតខ្លួន ជួនកាល បង្ក្រាបបាន អោយនៅក្រោម អំណាចចិន។ ដូចនេះ បានជាមានកើត អនុអរិយធម៌ រស់រវើក នៃ អាណិកជន អណ្ណាម ហើយ បន្ទាប់មក វា ហូរ ធ្លាក់មកក្នុង ឥណ្ឌូចិនខាងត្បូង។

អរិយធម៌ ឥណ្ឌា ហូរចូល ឥណ្ឌូចិន តាម ឈ្មួញសមុទ្រទាំងឡាយ។ គេបង្កើត សាខាគ្រិះស្ថានជំនួញ ជួន ធ្វើសម្ពន្ធមិត្ត ជាមួយ ពួកមេកន្ទ្រាញ ដើម្បី សម្រួល ដល់ វិក្ក័យទំនិញ។ ជួនកាល សម្ពន្ធមិត្តនោះ នាំអោយ ពួកមេកន្ទ្រាញខ្លះ មានបានសម្បត្តិជាច្រើន ហើយនាំអោយ កុលសម្ព័ន្ធខ្លួន មានប្រៀប ខាង បច្ចេកទេស និង វប្បធម៌ ជាង កុលសម្ព័ន្ធ ដទៃទៀត ដែលជា កត្តា អាច បង្ក្រាប ពួក អ្នកទុនខ្សោយ ហើយ បង្កើត រាជាណាចក្រ ឥណ្ឌូនិយម ឬ

ផ្សំកាត់ ឬ ប្លែកមួយ។ ដូចនេះ មានកើត រាជាណាចក្រ ចំប៉ា (អណ្ណាមសព្វថ្ងៃ), មន និង ហ្វូណន នៅ ដែនដីសណ្ដរ នៃ ទន្លេមេកុង ដែលក្រោយមក ត្រូវបាន រាជាណាចក្រ ចេនឡា វាយយកបាន បន្ដមក រួមបញ្ចូលគ្នា ក្លាយ ជា រាជាធិរាជាណាចក្រខ្មែរ មានមហិទ្ធានុភាព នៅ អាស៊ីភាគអាគ្នេយ៍ ក្នុង រយៈពេល ពី សតវត្សរ៍ទី៩ ដល់ សតវត្សរ៍ទី១៤។ ក៏ប៉ុន្ដែ នៅក្នុង រយៈពេលនោះដែរ មាន ប្រជាពលរដ្ឋ ភូមា និង ថៃ (ដែលគេទុកជា ប្រជាពលរដ្ឋសេរី) ចាប់រុករាន នគរខ្មែរ និង មន នាំវិនាស ដល់ ជនជាតិទាំងពីរ បង្កើតបាន ជា រាជាណាចក្រ ភូមា ឈ្មោះ នគរលានជាង[6] (Lan-Xang) ដែលសព្វថ្ងៃ ជាដែនដី ប្ញ៉ា នៃ ប្រទេសលាវបច្ចុប្បន្ន និង ដែនដីរួមមាំ សៀម (le compact Siam) ឬ ថៃ។

## សតវត្សរ៍ទី១៩ មកដល់ សព្វថ្ងៃ

នៅសតវត្សរ៍ទី១៩ អាស៊ីភាគអាគ្នេយ៍ ទុកស្នាមជាប់ជ្រៅ នូវការរុករាន នៃ ពួកអាណានិគមនិយម អង់គ្លេស នៅផ្នែកខាងលិច និង បារាំង នៅផ្នែកខាងកើត។ ប្រទេសចក្រពត្រ ទាំងពីរនោះ ទុក ប្រទេសសៀម ជា នគរឯករាជ្យ ជាប្រភេទ ដំបន់ទ្រា ហើយ ទទួលស្គាល់ លក្ខន្តិកៈនោះ នៅឆ្នាំ ១៨៩៦។ បារាំងសែស បានបញ្ចូល ដែនដី

---

6 នគរលានជាង : តាមទម្លាប់លាវ ច្រើនប្រើថា នគរលានជាង ហ្លួងព្រះបាង។

កុងកឹង, អណ្ណាម, កូសាំងស៊ីន, ខ្មែរ និង លាវ ទៅក្នុង សហភាព ឥណ្ឌូចិន នៅឆ្នាំ ១៨៨៧។ រីឯ ពួក អង់គ្លេស វិញ គេបញ្ចូល នគរភូមា ទៅក្នុង រាជាធិរាជាណាចក្រ ឥណ្ឌា ហើយ ត្រួតត្រា រដ្ឋ មាឡេ ទាំងឡាយ ស្ថិតនៅ ចុងឧបទ្វីប ម៉ាឡាកា (Malacca) ដោយយក សិង្ហបុរី (Singapour) ជាកំពង់ផែ មួយយ៉ាងសំខាន់ នៅ ចុងបូព៌ាប្រទេស។

សង្គ្រាមលោកលើកទី២ ដែនដី អាស៊ីភាគអាគ្នេយ៍ បានធ្លាក់នៅក្រោម ការត្រួតត្រា ប្រទេសជប៉ុន ដែលនាំរំលាយ នូវ ការកសាង អំណាចអាណានិគម។ ក្រោយពីសង្គ្រាម រដ្ឋមាឡេទាំងឡាយ, ប្រទេសសិង្ហបុរី និង ភូមា ទទួលបាន ឯករាជ្យ ដោយមិនចាំបាច់ មាន ការប្រយុទ្ធ។ រីឯ នៅ ឥណ្ឌូចិន មានកើតសង្គ្រាម ទាមទារ ឯករាជ្យ រវាង ប្រជាជនយួន និង បារាំង។ នៅ ឆ្នាំ ១៩៥៤ តាម កតិកាសញ្ញា នៃ ទីក្រុង ហ្សឺណែវ បណ្តាប្រទេស នៅ ឥណ្ឌូចិន បូព៌ា ទទួលបាន ឯករាជ្យ ទាំងមូល នៅ ថ្ងៃ ទី ២១ កក្កដា។ តែ កតិកាសញ្ញា នោះ បាន ចែក ប្រទេសវៀតណាម ជាពីរនគរ ដោយ យក ខ្សែស្របទី១៧ ជា សីមា រវាង យួនខាងត្បូង ហៅថា សាធារណរដ្ឋ វៀតណាម និង ខាងជើង ហៅថា សាធារណរដ្ឋ ប្រជាធិបតេយ្យ វៀតណាម។ យួន ខាងជើង អត្តបញ្ចូល ទៅក្នុង លោក កុម្មុយនិស្ត ដោយមាន ការឧបត្ថម្ភ ពីសំណាក់ សហភាពសូវៀត និង សាធារណរដ្ឋ ចិនប្រជាមានិត្, រីឯ យួនខាងត្បូង វិញ

យក សហរដ្ឋអាមេរិក ជា អ្នកគាំពារ នៅចំពោះមុខ ការគំរាម កុម្មុយនិស្ត។ ជំរើស ខុសគ្នានេះ នាំបង្កើត សង្គ្រាមមួយ រវាង វៀតណាមទាំងពីរ នៅក្នុង បរិយាការណ៍ នៃ សង្គ្រាមត្រជាក់ រវាង លោកកុម្មុយនិស្ត នឹង លោកសេរី។ ស្រុកខ្មែរ និង លាវ ទទួលបាន ឯករាជ្យ ពេញលេញ រៀងៗប្រកាន់យក ជំហរ អព្យាក្រឹត ចំពោះ លោកទាំងពីរ មានទំនាស់មនោគមវិជ្ជា នឹងគ្នា។

ក្រោយទទួលបានឯករាជ្យ ប្រទេសទាំងនោះ បានជួបប្រទះនឹង បញ្ហា ឧនាភិវឌ្ឍន៍។ ដូចនេះ ត្រូវដោះស្រាយជាបន្ទាន់ នូវ បញ្ហា នៃ ការរៀបចំ អោយមាន ឧស្សាហកម្ម និង កសិកម្ម ទំនើប និង សមតា នៃ តុល្យភាព នៃ ការទូទាត់ (balance de paiements), បញ្ហា នៃប្រជាភិវឌ្ឍន៍សព្វវត្តមាន ហើយនឹង បញ្ហា នៃ អស្ថិរភាព នយោបាយនៅក្នុងប្រទេសនិមួយៗ និង ក្នុងដំបន់។

លើសអំពីបញ្ហាទាំងនោះ គឺ នៅមានជានិច្ច នូវ បញ្ហា វប្បធម៌ រវាង ជាតិសាសន៍ តាំងពី បុរាណកាលមក នៅ ឥណ្ឌូចិន។ តំបន់នេះ តែងតែមាន ទំនាស់ធម្មជាតិ រវាង វាល នឹង ភ្នំ។ តំបន់ វាល មាន ប្រជាជន រស់នៅ ច្រើនខ្ចាន់ខ្ចាប់ រីឯ តំបន់ ភ្នំ វិញ ជា តំបន់ មាន ប្រជាជន រស់នៅ តិចតួចណាស់។ តំបន់ វាល ជា ទីកដី នៃ កសិកម្ម បង្កើត បានជា កម្លាំង នៃ សន្ទភាពមនុស្ស (densité

humaine) នៅ ដែនដីសណ្ដរ នៃ ទន្លេក្រហម-ទន្លេមេគង្គ-ទន្លេមេណាម និង ទន្លេអ៊ីរ៉ាវាឌី (Irrawaddy) ។ល។ ទឹកដី កសិកម្ម និង ប្រជាករ ទាំងឡាយនោះឯង បង្កើតបាននូវ អរិយធម៌ ខ្ពង់ខ្ពស់ជាងគេ។ ជនជាតិយួន ជា បុត្រ នៃ អរិយធម៌ចិន រស់នៅ ជាយូរមកហើយ លើ ដែនដីសណ្ដរ នៃ ទន្លេក្រហម ក្លាយ ជា ប្រជាជន ឈ្លានពាន ចូលមកក្នុង ដែនដី រាជាណាចក្រ ហិណ្ឌូ គឺ ចំប៉ា នៅសតវត្សរ៍ទី១៧ ហើយ នៅ សតវត្សរ៍ទី១៨ រុករានបំពាន ដែនដីសណ្ដរ នៃ ទន្លេមេគុង គឺ ទឹកដី កម្ពុជាក្រោម បច្ចុប្បន្ន។ ចំណែកទិសខាងកើតវិញ បង្កើតបាននូវ អរិយធម៌រួមមាំ[7] ហិណ្ឌូនិយម និង ពុទ្ធសាសនានិយមផង មាននៅ ស្រុកខ្មែរ, សៀម និង ភូមា។ រីឯ នៅ តំបន់ភ្នំ នៅគ្រប់នគរ វិញ ប្រជាជនដើម ជាអ្នក វិញ្ញាណនិយម (animistes) អនុវត្តវប្បកម្ម ដុតព្រៃ ដើម្បី គ្រាន់តែ រស់ៗ។

នៅ តណ្ឌូចិន ចម្រុះពណ៌មិនស៊ីគ្នា ពួកអ្នកផ្សាយសាសនាគ្រិស្ត ឬ យេស៊ូគ្រិស្ត ទទួលបានជោគជ័យណាស់ នៅក្រៅប្រទេស ពុទ្ធសាសនានិយម និងអ៊ីស្លាមនិយម។ នៅឆ្នាំ ១៩៥៤ កសិករ និយម សាសនាគ្រិស្ត នៅវៀតណាម ខាងជើង ចំនួន ប្រមាណ ៣០ម៉ឺននាក់ នាំគ្នា រត់មក វៀតណាមខាងត្បូង ដើម្បី វៀរចាក របបកុម្មុយនិស្ត។ ត្រូវដឹងថា

[7] អរិយធម៌រួមមាំ ; civilisations compactes។

ឥទ្ធិពល នៃ សាសនាគ្រិស្ត ទៅលើ ជនជាតិដើម ដែល ជាអ្នកវិញ្ញាណនិយម ជាប្រត្យក្សភាពព្រោះ ជំនឿវិញ្ញាណនិយម មិនមែន ជាសាសនា ដូចនេះ ការផ្សាយ សាសនាគ្រិស្ត វាងាយស្រួលជាង ចំពោះ ប្រជាជន មាន សាសនា ពិតប្រាកដ។ នៅ សហភាព ភូមា នៅ មួយផ្នែកធំ នៃ តំបន់ ការ៉េន (Karen) សាសនា ប្រូតែស្តង់និយម (protestantisme) ក្លាយជា កត្តា សំរាប់ចងសាមគ្គីភាព នៃ ប្រជាជនការ៉េន ហើយនាំគ្នា បះបោលប្រឆាំងនឹង អំណាចមជ្ឈឹម និយម ពុទ្ធសាសនា។

## ការប៉ះទង្គិច រវាង អរិយធម៌

ឥណ្ឌូចិន ក្រោយពីសង្គ្រាមលោកលើកទី២ ជា យុទ្ធភូមិ រវាង លទ្ធិកុម្មុយនិស្ត និង លទ្ធិប្រជាធិបតេយ្យសេរី នាំអោយ ផ្ទុះសង្គ្រាម នៅ ប្រទេសវៀតណាម បន្ទាប់មក នៅ ស្រុកលាវ និង ខ្មែរ។ សន្និសិទ្ធ អន្តរជាតិ នៅទីក្រុង ហ្សឺណែវ នៅឆ្នាំ ១៩៥៤ មាន អនុភាព ត្រឹមតែ គូសចែកទឹកដី អោយបានច្បាស់លាស់ នៃ ប្រទេសទាំងឡាយ ស្ថិតនៅ ក្រោម អាណានិគមបារាំងសែស និង បញ្ជាក់ នូវ ឯករាជ្យភាព និង អធិបតេយ្យភាព នៃ ប្រទេសទាំងនោះ តែប៉ុណ្ណោះ តែ សន្និសិតនោះ មិនបានដោះស្រាយ ស៊ីជម្រៅ នូវ ទាំងខាង ទំនាស់ នៃ មនោគមវិជ្ជា នយោបាយ មាន នៅក្នុង បរិបទ នៃ សង្គ្រាមត្រជាក់ រវាង លោកសេរី និង

លោកកុម្មុយនិស្ត ទាំងខាង ការប៉ះទង្គិច ជាប្រវត្តិសាស្ត្រ រវាង វប្បធម៌ ពីរខុសគ្នា នៅតំបន់ ឥណ្ឌូចិន។ មួយ ជាកូនកាត់ចិន ប្រែក្លាយ ជា អរិយធម៌ វៀតណាម នាមបញ្ញត្តិថា យួន[8], មួយទៀត ជា ការផ្សំកាត់ រវាង អរិយធម៌ឥណ្ឌា នឹង អាយ បង្កើតបាន ជា អរិយធម៌ អង្គរ ដ៏ត្រចេះត្រចង់មួយ នៅ អាស៊ីអាគ្នេយ៍។

## អរិយធម៌យួន

មូលដ្ឋានគ្រឹះ នៃ អរិយធម៌យួន គឺ គ្រួសារ និង ការគោរពបូជា ចំពោះបុព្វបុរស (culte des ancêtre)។ គ្រួសារយួន ស្ថិននៅលើសិនិទ្ធពល ជា លំនាំ សាសនា តំណភ្ជាប់ តាមការគោរព បុព្វបុរស រួបរួមរស់ជាមួយគ្នា រវាង ជីវន្តជន (vivants) ជាមួយ អ្នកស្លាប់។ រាល់ថ្ងៃកំណើត របស់អ្នកស្លាប់, រាល់ខែ ក្នុងថ្ងៃណាមួយ និង ពេលបុណ្យចូលឆ្នាំ ហៅថា តេត (Têt) ក្រុមគ្រួសារ ត្រូវតែ រៀបចំ តង្វាយ សែនដល់ អ្នកស្លាប់នៅលើ វេទី នៃ បុព្វបុរស (autel des ancêtres)។ នៅក្នុងផ្ទះ យួន នៅ បន្ទប់ចម សំរាប់ទទួលភ្ញៀវ គេ តែងឃើញ មាន តុក លាបខ្មូក ពណ៌ ក្រហម ឬមាស លើនោះ មាន ដាក់ បន្ទះឈើ[9] (tablette) ចំនួន៥ ជាតំណាង ៥ ទំនាន់ នៃ បុព្វបុរស។ អ្នកស្លាប់មុនគេ ត្រូវ

[8] យួន : ជាតិមនុស្សអ្នកដែនតុងកឹង, ដែនអណ្ណាម, ដែនកូស័ងស៊ីន។
[9] បន្ទះឈើ ឬ បន្ទះ ធ្វើពី វត្ថុធាតុអ្វីផ្សេងទៀត។

គ្រួសារ ដកចេញ បន្ទះឈើ ជាតំណាងខ្លួន ពី លើតុក ដើម្បី ដាក់ បន្ទះឈើ នៃ អ្នកស្លាប់ថ្មី។ ដើម្បី រក្សា ការ គោរព បុព្វបុរស នោះ នៅពេល មេគ្រួសារ ទទួលមរណៈ ដី មួយចំណែក ត្រូវប្រគល់អោយ កូនប្រុសច្បង ដើម្បី ធ្វើ ការយកផលពីដីនោះ សំរាប់ ទុកជាចំណាយ នៃ ការរក្សា នោះ។ គ្រុះគុណ (faute grave) របស់ជនយួន ចំពោះ បុព្វ បុរស គឺ គ្មានកូន សំរាប់ រក្សា ការគោរពបូជា ចំពោះបុព្វ បុរស។ ម្លោះហើយ ពហុពន្ធភាព មានដើមគំនិត ពី ចំណង់ ចង់មាន កូនច្រើន ជាពិសេស គឺ កូនប្រុស សំរាប់ បន្តត្រកូល។

ដូចនេះ គ្រួសារយួន ស៊ុម ដោយ វិន័យតឹងរឹង នៃ គ្រួសារ ហើយ គ្រួសារ និមួយៗ ជា អង្គភាពពេញលេញ នៃ ភូមិ ហើយ ភូមិនិមួយៗ មាន លក្ខណៈ ជា សមូហភាព គឺ មិន ត្រឹមតែ ជាការប្រជុំ នៃ គ្រួសារ នោះទេ គឺ ជា នីតិបុគ្គល តែម្តង ដែល សមាជិកម្នាក់ៗ រួមគ្នា ក្នុង ស្មារតី នៃ សាមគ្គីភាព។ ដូចនេះ គ្រួសារនិមួយ មិនអាចទទួល បរ ជន ណាម្នាក់ ដោយគ្មាន ការអនុញ្ញាតពី មេគ្រួសារ នោះ ឡើយ ដូចគ្នានឹងភូមិ មិនងាយនឹង ទទួល ជនបរទេស អោយស្នាក់ ពី ក្រាមេស[10] ជាពួកជន រឹងត្អឹងនឹង វិន័យ បុរាណ។ សាមគ្គីភាព សំដែង ជារូបភាព តាម សមាគម

---

10 ក្រាមេស ជាមនុស្សជាធំ, ជាចម្បងក្នុងស្រុក; les notables។

ផ្សេងៗ សំរាប់ជួយគ្នាទៅវិញទៅមក ដូចយ៉ាង សមាគមបុណ្យសព ជាអាទិ៍។

ជំនឿ សាសនា បុរាណ គឺ ជំនឿ គោរពបូជា ចំពោះព្រលឹង (culte des Esprits) ដូចយ៉ាង គោរពបូជា ព្រលឹងខ្លា ជាព្រលឹង កំចាត់ នូវ អារក្សទាំងឡាយ។ ជំនឿលើ ហោរ បូលដោយរោយ ដី ឬ ស្រូវ ឬ អង្ករ ដើម្បី ជ្រើសរើស ថ្ងៃល្អ សំរាប់សង់ ឬ ឡើង ផ្ទះថ្មី ឬ គ្រប់ ព្រឹត្តិការណ៍ ដែលត្រូវធ្វើក្នុងជីវិត។ ការគោរពបូជា ចំពោះបុព្វបុរស ជា ជំនឿ យកគំនិតតាម លទ្ធិខុងជឺ ដែលជា ផ្លូវស្វែងរក ឧត្តមវិចារណញ្ញាណ និង សក្តិយស សំរាប់ជីវិត។ ពុទ្ធសាសនា មហាយាន ជាសាសនាធំចម្បង នៃ ប្រជាជនយួន គោរព អង្គព្រះពុទ្ធសក្យមុនី និង ព្រះជាច្រើនទៀត ដែលមិនទាន់ត្រាស់ជាព្រះពុទ្ធ។ យេស៊ូគ្រិស្ត ក៏ជា សាសនាសំខាន់មួយដែរ នៅស្រុកយួន។ ពាក្យយួន (ដាវ) មានន័យថា សាសនា ហើយរីកសាយន័យថា ផ្លូវ នៃ មនោចិត្ត ជាអនន្ត។ បុគ្គលម្នាក់ៗ ជ្រើសរើស ផ្លូវមនាបៈ[11] រៀងៗខ្លួន ដោយយកគំរាប់តាម បុព្វគតិបណ្ឌិត។ ដូចយ៉ាងនេះ បានជាមានកើតនិកាយមួយ ឈ្មោះ កៅដាយ (Caodaïsme) ដែល គោរពចំពោះ ព្រះពុទ្ធផង, ព្រះយេស៊ូផង និង Mahomet ផង។

[11] មនាបៈ, ដែលជាទីពេញចិត្ត។

អ្នកចេះដឹង ឬ *វិទូអក្សរសាស្ត្រ (les lettrés) ទាំងឡាយ ដែលជា ឧត្តមមន្ត្រីរដ្ឋ មានកិត្យានុភាពក្រៃ ក្នុងទឹកចិត្ត ប្រជាជន ទោះបីខ្លួន មាន ជីវភាពរស់នៅ មិនហ៊ឺហាក្តី ព្រោះ ប្រជាជន ដែលគោរព ការចេះដឹង តែងតែមាន វប្បធម៌ នៃបញ្ញា ក្នុងចិត្ត។ ត្រូវដឹងថា *ឧត្តមមន្ត្រីរដ្ឋ ជ្រើសតាំងឡើង ពីការប្រឡងអាជីពបីឆ្នាំម្តង ពិនិត្យតែ លើចំណេះចេះដឹងទូទៅ[12] របស់បេក្ខជនទាំងឡាយ មកពី គ្រប់មជ្ឈដ្ឋានសង្គម, ដូចនេះ បេក្ខជន ដែលជាកូនអ្នក ក្រ ក៏អាច ប្រឡងជាប់ ជា ឧត្តមមន្ត្រីរដ្ឋ ហៅថា វិទូអក្សរ សាស្ត្រ បានដែរ។ វិញ្ញាសា មានប្រាំវិជ្ជា នៃ អក្សរសាស្ត្រ និង ទស្សនវិជ្ជា[13]។ ពួកមុនីអក្សរសាស្ត្រ និយាយ និង សេសេរ តែ ភាសាវិញ្ញូចិន (langue savante chinoise) ទាំងស្រុង។ តែ ក៏មានដែរ ភាសាសាមញ្ញ នៃ ប្រជាជន ហៅថា nôm តែ ភាសានោះ គេមិនបាន យកមក បង្រៀន នៅក្នុងសាលា រៀន នោះទេ។ អ្នកនិពន្ធ សរសេរសៀវភៅ ប្រវត្តិសាស្ត្រ, ទស្សនវិជ្ជា និង សីលធម៌ ជា អក្សរចិន តែ ក៏មាន សរសេរ ជា អក្សរជាតិដែរ ដូចយ៉ាង រឿងព្រេង, ចំរៀងស្នេហា ។ល។ តែពេលខ្លះ ពួកមុនីអក្សរសាស្ត្រយួន នាំគ្នាសរសេរ អំពី អក្សរសាស្ត្រ ដោយមិនប្រើ អក្សរចិន តែ អក្សរ chu nôm

[12] Un concours unique de culture générale។
[13] វិជ្ជាទាំងនោះ មានចារទុកនៅក្នុងសៀវភៅ ខុងជឺ និង Mencius។

ដែលជា អក្សរចិន កែប្រែទ្រង់ទ្រាយ ដើម្បី តម្រូវនឹង សព្វ យួន។ អក្សរសាស្ត្រនោះ ក៏ល្បីល្បាញដែរ។

បុរាណវិទូ រកឃើញ នូវ ស្នាម នៃ សិល្បៈបុរាណយួន មុន សម័យអង្គរខ្មែរ នៅ Daï-La Thanh និង Co Loa ដែលនាំ អោយ ពួកអ្នកប្រាជ្ញ ទាំងនោះ ទាញគំនិតបានថា សិល្បៈ យួន ក្នុងផ្នែងសំណង់ គឺស្ថិតនៅលើ ការសម្រប អោយស៊ី គ្នា រវាង វិមាន នឹង បរិស្ថាន របស់ខ្លួន អោយកាន់តែ មាន សោភ័នភាព ឡើង។ ផ្ទុយទៅវិញ គេឃើញ សិល្បៈ នៃ ទេសភាព របស់យួន មាននៅត្រឹមតែ នៅកន្លែង ផ្លូវ តែ ប៉ុណ្ណោះ។ តាមការស្រាវជ្រាវ របស់បុរាណវិទូ អាចបញ្ជាក់ បានថា នៅ សតវត្សរ៍ទី១១ នៅ តំបន់ តុងកឹង កំពុងតែ ទទួល ឥទ្ធពល សិល្បៈ ពី ប្រទេសចិន, ឥណ្ឌា និង ឥណ្ឌូណេ ស៊ី។ ដូចនេះ ការរួម នៃ សិល្បៈ ទាំងឡាយនោះ ដែលជា ប្រភព នៃ វិចិត្រសិល្បៈយួន សព្វថ្ងៃនេះ។

## អរិយធម៌ខ្មែរ

អ្នកប្រវត្តិសាស្ត្រខ្មែរ ជាច្រើន ធ្លាប់បានសរសេរ អំពី អរិយ ធម៌ខ្មែរ ជា ភាសាជាតិ ដូច ព្រះភិក្ខុ ប៉ាង ខាត់, លោកស្រី ត្រឹង ងា, លោក ទារ ឆៃសុខ, លី ឆាមតេង, ដែលជាស្នាដៃ សំរាប់អប់រំ យុវជន អោយ ស្គាល់ និង យល់ដឹង ច្បាស់លាស់ អំពី តម្លៃជាតិខ្លួន ដែលជា ប្រជាជាតិ ធ្លាប់មាន អរិយធ ម៌ខ្ពង់ខ្ពស់ នៅក្នុងពិភពលោក បានទុកស្នាម ជា វត្ថុ

ធាតុពិត (éléments objectifs) ដូចយ៉ាង ភាសា, ប្រវត្តិសាស្ត្រ, សាសនា, ប្រពៃណី, ស្ថាប័ន និង វត្ថុធាតុអត្តវិស័យ (éléments subjectifs) ដូចយ៉ាង ស្វ័យអត្តសញ្ញាណកម្ម គឺថា ការស្គាល់ខ្លួនដោយខ្លួនឯង ជា ខ្មែរ ដែលខ្មែរយើងតែងហៅថា ព្រលឹងជាតិរបស់ខ្មែរ។ តែយើងដឹងថា អ្នកជំនាញ ខាង អរិយធម៌ខ្មែរ គឺ អ្នកប្រាជ្ញបរទេស មួយចំនួន ដែលបាន សិក្សា-ស្រាវជ្រាវវា យ៉ាងជម្រៅ តាមគោលវិធី វិទ្យាសាស្ត្រ ដើម្បីបង្ហាញ នូវ តម្លៃ ខ្ពង់ខ្ពស់ នៃអរិយធម៌ខ្មែរ ក្រោយពី អរិយធម៌នោះ លាក់ខ្លួនបាត់ឈឹង នៅក្នុង ព្រហាវ័ន (forêt profonde) អស់ច្រើនសតវត្ស។ តែ អ្នកប្រាជ្ញបរទេស ទាំងនោះ សន្និដ្ឋានថា អរិយធម៌ខ្មែរ ជា និស្សន្ទវត្ថុ (dérivée) នៃ អរិយធម៌ ឥណ្ឌូ ឬឥណ្ឌា កើតឡើង តាំងពី ១៥០០ ឆ្នាំ មុន គ.ស.។ ត្រូវដឹងថា អរិយធម៌ ឥណ្ឌា នេះ មាន អត្ថប្រយោជន៍ជាវត្ថុ ជាសាសនា ផង ប្រព័ន្ធសង្គម ផង ហើយ ន័យពាក្យ ឥណ្ឌូ គឺជា អរិយធម៌ នៃ ភារៈ ជាអ្នកបំភ្លឺផ្លូវ។ យ៉ាងនេះ គេឃើញមាន វប្បធម៌ ដែលមានចងព័ន្ធនឹង អរិយធម៌ ឥណ្ឌូបានហូរចេញពីប្រទេសឥណ្ឌា ចូលមកក្នុង ដំបន់ អាស៊ីភាគអគ្នេយ៍ ឬ ក្នុង ដែន សុវណ្ណភូមិ[14]។ មាន ទស្សនៈខ្លះហ៊ានប្រកាសថា ខ្មែរ ជាឥណ្ឌាទី២ ព្រោះយល់ឃើញថា ស្រុកជាតិខ្មែរ ជា ជាតិ ប្រវេសន៍ ចេញ ពី ប្រទេសឥណ្ឌា ហើយ

14 ដែន សុវណ្ណភូមិ គឺ ស្រុកខ្មែរ, ថៃ, ភូមា និង លាវ។

បានមក លុកលុយ ដណ្ដើម យកទឹកដី របស់ជាតិដើម មួយ គឺ ជនជាតិក្នុង អំបូរ ម៉ាឡាយូ ប៉ូលី នេស៊ីយែន ឬ ជនជាតិ ថៃកាដៃ ប៉ុន្តែ ជា ជាតិមួយដោយឡែកពីឥណ្ឌា ហើយ ស្ថិតនៅក្នុង អំបូរ មន-ខ្មែរ។ តែ មាន ទស្សនៈ ខ្លះ យល់ឃើញថា ជាតិខ្មែរ ជា ជាតិពិសេសមួយ ស្ថិតនៅក្នុង អំបូរ មន-ខ្មែរ ហើយ បានកើតឡើង នៅភូមិភាគ អាស៊ីអាគ្នេយ៍នេះតែម្តង[15]។

គេដឹងថា នៅឥណ្ឌូចិន ជនជាតិខ្មែរ ជាម្ចាស់ទឹកដី ដើមគេបំផុត។ គួរកត់សំគាល់ថា ទោះបី ខ្មែរ និង មន បែកឆ្ងាយពីគ្នា ប្រមាណជិត ១៥០០ឆ្នាំ មកហើយក៏ដោយ ក៏ភាសាមន វប្បធម៌មន ទំនៀមទម្លាប់មនខ្លះ នៅតែមានទ្រង់ទ្រាយ ដូចខ្មែរដដែល។ ដូច្នេះ គេអាចពោលអះអាងថា នាបុព្វសម័យ មន និង ខ្មែរ ជា អំបូរតែមួយ។ ប្រមាណជិត ៣០០០ ឆ្នាំ មុន គ.ស. ជនជាតិមន មករស់នៅក្នុងប្រទេស ភូមា សព្វថ្ងៃ។ នៅ សតវត្សទី២ មុន គ.ស. ជនជាតិមន បានបង្កើត ព្រះរាជាណាចក្រមួយ ឈ្មោះថា សុវណ្ណភូមិ មាន រាជធានី នៅ ថាតុន (Thatön) លើឈូងសមុទ្រ មាតាបង់ (Martaban)។ ហើយនៅខាងជើងប្រទេសថៃ បច្ចុប្បន្ន ជនជាតិមន បានបង្កើត ព្រះរាជា

15 សូមរកអាន សៀវភៅមួយ មានចំណងជើងថា ប្រទេសខ្មែរ (C.M.G – Promo-Khmer) បានសរសេររៀបរាប់យ៉ាងក្បោះក្បាយ អំពី ដើមកំណើតខ្មែរ។

ណាចក្រមួយដែរ នៅសតវត្សទី៨ ឈ្មោះ Haripunjaya។ តាមទស្សនៈ លោក គេង វ៉ាន់សាក់ ខ្មែរ និង មន មានឈ្មោះខុសគ្នា ព្រោះ បានជ្រើសរើសទីកន្លែង សំរាប់រស់នៅខុសគ្នា តែប៉ណ្ណោះ។

តាមឯកសារចិន របស់អ្នកដំណើរចិនម្នាក់ មកដល់ស្រុកខ្មែរ ក្នុងសតវត្សទី៣ ថា ស្រុកខ្មែរ ឈ្មោះ នគរ ហ្វូណន មានដែនដីចម្ងាយ ៣០០០ លី ខាងលិច ប្រទេស លីយីដូច្នេះ ដែនដី ហ្វូណន គឺ ស្ថិតនៅ លើទឹកដី កម្ពុជាក្រោមសព្វថ្ងៃនេះ។ តាមទស្សនៈ ប្រវត្តិវិទូបារាំងសែស ឈ្មោះ G. Cœdès ថា ពាក្យនេះ ក្លាយចេញពីពាក្យខ្មែរ វ្នំ ដែលសព្វថ្ងៃ ក្លាយជា ភ្នំ ដូចនេះ ស្រុកខ្មែរ ជំនាន់ដើម មានឈ្មោះថា នគរភ្នំ។ តាមឯកសារចិនដដែលនោះថា នគរហ្វូណន់មានស្តេចស្រីមួយអង្គសោយរាជ្យ ព្រះនាម លីវ យី។ ប្រជាជនខ្មែរ គោរពបូជានាគ ដែលគេចាត់ទុកជា អាទិទេព។ ដូច្នេះហើយ បានជា នៅក្នុង ពង្សាវតារខ្មែរ គេច្រើនតែនិយាយ អំពី នាងនាគ, ស្តេចនាគ និង នាម៉ឺននាគ។

តាមឯកសារប្រវត្តិសាស្ត្រផ្សេងទៀត កត់ទុកថា មាន ព្រាហ្មណ៍ ម្នាក់ ឈ្មោះ ហ៊ុន ទៀន បានលើកទ័ពតាមសំពៅកាត់ឆ្លងតាមសមុទ្រ ចូលមកវាយប្រហារលុកលុយ កាន់កាប់ត្រួតត្រា នគរហ្វូណន ហើយ បានរៀបអភិសេកជាមួយនឹង នាង លីវ យី ហើយបានឡើងសោយរាជសម្បត្តិ

នៅ នគរហ្វូណន ចាប់ពីថ្ងៃនោះមក។ មានឯកសារផ្សេង ទៀតថា ប្រមាណជិត ៥០ឆ្នាំ ក្រោយ គ.ស. មាន ព្រាហ្មណ៍ ក្លឹង ម្នាក់ ឈ្មោះ កៅណ្ឌិន្យ មកពីប្រទេស មាលាយូ (Malaisie) ដែលជាដែនដី អាណានិគម ពួកឥណ្ឌា នៅ សម័យនោះ បានវាយលុកលុយ តាមផ្លូវសមុទ្រ នគរហ្វូ ណន ហើយ ច្បាំងឈ្នះ ស្តេចស្រីនគរនោះ ព្រះនាម លីវ យី។ បន្ទាប់មក ព្រាហ្មណ៍ កៅណ្ឌិន្យ បានឡើងគ្រងរាជសម្បត្តិ ហើយ បានរៀបអភិសេក ជាមួយនឹង ស្តេចស្រី លីវ យី តែ ម្តង។ ចាប់ពីពេលនោះមក ភាសា សំស្ក្រឹត បានក្លាយជា ភាសាផ្លូវការ របស់ខ្មែរ ហើយ រាជវាំង (la cour) មានរូប ភាព បេះបិទនឹង រាជានិយម ឥណ្ឌា, ការរៀបចំសង្គម គឺ ឈរលើ ប្រព័ន្ធ នៃ វណ្ណៈ នៃ ព្រាហ្មណ្ណសាសនា ជា ពិសេស វ ណ្ណៈ ក្សត្រិយ:, ព្រាហ្មណ:, វៃស្ស និង សូទ្រ: តែ ការអនុវត្តន៍ មិនសូវតឹងរ៉ឹង ដូចនៅឥណ្ឌា នោះទេ ព្រោះ មិនចង់អោ យមាន ទំនាស់នឹង ទំនៀមទំលាប់ របស់អ្នកស្រុកអាយ។ ទោះបី របៀបនិទានរឿង មាន សភាព ប្លែកៗគ្នា ក៏ដោយ គេអាចសន្និដ្ឋានបានថា តួអង្គ ហ៊ុន ទៀន ឬ កៅណ្ឌិន្យ ជាមនុស្សតែមួយ។ ក៏ដូចជា តួអង្គ ព្រះថោង គឺជា តួអង្គ កៅណ្ឌិន្យ នៅក្នុងរឿង ព្រះថោង-នាងនាគ នៅក្នុង ពង្សាវតារ ខ្មែរទៀតដែរ។ រឿងព្រេងខ្មែរ ទាំងនោះឯង បង្ហាញ នូវ លក្ខណ:រួមមួយ គឺ ការហូរចូល វប្បធម៌ ឥណ្ឌា មកក្នុងស្រុកខ្មែរ នាំបង្កើតបាន នូវ វប្បធម៌ចំរុះមួយ

ដែលបាន វិវត្តន៍ រហូតមកដល់សព្វថ្ងៃនេះ។ ដូចនេះ ខ្មែរយើង អាចសួរជាសំនួរថា តើ អរិយធម៌ ខ្មែរដើម មានគុណភាព បែបយ៉ាងណាដែរ ? មុននឹងឆ្លើយនឹងសំនួរនេះ គួរគប្បី ពិនិត្យ អំពី ធាតុ នៃ អរិយធម៌ ដើម្បី បំភ្លឺ ការសាកល្បងពិចារណា បន្ត របស់យើង។

នៅទីនេះ យើងលើកយកតែ លក្ខណៈសំខាន់ៗ នៃ អរិយធម៌ខ្មែរ មកអធិប្បាយ ដូចយ៉ាង គ្រួសារ, ភូមិ, សាសនា, ភាសា, អក្សរ, អក្សរសិល្ប៍, សិល្បៈ, អ្នកចេះដឹង និង ស្ថាប័នជាតិ។ ប្រវត្តិវិទូបរទេស ចែក អរិយធម៌ ជាពីរកាលសម័យធំៗ : កាលសម័យ បរិប្រវត្តិសាស្ត្រ និង កាលសម័យប្រវត្តិសាស្ត្រ។ តែ កាលសម័យ ដែលគេ យកចិត្តទុកដាក់ខ្លាំង គឺ សម័យអង្គរ ដែលជា សម័យរុងរឿង នៃ ជនជាតិខ្មែរ។ ប្រវត្តិវិទូ មានយោបល់ខុសគ្នា អំពី ប្រភព នៃ ជាតិសាសន៍ខ្មែរ។ ជាសង្ខេប វាមានបីទស្សនៈខុសគ្នា : ទស្សនៈទី១ ថាខ្មែរជា ជនជាតិឥណ្ឌាទី២ ផ្ទេរទេសន្តរប្រវេសន៍ ពីឥណ្ឌា មករស់នៅដំបន់សុវណ្ណភូមិមុនគេ; ទស្សនៈទី២ គឺថា ជនជាតិខ្មែរ ពិតមែនតែមានប្រភព ចេញពីឥណ្ឌាពិតមែន តែ ជា ជនជាតិ ខុសពី ជនជាតិឥណ្ឌាទាំងស្រុង នាំគ្នាចាកចេញពីឥណ្ឌា មករស់នៅ តំបន់ ឥណ្ឌូចិន មុនគេ; ទស្សនៈទី៣ គឺ ជនជាតិខ្មែរ មានកំណើត នៅលើទឹកដី របស់ខ្លួនតែម្តង តែបាន ទទួលឥទ្ធិពលពី អរិយធម៌ឥណ្ឌា។ តែទោះបី ទស្សនៈទាំងបីនេះ ខុសគ្នាយ៉ាងណាក៏

ដោយ តែចំណុចរួមមួយ គឺ យល់ស្របគ្នាថា ជនជាតិខ្មែរ ជាជនជាតិ រស់នៅមុនគេ នៅតំបន់ មជ្ឈិម និង ដែនដីសណ្ត នៃ ទន្លេ មេគង្គ ដូចជា ទឹកដៃ ប្រទេសថៃសព្វថ្ងៃ រហូត ទៅដល់ សមុទ្រចិន។ តាមសៀវភៅ[16] សរសេរ ដោយ លោក សាស្ត្រាចារ្យ វិជ្ជបណ្ឌិត ថាច់ ទាន់ ស្រុកខ្មែរ ជា ស្រុក មាននគរបូរីចំណុះ ជាច្រើន ស្ថិននៅក្រោមអំណាច រាជាណាចក្រ អធិរាជមួយ។ ដូចជា រាជាណាចក្រ អង្គរបូរី ដែលចិនហៅថា ហ្វូណន ក្រោយឆ្នាំ ៦៣០ ក្រោយ គ្រិស្តសករាជ ត្រូវបាន សមន្តរាជ របស់ខ្លួន ឈ្មោះ កម្ពុជា វាយបញ្ចូល ក្នុងរដ្ឋកម្ពុជា រួចក្លាយជា រាជាណាចក្រអធិរាជ តែម្តង។ ទោលិកា (berceau) នៃ នគរហ្វូណន គឺ អតិត ទឹកដី កូសាំងស៊ិន បារាំងសែស ឬ វៀតណាមខាងត្បូង មានរាជធានី នៅ ស្រុកអង្គរបូរី ក្នុងខេត្ត តាកែវ សព្វថ្ងៃ[17]។ នគរហ្វូណន មាននគរចំណុះ ជាច្រើន បណ្តានគរទាំងនោះ មាន នគរ ចេនឡា។ ទីកំណើត ចេនឡា គឺនៅត្រង់ ជ្រលងភ្នំ រ៉យអែត និង ទន្លេមូល ដែលជា ដៃទន្លេ នៃ ទន្លេ មជ្ឈិម មេកុង ហើយ លាតសន្ធឹង ទៅខាងត្បូង ដោយប្រើ នយោបាយ វាតទឹកដី ជានិច្ច រហូត លេបបាន ទឹកដី នគរហ្វូណន ទាំមូល។ នៅ សតវត្សរ៍ ទី៥-ទី៦ នគរ

[16] Thach Toan : Histoire des Khmers, Edition L'Harmattan.

[17] លោក G. Coedès មានទស្សនៈផ្សេងថា រាជធានី នគរហ្វូណន ឈ្មោះ វ្យាធបុរ ស្ថិននៅ បាភ្នំ នៅក្នុងខេត្ត ព្រៃវែង នៅក្បែរ ស្រុក បាណាម ទៅវិញ។ ទស្សនៈនេះ ខុសពី លោក Claude Jacques ថានៅ អង្គរបូរី ក្នុងខេត្តតាកែវ ព្រោះថា នៅបាភ្នំ គេគ្មានឃើញ ទាល់តែសោះ នូវ ស្នាម នៃ អត្ថភាព រាជធានី ឈ្មោះ វ្យាធបុរ នោះ។

ចេនឡា មានទឹកដី ផ្នែងខាងជើងទាំងអស់ នៃ ប្រទេសថៃ គឺ ខេត្ត នគររាជសីមា, អ៊ូបុន, ឧត្តុន និង រយអែត និង ពាក់កណ្ដាលខាងត្បូង នៃប្រទេសលាវ នូវ មួយផ្នែកធំខាងជើង នៃ ស្រុកខ្មែរសព្វថ្ងៃ គឺខេត្ត ស្ទឹងត្រែង, ក្រចេះ និង ខាងត្បូង នៃ ខេត្តកំពង់ធំ។

ជនខ្មែរ មាន សម្បុរ ស្រអែម មាន កំពស់មធ្យម ១,៦១ ម៉ែត្រ មានភ្នែកបើកធំ, ច្រមុះទូលាយ, ក្បាលពយ មានរាងកាយ សមរម្យ[18]។ ឧសពីឯកសារបុរាណចិន សរសេរ ដោយ ជនចិន ឈ្មោះ k’ang T’ai អំពី ជនជាតិខ្មែរ នៅសម័យ ហ្វូណន ថា ‹ប្រជាជន ហ្វូណន ជាមនុស្ស មានរាយកាយ អាក្រក់ មានសក់ក្រញាញ់ ហើយ ចេញដើរទៅណាមកណា ទាំង អាក្រាត តែ មិនលួច ជាដាច់ខាត។ ជនខ្មែរ ដាក់ ម្ហូបចំណី នៅក្នុង ភាជន៏ ធ្វើអំពីប្រាក់ ហើយ នៅក្នុងផ្ទះនីមួយៗ មាន ទូដាក់សៀវភៅ និង បណ្ណសារផ្សេងៗ។ ដូចនេះ ប្រជាជនខ្មែរ សម័យនោះ ពុំមែនជា មនុស្សព្រៃផ្សៃ តែជាមនុស្ស មានវឌ្ឍនាការលឿនទៅមុខហើយ។

ជនជាតិខ្មែរ ហៅឈ្មោះ នគរខ្លួន ថា ‹ស្រុកខ្មែរ› គឺថាស្រុក របស់ជនជាតិខ្មែរ ទោះបី មាន ឈ្មោះនគរ ជាផ្លូវការ

[18] ក្នុងសៀវភៅ លោក P.W. Schmid (Les peuples Mon-Khmer) បោះពុម្ពផ្សាយនៅឆ្នាំ ១៩០៨។

ថា កម្ពុជា និង ឈ្មោះ ដែល ចិន ចារនៅក្នុង ឯកសារ បុរាណ ថា ហ្វូណន និង ចេនឡា ក៏ដោយ។

ផ្ទះខ្មែរ ជាផ្ទះមានសសរចន្ទល់ ពី ២ ទៅ ៤ ខ្នង មានកំពស់ច្រើនតែ ២ម៉ែត្រ មាន ជណ្ដើរ សំរាប់ឡើងលើផ្ទះ ព្រមនឹង កាំជណ្ដើរ ចំនួនសេស ជានិច្ច។

## គ្រួសារខ្មែរ

គ្រួសារខ្មែរ ស្ថិតនៅក្រោម អំណាចមាតា (មតេយ្យកា)។ អ្វីដែលទុកជា ឧត្តុងឧត្ដម ខ្មែរ ហៅថា មេ មានន័យថា មាតា ជា អ្នកដឹកនាំ។ លោក សាស្ត្រាចារ្យ វិជ្ជបណ្ឌិត ថាច់ ទាន់ សេសេរ ពន្យល់យ៉ាងពិស្ដា អំពី ប្រព័ន្ធ នៃ មតេយ្យកា នៅក្នុង សៀវភៅរបស់លោក ដែលយើងយក ខ្លឹមគំនិតមួយចំនួន មកអធិប្បាយ នៅទីនេះ។ អ្នកខ្លះយល់ឃើញថា ប្រព័ន្ធ មតេយ្យកាខ្មែរ គឺស្ថិតនៅលើ សេរីភាពរបស់ស្ត្រី ជ្រើសរើស បុរស ជា ស្វាមី ឬ ជា ដៃគូ សំរាប់រួមរក្ស តែប៉ុណ្ណោះ ដូច ប្រព័ន្ធ នៃ ពហុស្វាមី មាននៅ ទីបេ និង ឥណ្ឌា។ ជារឿយៗ គឺ ស្ត្រីម្នាក់ រៀបការ ជាមួយ បុរសច្រើននាក់ ដែលជាបងប្អូននឹងគ្នា ព្រោះ គេលើកយកលេសថា កុំអោយ បែកសម្បត្តិ គឺចែកដី នៅក្នុងគ្រួសារ ដែលជាដីមូលដ្ឋាន នៃ សេដ្ឋកិច្ចគ្រួសារ។ នៅក្នុង ឯកសារជនចិនឈ្មោះ Tcheou Ta Kouan[19] មានសរសេរថា : នៅ

[19] ជនចិន ដែលបានមកស្រុកខ្មែរ នៅឆ្នាំ ១២៩៦។

ក្នុងគ្រួសារខ្មែរ បើមានកើតកូនស្រី គេអោយពរថា សូមអោយកូនស្រីនេះ មានស្វាមី មួយរយ ឬ មួយពាន់ ស្វាមី។ តែ ស្រុកខ្មែរបុរាណ មិនមាន រហូតដល់ទៅ ប្រព័ន្ធ នៃ ពហុស្វាមីនោះទេ តែវាអាចមាន នៅត្រឹមតែលើ សេរីភាពស្ត្រី ជ្រើសរើស ស្វាមី តែប៉ុណ្ណោះ ដែលជា សេរីភាពសារពើនៅក្នុង ប្រព័ន្ធ នៃ មតេយ្យកា។ នៅស្រុកខ្មែរបុរាណ ប្រព័ន្ធ នៃ មតេយ្យកា ទុកជា របបសង្គម គឺ គ្រឹះ ស្ថិតនៅលើ ការគោរពចំពោះ ‹មេ-បា› គឺថា គោរព មាតាបិតា តែទុក មាតា ជា ភាពប្រសើរ។ ដូច្នេះ មាតា ជា មេ សារពើឋាន នៅក្នុងការរស់នៅ នៅក្នុងសង្គមខ្មែរ ដូចយ៉ាង ខ្មែរប្រើពាក្យ មេទ័ព, មេស្រុក, មេភូមិ, មេឃ្លាំង, ទន្លេមេកុង ។ល។ អ្វី ដែលជា រូបភាព នៃ ស្ត្រី ជា ភាពប្រសើរ ដូចយ៉ាង ពហិលក្ខណៈ នៃ ព្រះមហាក្សត្រ មាន រូបភាព ជា ស្ត្រី គឺថា ផាត់ម្សៅ ពណ៌ក្រហម លើ បាតដៃ និង បាតជើង, សៀតផ្កា លើផ្នួងសក់, ពាក់ខ្សែកធ្វើពីគជ ពាក់ក្រវិល ហើយ ប្រើ ពាក្យ ចាស[20] ដែល ជា ពាក្យសំរាប់ស្ត្រីនិយាយ ជំនួសពាក្យ បាត សំរាប់បុរស។

តែ ការគោរពចំពោះ ‹មេ-បា› មិនដូច ការគោរពបូជាចំពោះបុព្វបុរស របស់ ជនជាតិ ចិន-យួន នោះឡើយ ព្រោះថា ខ្មែរ គោរព មាតា-បិតា ដែលកំពុងរស់នៅ រីឯ

[20] ពាក្យ ចាស នេះ ជា ពាក្យទោល សំរាប់និយាយ នៅក្នុង រាជវង្សានុវង្ស។

ចិន-យួន គោរពព្រលឹង បុព្វបុរស នៃ គ្រួសារ ដែលបាន ចាកស្ថាន ទៅហើយ។ ជនជាតិខ្មែរ គោរពចំពោះមាតា ព្រោះ ទុកជា ខ្លឹម នៃ គ្រួសារ រីឯ ជនជាតិ ចិន-យួន គោរពបូជាចំពោះបុព្វបុរស ព្រោះទុកជា ទំនាមទំលាប់ នៃ គ្រួសារ។

តែមកដល់ សម័យ ពុទ្ធសាសនាហីនយាន[21] មានឫទ្ធិ គឺ ចាប់ពី សតវត្សរ៍ទី១៤ មក គេឃើញថា ប្រព័ន្ធ នៃ មេតេ យ្យកា ចុះថយ ឥទ្ធិពល ជាខ្លាំង នៅក្នុងសង្គមខ្មែរ រហូត លុបបាត់តែម្តង។ បុព្វហេតុ គឺ ជំនឿលើ ពុទ្ធសាសនា ហីនយាន ដែលក្លាយជា សាសនាជាផ្លូវការ របស់រដ្ឋខ្មែរ។ តាម ការសរសេរ របស់លោក ថាច់ ទាន់ ថា ពួកសាសនិក ទុក ស្ត្រី ជា ប្រភព នៃ តណ្ហា ហើយ តណ្ហា ជា ប្រភព នៃ ទុក្ខ របស់មនុស្សលោក ដែលត្រូវតែ កំចាត់ចោល។ ចំពោះ ពុទ្ធសាសនិក យល់ថា មនុស្ស តែងតែមាន បាបចិត្ត ជា ច្រើន នាំអោយជាប់អន្ទាក់ទុក្ខ គ្រប់បែបយ៉ាង ហើយ អន្ទាក់ ដែល មាន គ្រោះថ្នាក់ច្រើនជាងគេ គឺ ឧបាយ របស់ស្ត្រី នោះឯង។ យើង ពុំយល់ស្របនឹង ការយល់ឃើញ បែបនេះ ព្រោះ នៅក្នុង ពុទ្ធសាសនាហីនយាន វាគ្មានឪ វាទណាមួយ ទុក ស្ត្រី ជា ចារី នៃ បាបកម្ម កំណាចបំផុត ដែលនាំអោយ សាសនិក ទុកស្ត្រី ជាអន្តរាយនោះឡើយ។

---

[21] ពុទ្ធសាសនាហីនយាន ជាលទ្ធិនាំមកពី លង្កា មិនត្រឹមតែមានជ័យជំនះ លើសាសនាព្រាហ្មណ៍ គឺលើ ពុទ្ធសាសនាមហាយានទៀត។

ចំពោះយើង ការចុះថយ មគេយ្យកា នៅក្នុងសង្គមខ្មែរ គឺជា វិវត្តន៍ ចិត្តគំនិត ពី មគេយ្យកា ជា របបសង្គម ទៅជា អតិថិធម៌[22]ធម្មតា តែប៉ុណ្ណោះ។ ដូចនេះ ជនជាតិខ្មែរ នៅតែគោរពស្ត្រី ព្រោះមិនដែលទុកស្ត្រី ជាភេទទុនខ្សោយ តែជាស្តំមួយ សំរាប់ទ្រទ្រង់គ្រួសារ ស្មើភាពនឹង បុរស ដែលមាននៅក្នុងជាតុដើម នៃ ការគោរពចំពោះ មេ-បា នោះឯង។

គួរកត់សំគាល់ថា ក្នុងការវិវត្តន៍ នៃសាសនាព្រហ្មណ៍ ពីការទុក ព្រះឥន្ទ្រ ជាអាទិទេពធំ មកយក ព្រះព្រហ្ម ជាសារណៈធំចម្បង ដោយសារតែព្រះឥន្ទ្រ ឈ្លក់ស្រវឹងកាមឈ្លប់មុខ ដើរលួចប្រពន្ធគេឯង សាសនិក នាំគ្នាបង្កើត ទេពតា ព្រះព្រហ្ម កុំអោយមានរូប ពោលថា កុំអោយមានប្រពន្ធ មានតែម្នាក់ឯង ដូច្នេះបានជាកើត ប្រពៃណីឡើងថា « ស្ត្រីជាទោស នៃ ព្រហ្មចរិយៈ »។ ប្រាស្នាថា តើ ការវិវត្តន៍ នេះ វាអាចមាន ការចលនា ទៅលើ ការចុះថយ មគេយ្យកា នៅក្នុងសង្គមខ្មែរ ដូច្នេះទេដឹង ? ព្រោះថា បើទុក ស្ត្រីជាធំ ហេតុអ្វី ត្រូវហាមខាត់ ទេពតា ព្រះព្រហ្ម មិនអោយមានប្រពន្ធ ?

---

[22] Règle du savoir vivre.

## ភូមិខ្មែរ

ខ្មែរហៅភូមិខ្លួនថា ស្រុកខ្ញុំ ដូចហៅ នគរ ថា ស្រុកខ្មែរ នោះដែរ។ ភូមិខ្មែរ ជាទីប្រជុំជនតូច មាន ប្រជាជន ភាគច្រើន ជា កសិករ រស់នៅក្បែរ ដីស្រែ របស់ខ្លួន។ ភូមិ គ្មានរចនាសម្ព័ន្ធសង្គម រៀបចំច្បាស់លាស់។ អ្នកភូមិម្នាក់ៗ រស់នៅ ក្នុង គំនិត ឯកាផង និង សហការផង ដែល អាស្រ័យទៅលើ ករណី នីមួយៗ។ តួយ៉ាង សហការ ជា កិច្ចការសាធារណៈ (services publics) : ជិកស្រះ ទុកជា ភោគសម្បត្តិរួម[23] ក្នុងភូមិ។ តួយ៉ាង សហការ ជា សាមគ្គីភាព រវាង អ្នកភូមិ: ជួយស្ទូង, ជួយច្រូតស្រូវ, ជួយសង់ផ្ទះ ។ល។

នៅក្នុងភូមិ គ្មាន មេភូមិតែងតាំងទេ តែ មានអ្នកដឹកនាំ ដែលអ្នកភូមិទាំងឡាយ ទទួលស្គាល់នៅក្នុងចិត្តព្រោះ ទុកគាត់ ជា ព្រឹទ្ធាចារ្យ។ ជននោះ ដឹកនាំភូមិ នៅក្នុង គំនិតណែនាំ ច្រើនជាង បង្គាប់ ព្រោះ ខ្លួន គ្មានអំណាច ជាផ្លូវការទេ។ ដូច្នេះ ការសំរេច ស្ថិតនៅក្នុងយោបល់រួម តែ ការអនុវត្តន៏ ពុំមាន លក្ខណៈ ជាកាតព្វកិច្ច នោះឡើយ សំរាប់អ្នកភូមិទាំងឡាយ។ ដូចនេះគេអាច សន្និដ្ឋានបានថា មាន សាមគ្គីភាព រវាង អ្នកភូមិ តែ គ្មាន សិនិទ្ធពលសង្គម នៅក្នុងភូមិ។ បាតុភូតនេះ នាំអោយ ភូមិខ្មែរ មានគ្រឹះស្រួយ នៅចំពោះមុខ ការ

23 ភោគសម្បត្តិរួម ; biens communs។

រុករុល គ្រប់បែបយ៉ាង មកពីក្រៅ។ គួរកត់សំគាល់ថា ភូមិខ្មែរ មាន ភាពនៅដាច់ស្រយាល ពីមជ្ឈមណ្ឌល រដ្ឋបាលផង និង នៅឆ្ងាយពីគ្នាផង។ ដូចនេះ ពន្ធនាការជាមួយរដ្ឋ គឺនៅត្រឹមតែ ការទាក់ទង នៃ ប្រព័ន្ធ ពន្ធដារ ដែល សាមីខ្លួនជាម្ចាស់របស់ ត្រូវបង់ជូនរាជការ ដូចយ៉ាង ពន្ធដី, ពន្ធស្រូវ, ពន្ធទូក, ពន្ធទាស និង ពន្ធខ្លួន។

## ជំនឿ និង សាសនា

ជនជាតិខ្មែរ មានជំនឿដើម មុនទទួលយក សាសនាបរទេស មកទុកជា សាសនាខ្លួន គឺ ព្រាហ្មណ៍សាសនា និង ពុទ្ធសាសនា។ ជំនឿដើមនេះហើយ ជា មូលដ្ឋានគ្រឹះ នៃ ជនជាតិខ្មែរ។ ដូចនេះ អ្វីដែល ខ្មែរ ទទួលយកពីបរទេស ទាំង សាសនាក្តី ភាសាក្តី អក្សរក្តី អក្សរសិល្ប៍ក្តី សិល្បៈក្តី ខ្មែរតែងតែ រក្សាមូលដ្ឋានគ្រឹះ របស់ខ្លួនជានិច្ច ក្នុងគំនិត ពុំទុកគំនិតបរទេសទាំងដុល នោះឡើយ ដូចនេះ ខ្មែរតែងតែយក គំនិតបរទេស មកកាលៃលក្ខណៈ អោយទៅជាខ្មែរ ដើម្បី ស្របស្រួលមកនឹង ចំណង់ចំណូលចិត្ត របស់ខ្មែរ។

ជំនឿដើមខ្មែរ គឺ ការគោរពចំពោះ មេ-បា ការគោរពចំពោះ នាង កាហ៊ុញ និង ក្រពើ នូវ ការគោរពចំពោះ អ្នកតា។

## ការគោរពចំពោះ មេ-បា

ជនជាតិខ្មែរ គោរព មេ-បា ដែល ខ្មែរ យកឈ្មោះមកដាក់អោយ ប្រាសាទទាំងឡាយ ដូចយ៉ាង មេបុណ្យ, បាយន្ត, បាពួន ។ល។ រីឯ ឈ្មោះ បា ខ្មែរយកមក ដាក់ ឈ្មោះអោយ ប្រាសាទ ឬ ទីកន្លែងដែរ ដូចជា បាខែង, បាដែង, បាតើ, បារិយា, បាណាម។

លោក វ៉ាន់ ឌីកាអុន, បញ្ញាវន្តខ្មែរ ល្បីល្បាញមួយរូប, ពន្យល់ពាក្យ មេបា ថា[24] : «*នៅក្នុងគ្រួសារនិមួយៗ សមាជិកគ្រួសារ គ្មានឯកភាពគ្រប់គ្រាន់ក្នុងការសម្រេចចិត្ត ដោយខ្លួនឯងឡើយ នោះរឿង ស្នេហា ដែលជា រឿងផ្ទាល់ខ្លួនសុទ្ធសាធ នោះក៏ដោយ។ បើ កម្លោះ ក្រមុំស្រឡាញ់គ្នា គេត្រូវសួរចិត្ត មេបា សិនថា តើព្រម ឬមិនព្រម។ បើស្រឡាញ់គ្នាយ៉ាងណាក៏ដោយ តែបើមេបាមិនព្រម ក៏ពុំអាចស្រឡាញ់គ្នាកើតដែរ*»។ ការគោរពនេះ វាជា ការគោរពចាស់ទុំ ដូចមានចែងនៅក្នុង ច្បាប់ល្បើក របស់ព្រះភិរម្យភាសាអ៊ូ ហៅ ងុយ ថា : «*រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ខុសផ្លូវ កុំព្រហើនភ្លេចម៉ែ កុំប្រែហួសឱ ឃើញចាស់សក់ស្កូវ កុំត្រូវមើលងាយ*»។

---

[24] ដកស្រង់ចេញពី អត្ថបទ របស់លោក វ៉ាន់ ឌីកាអុន មានចំណងជើងថា សង្គមសក្តិភូមខ្មែរ នៅក្នុងរឿងទុំទាវ។

លោក វ៉ាន់ ឌីការអុន យល់ឃើញថា ការគោរព មេបា តាម ដំបូន្មាននិច្ច័យ (le sens morale) បើមានលក្ខណៈ តឹងតែងពេក វាជា ការកាច់ឲបាក់ជាផ្ទត់ នៃ អក្សកិរិយា របស់មនុស្សម្នាក់ៗ ឲរស់តាមទំនៀមទម្លាប់តឹងរ៉ឹង នោះឯង។ ដើម្បីរក្សាទំនាមទម្លាប់ ឲបានគង់វង់ សមាជិក នៃ សង្គម មាន មេបា ជា សក្ការៈដាច់ខាត ត្រូវតែបោះបង់ចោល នូវ គំនិតរិះគន់ ពុំនោះសោត គេទុកជាមនុស្សពាល ដែលគេឈប់រាប់អាន។

តាមទស្សនៈ លោក កេង វ៉ាន់សាក់ ‹ការគោរព មេបា› ជាប្រព័ន្ធ នៃ ចិត្តនាការខ្មែរ[25] មានជម្រៅជ្រៅណាស់ គឺប្រៀបធៀបទៅនឹង រូបភាព នៃ មនុស្ស សាប គ្រាប់ពូជឲចេញពន្លក នៅនិទាឃរដូវ, វិកសិត[26] ជាបុប្ផា នៅវស្សានរដូវ,មានផ្លែ នៅសរទរដូវ, សំរាប់ រក្សាគ្រាប់ពូជ នៅហេមន្តរដូវ។ គឺជា វាលវែងវដ្តសង្សារ (cycle de vie) នៃធម្មជាតិ ឬ មនុស្សជាតិ។ គឺ ជា ចិត្តនាការ ជាថាមពលចេះគ្រោងផែនការ នៅក្នុងសង្គមខ្មែរ សំរាប់ អនាគត។ ពាក្យ **មេ** ជា ឧត្តមចិត្តនាការ មានប្រភព ចេញមកពីសហអរិយធម៌ទាំងឡាយ នៃ ក្រុមមនុស្សផ្សេងៗគ្នា ដើម្បីកសាង អរិយាធម៌ថ្មី រិតតែ ខ្ពង់ខ្ពស់ និង កាន់តែមានថាមពល ខ្លាំងក្លា ថែមទៀត ពោលថា បង្កើតជា ប្រជា

25 ចិត្តនាការខ្មែរ ; la pensée khmère។
26 វិកសិត : វីក ; s’épanouir។

ជាតិមួយ ដែលមាន សមាជិកម្នាក់ៗ ស្គាល់ជាក់លាក់ នូវ សិទ្ធិ និង ការណីយកិច្ច របស់ខ្លួន។ រឿង ព្រះថោង និង នាងនាគ ជា ឧទាហរណ៍មួយ បញ្ជាក់ នូវ សហអរិយធម៌ នេះឯង។ នៅក្នុងពាក្យ **បា** ហៅថា ‹ផ្លូវ› មាន សញ្ញាណ បី យ៉ាង : ព្រះ, ថៅ និង តា។ បា ជា គំនិត នៃ គំរោង នៃ សង្គមមួយ ដែលមានគោលដៅ ច្បាស់លាស់ សំរាប់ ការរស់ នៅ។ គំរោង នៃ សង្គមនោះ គឺ ព្រះ ក្នុងនោះ មាន អ្នក ដឹកនាំជាទីស្នេហា[27] គឺ ថៅ, ដែល ជា អ្នកដឹង មានក្បួន ដឹកនាំ គឺ តា។ ដូចនេះ **ព្រះ** ជា ព្រលឹងជាតិ, **ថៅ** ជា អ្នក ដឹកនាំជាតិ ចេះបង្រួបបង្រួមប្រជារាស្ត្រ នៅក្នុងគំនិត បំរើ និង ការពារ, **តា** ជា ប្រភព នៃ ច្បាប់ដឹកនាំ និង ការ ពិសោធ របស់បុព្វបុរសជាតិ នោះឯង។ ការគោរព មេបា នេះ ជា មូលដ្ឋាន វប្បធម៌ដើម របស់ជនជាតិខ្មែរ ដែល អាច តទល់បាននឹង ឥទ្ធិពល អរិយធម៌ឥណ្ឌា ដែលហូរ ចូលមក ក្នុងស្រុកខ្មែរ។ នៅចំពោះមុខ ការតទល់នេះ តម្រូវឲ ពួកព្រាហ្មណ៍ព្រឹទ្ធបណ្ឌិត នៅស្រុកខ្មែរ ធ្វើ សិថិល ភាព (concession) ជាច្រើន ដើម្បី កុំឲមាន ការប៉ះទង្គិច ទាំងកម្រោល រវាង ទ្រឹស្ដីសាសនា របស់ពួកខ្លួន នឹង ជំនឿ អាយ ដែលជាជំនឿ មាន គ្រឹះច្បាស់លាស់ រួចមកហើយ។ លោក កេង វ៉ាន់សាក់ ពុំទុក ការគោរព មេបា នេះ ជា វិសិដ្ឋភាពខ្មែរ លើ ព្រហ្មញ្ញណ៍សាសនា នោះទេ តែជា ចិត្ត

[27] អ្នកដឹកនាំជាទីស្នេហា ; un dirigeant charismatique។

នាការខ្មែរ អំពី សង្គម ដែល ពួកព្រាហ្មណ៍ព្រឹទ្ធបណ្ឌិត ត្រូវយកមកសម្របសម្រួល ជាមួយនឹង សាសនាខ្លួន ដើម្បីឲ្យប្រជាជនអោយ អាច រើសយក សាសនាថ្មីនេះ ជាជំនឿថ្មីបាន។

## ការគោរពចំពោះ នាង កាហ៊ុញ និង ក្រពើ

មាននៅក្នុងរឿងព្រេងខ្មែរ ថា ស្រុកខ្មែរដើមដំបូង ជាជលសា។ ក្រោយមក លេចចេញ ទេវតាស្រីម្នាក់ ឈ្មោះ កាហ៊ុញ ឈរលើក្រពើ យកដៃ ច្បូតសក់វែងរបស់ខ្លួន បង្កើតបានជា ពុសធា។ លើពសុធា នោះឯង ដែលអាចអោយមនុស្សខ្មែរ មករស់នៅបាន។ ខ្មែរហៅ ទេវតាស្រីនោះ នាងកាហីញ ជា និមិត្តរូប នៃ ពសុធា, រីឯ ក្រពើ ជា និមិត្តរូប ជលសា។ គូ ទេវតាស្រី និង ក្រពើ នោះ ជា តូតិម នៃ ជនជាតិខ្មែរ និង ទឹកដីខ្មែរ។ រូបតំណាង នៃ តូតិម នាងកាហ៊ុញ-ក្រពើ គឺ មាណវី[28] និង សត្វក្រពើ។ នៅស្រុកខ្មែរសព្វថ្ងៃ នៅគ្រប់បូជនីយដ្ឋាន ទាំង ព្រាហ្មណ៍សាសនា ពុទ្ធសាសនា និង ជំនឿ ផ្សេងៗទៀត គេ តំណាង ក្រពើជា ទង់ ហៅថា ‹ទង់ក្រពើ› ឬ ‹ទង់រលក› ដែលក្រើនរំឭក នូវ ធម្មជាតិ ជាបាយាប[29] នៃ ក្រពើ។ គេឃើញ នៅមុខផ្ទះណា មានមនុស្សស្លាប់ ដោត ទង់ក្រពើ មានពណ៌ស នាំអោយ គេហៅ ទង់នោះ ថា ‹ទង់ព្រលឹង›។ តែ ពួកអ្នកប្រឆាំងនឹង

---

[28] មាណវី, ស្រីនៅវ័យក្មេង, jeune fille។
[29] បាយាប, អ្នកតាទឹក, génie des eaux។

ជំនឿនោះ នាំគ្នាហៅទង់នោះ ថា ‹ទង់ខ្មោច›។ គួរកត់សំគាល់ថា ក្រពើ ក៏ជា តំណាង នៃ ជនក្បត់ ឬ ជនរមិលគុណ។ ទស្សនៈនេះ មានអ្នកខ្លះថា ចេញពី ប្រភព ពុទ្ធសាសនា ព្រោះទុក ជំនឿដើមខ្មែរ ជាសត្រូវនឹងខ្លួន ដូចមាន នៅក្នុងរឿង ក្រពើនេនធុន : នេនធុន ព្រោះ តែក្បត់នឹង ពុទ្ធសាសនា បានជា ពុំអាចប្រែខ្លួនមក ជាមនុស្សវិញបាន។

មួយវិញទៀត ពុទ្ធសាសនិក តែងតែប្រដូច នាងកាហ៊ុញទៅនឹង នាង មារា ដែលមាន ចារក្នុងពុទ្ធរឿងព្រេង មានចំណងជើងថា ‹បាបចិត្ត នៃ នាងមារា› : ដើម្បី ធ្វើអោយអាក់ខាន ព្រះសក្យមុនី បានត្រាស់ដឹង។ នាងមារា មកពីឋាន យក្ស ជាមួយនឹងកងទ័ព របស់នាង មកទាមទារអាសនៈ ដែល ព្រះអង្គកំពុងគង់លើ។ ដើម្បីទប់ទល់នឹងបាបចិត្តនោះ ព្រះដ៏មានព្រះភាគ ព្រះអង្គ យកដៃស្តាំពាល់ដី ហើយ បួងសួង ដល់ ព្រលឹង ព្រះពសុធា អោយជួយព្រះអង្គ ឯកា នៅចំពោះមុខ ទ័ពយក្ស នាំអោយរញ្ជួយដីប្រាំមួយយ៉ាង អាចកំចាត់ នាងមារាបាន។ តាម របៀបនិទាន រឿងខ្មែរ គឺ នាងកាហ៊ុញ ជា អ្នកជួយ ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ដោយច្បូតសក់នាង បង្កើតជា ជលសា នាំអោយលិចលង់ ទ័ពនាងមារា។ កុសលកម្ម នោះឯង ដែល ខ្មែរ នៅតែគោរព នាងកាហ៊ុញ មកដល់សព្វថ្ងៃតែ ពុំទុកជា ទេវតាស្រី ធំចម្បង ទៀតនោះឡើយ។

## ជំនឿចំពោះ អ្នកតា

អ្នកតា ជា ព្រលឹង ស្ថិតនៅ ក្នុង រុក្ខជាតិ, ក្នុងភ្នំ និង ទីកន្លែងដទៃទៀត។ ខ្មែរ យក ដុំថ្ម ជាតំណាង រូបអ្នកតា យកទៅដាក់ ក្រោមគល់ដើមឈើ។ ជូន សង់កូនខ្ទម ទ្រ ដោយសសរ សំរាប់ដំកល់។ នេះជា ជំនឿវិញ្ញាណនិយម : ក្នុង រឿង ព្រះបាទ ហ៊ុន ទៀន និង ព្រះនាង លិវ យី កាល ជន ហ៊ុន ទៀន ឬ កៅណ្ឌិន្យ នៅតណ្ឌា យល់សប្តិ ឃើញ អ្នកតា ឬ ទេវតា រក្សាខ្លួន ប្រគល់ ធ្នូទិព្វអោយ ហើយបញ្ជាអោយ ឡើងជិះសំពៅជំនួញដ៏ធំមួយ ដើម្បីធ្វើដំណើរ មកស្រុក ខ្មែរ ច្បាំងយករាជសម្បត្តិ (នៅពាក់កណ្តាល ស.វ. ទី៣ ក. គ.ស.)។ ដូច្នេះ ខ្មែរតែងតែទុក ព្រះបាទ ហ៊ុន ទៀន ជា ស្ថាបនិកក្សត្រ នគរ ហ្វូណន។

ព្រលឹង អ្នកតា ជា អ្នកការពារ អ្នកភូមិទាំងឡាយ ហើយ ជួយដល់ ជនណា ដែល បន់ស្រន់ ដល់លោក សូមអោយ ជួយខ្លួន។ អ្នកតា ក៏ជា អ្នកថែរក្សា ប្រចាំទីកន្លែងមួយ។ ទំនាក់ទំនង រវាង មនុស្ស នឹង ព្រលឹងអ្នកតា គឺងាយ ស្រួលបំផុត គឺគ្រាន់តែ ធ្វើការបន់ស្រន់ ថ្វាយដង្វាយ ដូច ជា បាយ, មាន់អាំង, ទឹកដូង ឬ ចេក ដើម្បី សូមពរ ពី អ្នកតា អោយខ្លួន បានសំរេច នូវ បំណន់ខ្លួន។ តែកាល ណាបានសំរេចដូចប្រាថ្នា ត្រូវតែអ្នកបន់នោះ ធ្វើពិធីលា បំណន់ជាដាច់ខាត ពុំនោះសោត គឺច្បាស់ជា ព្រលឹង

អ្នកតា ធ្វើទោស។ អ្នកណាមួយ សើច នូវសំដី ឡកឡឺយ នៃជនម្នាក់ទៀត ដល់អ្នកតា គឺ អ្នកសើច ជា អ្នកទទួលទោស ពុំមែន អ្នកនិយាយចំអកឡកឡឺយនោះទេ ដូចយ៉ាង ធ្វើអោយឈឺពោះ ក្រៃលែង។ លុះត្រាតែរៀបចំ ធ្វើពិធីលាងទោស ទើបអាចបាត់ឈឺពោះ។

ជំនឿ លើអ្នកតារបស់ប្រជាពលរដ្ឋខ្មែរ មានលក្ខណៈ ពីរយ៉ាង៖

១. ជាការសំម្តែងគំនិត នៃថាមពលធរណី ដែល ដីឃុំ ស្រុក ខេត្ត មានពហុផលភាព មានវិបុលភាព ដោយសារអ្នកតាប្រចាំឃុំ ស្រុក ខេត្តនិមួយៗ នោះឯង។ ហេតុនេះឯង រៀងរាល់ឆ្នាំអ្នកស្រុក នាំគ្នាធ្វើពិធីសែន ដែលគេហៅថា បុណ្យលើកអ្នកតា ដើម្បី សូមសេចក្តីសុខ និង សេចក្តីចំរើនពីព្រះធរណីនេះ។

២. ជាការសំដែងគំនិត នៃការទុកអ្នកតា ជាទីកន្លែងតែម្តង ដោយយក ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និង អនុស្សាវរីយ៍របស់ អ្នកស្រុកនៅទីកន្លែងនោះ មកបញ្ជាក់ថាជំនឿនេះគឺជាការពិត ដូចយ៉ាង អ្នកស្រុកនៅខេត្តពោធិសាត់ ទុកអ្នកតាឃ្លាំងមឿងជាខេត្តពោធិសាត់តែម្តង។ ដើមដំបូងនៃជំនឿនេះ គឺ ក្នុងសតវត្សទី១៦ មាន មេទ័ពខ្មែរម្នាក់ឈ្មោះ ឧកញ្ញាឃ្លាំងមឿង លោកសុខចិត្ត បូជាជីវិតលោកខ្លួនឯង ដើម្បី ការពារ ពញាចន្ទ ដែលជាប់ ក្នុងបន្ទាយ

ជ័យ ពីការឡោមព័ទ្ធ របស់កងទ័ពស្តេចកន។ ការបូជាជីវិតដោយខ្លួនឯង របស់ឧកញ៉ាឃ្លាំងមឿង ចៅហ្វាយខេត្តពោធិសាត់ មានគោលបំណង ទៅកែនទ័ពខ្មោច ឲ មកជួយវាយរំដោះ ពញាអង្គចន្ទ ពីការឡោមព័ទ្ធរបស់សត្រូវ ចំណេរកាលតៗមក អ្នកស្រុកនៅខេត្តពោធិសាត់ក៏នាំគ្នាជឿថា ព្រលឹងខ្មោច ឧកញ៉ាឃ្លាំងមឿង ក្លាយទៅជា អ្នកតា រក្សាទឹកដី ខេត្តពោធិសាត់ ហើយមកដល់បច្ចុប្បន្នកាល រាល់ខែមេសា គ្រប់មន្ត្រីប្រចាំ ខេត្តពោធិសាត់ និង អ្នកស្រុកនាំ គេគ្នា ធ្វើពិធីបន់ស្រន់ដល់អ្នកតាឃ្លាំងមឿង ដើម្បីសូមសេចក្តីសុខសប្បាយពីម្ចាស់ទឹកដី។

ជំនឿបែបនេះ គេឃើញមានដែរ នៅស្រុកត្បូងឃ្មុំ នៅក្នុងខេត្តកំពង់ចាម គ្រប់ចៅហ្វាយស្រុកថ្មី ត្រូវតែធ្វើពិធីបន់ស្រន់ដល់អ្នកតា អជូន នៅភូមិអជូន ដែលជាម្ចាស់ទឹកដីទីនោះ ដើម្បីសូមសេចក្តីសុខ។ ត្រូវដឹងថា អជូនជាអតីតចៅហ្វាយខេត្តត្បូងឃ្មុំ ក្នុងសតវត្សទី១៦ ដែល ព្រះរាជាកាត់ទោសប្រហារជីវិត ពីបទធ្វើឃាតកម្ម ដោយចេតនាបំពាន អាជ្ញាស្តេច លើបុគ្គលទុំ។ ចំណេរកាលតៗមក អ្នកស្រុកត្បូងឃ្មុំ មានជំនឿថា ព្រលឹង អជូន ក្លាយជា អ្នកតារក្សាទឹកដី ហើយនាំគ្នា ធ្វើការបន់ស្រន់ ដើម្បី សូមសេចក្តីសុខ។ រឿងអជូននេះ ខ្មែរយើងភាគច្រើន ដឹងច្បាស់ដោយសារ មាន អ្នកនិពន្ធខ្មែរម្នាក់ បានដកស្រង់

ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រនេះ មកតែងជា ប្រឡោមលោក ដ៏ល្បី ដែលមានចំណងជើងថា«រឿងទុំទាវ» ឬ ទាវឯក។

## ព្រាហ្មណ៍សាសនា

ព្រាហ្មណ៍សាសនា ទំនងហូរចូលស្រុកខ្មែរ តាមរយៈ ពួក ឈ្មួញឥណ្ឌា ដែលធ្វើដំណើរតាមសំពៅ ទាក់ទងលក់ដូរ ជាមួយអ្នកស្រុក។ មានឈ្មួញខ្លះ ជា អ្នកចេះដឹងខាង ព្រាហ្មណ៍សាសនា ជួនបានរៀបការជាមួយស្ត្រីខ្មែរ ក៏នាំអោយ មានឥទ្ធិពល ទៅលើជនជាតិខ្មែរ។ ម្យ៉ាងទៀត គេដឹង តាម ប្រវត្តិសាស្ត្រថា កាលណោះ ស្រុកខ្មែរ គ្រប់គ្រងដោយ ព្រះនាង លីវ យី ហើយមាន ស្តេចឥណ្ឌា ព្រះនាម ហ៊ុន ទៀន បានលើកទ័ព មកច្បាំងដណ្តើមយកទឹកដីខ្មែរ។ ក្រោយដែលបានជ័យជំនះ ព្រះអង្គ ក៏បានរៀបអភិសេក ជាមួយ ព្រះនាង លីវ យី ហើយបាន ប្រកាសតាំងខ្លួន ជា ស្តេចគ្រងរាជ្យ ព្រមទាំងបាន រៀបចំស្រុកខ្មែរ តាមទស្សនៈបែបព្រាហ្មណ៍ ថែមទៀត។ ម្លោះហើយ ឥទ្ធិពល លទ្ធិព្រាហ្មណ៍ ក៏រីកដុះដាលឡើង ដាលំដាប់នៅស្រុកខ្មែរ ក្លាយជា សាសនាជាតិតែម្តង ជា ពិសេស នៅក្នុង មជ្ឈដ្ឋាន ពួក អ្នកដឹកនាំ រហូតដល់ សតវត្សរ៍ ទី១៤។ នៅស្រុកខ្មែរ គេ និយមគោរព ព្រះឥសូរជាធំ ឯព្រះវិស្ណុ ព្រះហរិហរៈ (ឥសូរ និងនារាយណ៍រួមគ្នា) ព្រះព្រហ្ម ក៏មានគេគោរពខ្លះៗដែរ។

## ពុទ្ធសាសនា

ពុទ្ធសាសនា ចែកជា ពីរនិកាយ : មហាយាន និង ហិនយាន។ និកាយ ហិនយាន ចែកចេញទៅទិសខាងត្បូង នៃប្រទេសឥណ្ឌា (ទក្ខិណនិកាយ) ជាយានតូចចង្អៀត ផ្ទុកសត្វលោក ទៅកាន់និព្វានបានចំនួនតិច ពោលគឺ ក្របានសំរេចនិព្វាន ព្រោះ វិន័យតឹងតែងម៉ត់ចត់។ និកាយហិនយាន និយមចាស់ គឺគោរពប្រតិបត្តិ តាមពុទ្ធោវាទ ដែលព្រះពុទ្ធ ទ្រង់បានសំដែងរួចមកហើយ (ក្នុងគម្ពីរត្រៃបិដក) និកាយនេះ គោរពព្រះពុទ្ធសមណគោតម ដែលត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ហើយដែល បានចូលបរិនិព្វានទៅហើយ។ សព្វថ្ងៃប្រទេសដែលនិយម ពុទ្ធសាសនានិកាយហីនយាន មានប្រទេស ខ្មែរ-សៀម-លាវ-ភូមា-នេប៉ាល់-សិរីលក្កា ។ល។

ឯនិកាយមហាយាន ចែកចេញទៅ ទិសខាងជើង (ឧត្តរនិកាយ) ជាយានធំ អាចផ្ទុកសត្វលោកបានច្រើនគ្នាទៅកាន់គោលដៅត្រឹមពោធិសត្វ ដែលអាចជួយណែនាំប្រោសសត្វលោកបាន។ និកាយមហាយាននិយមធម៌ថ្មី គឺធម៌ដែលមានន័យធូរស្រាល ហើយគោរពប្រតិបត្តិតាមលទ្ធិអាចរិយវាទ (តាមគ្រូអាចារ្យរបស់ខ្លួនតៗគ្នា) ពុំមែនតាមពុទ្ធោវាទ ដូចនិកាយហីនយានឡើយ។ ដូចនេះ និកាយមហាយាន ពុំគោរពព្រះពុទ្ធជាធំទេ តែគោរព

ពោធិសត្វ ដូចជា ពោធិសត្វ អវលោកិតេស្វរៈ ឬ លោកកេស្វរៈ មញ្ជុស្រី អែតរេយ ប្រាជ្ញាបារមិតា ជាដើម។ សព្វថ្ងៃ ប្រទេស ដែលនិយមពុទ្ធសាសនាមហាយាន មានប្រទេស យួន-ជប៉ុន-ទីបេ-ឥណ្ឌូណេស៊ី ។ល។

នៅសតវត្សទី៣ មុន គ.ស. ក្នុងរជ្ជកាល ព្រះបាទ អសោក ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយពាសពេញ ទាំងប្រទេស ឥណ្ឌា ទាំងក្រៅប្រទេស។ តាមប្រវត្តិសាស្ត្រ គេដឹងថា នៅ ពុទ្ធសតវត្សទី៣ (ព.ស. ២៣៤) គឺតាំងពីមុន គ.ស. ៣០០ ឆ្នាំម្លេះ ព្រះបាទ អសោក ពុទ្ធសាសនិក ដ៏ឆ្នើមក្នុង ប្រទេសឥណ្ឌា បានបញ្ជូន សមណទូត ពីរអង្គ គឺ ព្រះ សោណត្ថេរ និង ព្រះ ឧត្តរត្ថេរ អោយនាំយកពុទ្ធសាសនាថេរវាទ (ហីនយាន) មកផ្សាយនៅសុវណ្ណភូមិ (អាស៊ីអាគ្នេយ៍)។ តាមសិលាចារឹករ៉ូកាញ់ (នៅស្រុកយួនខាងត្បូង) ទំនងជា ពុទ្ធសាសនា ចូលមកប្រតិស្ឋានក្នុងប្រទេសខ្មែរ នៅសតវត្សទី២ នៃ គ.ស. ក្នុងរជ្ជកាល ព្រះបាទ ស្រីមារៈ ឬ ហ្វាន់ ចេម៉ន។

## វិវត្តិន៍ នៃ ព្រាហ្មណ៍សាសនា និង ពុទ្ធសាសនា

ក. សម័យនគរភ្នំ (ស.វ. ទី១ ដល់ ទី៦)

នៅសម័យនោះ ខ្មែរខ្លះ គោរព ព្រាហ្មណ៍សាសនា ខ្លះទៀត គោរព ពុទ្ធសាសនា។ ពុទ្ធសាសនិក ពេញចិត្តនឹង ពុទ្ធ

សាសនាថេរវាទ (និកាយហីនយាន)។ នៅ សតវត្សទី២ ពុទ្ធសាសនា ចំរើនលូតលាស់ជាងព្រាហ្មណ៏សាសនា។

ខ. សម័យចិនឡា (ស.វ.ទី៦ ដល់ទី៨)

មកដល់សម័យចេនឡា ព្រាហ្មណ៏សាសនា លូតលាស់ជាងពុទ្ធសាសនា រហូតដល់ ស.វ. ទី១២។ ប៉ុន្តែ ពុទ្ធសាសនាហីនយាន មិនសាបសូន្យភ្លាមទេ ជាភស្តុតាង គេប្រទះឃើញ ព្រះពុទ្ធរូប នៅ ព្រៃកប្បាស ដែលបានសាងឡើងនៅ ស.វ.ទី៧ និង សិលាចារឹកជាច្រើនទៀត។ នៅចុងសតវត្សទី៧ និកាយ មហាយាន ក៏ផ្សាយចូលមកដល់ស្រុកខ្មែរហើយលូតលាស់រហូតដល់ ស.វ.ទី១៣ ប៉ុន្តែមិនសូវឃើញមានរូបបដិមាពោធិសត្វ លោកេស្វរៈ ទេ គេប្រទះឃើញមានមួយ នៅក្រមួនស (កម្ពុជាក្រោម) និង មួយទៀត នៅប្រាសាទ តាក្រៀម (សៀមរាប)។ ដល់ ស.វ.ទី៨ ព្រាហ្មណ៏សាសនា នៅតែលូតលាស់ទៀត។

គ. សម័យមហានគរ (ស.វ.ទី៨ ដល់ទី១៥)

នៅ ស.វ.ទី៩ ព្រាហ្មណ៏សាសនា កាន់តែលូតលាស់ ព្រោះព្រះបាទ ជ័យវរ្ម័ន ទី២ ទ្រង់សព្វព្រះទ័យ កាន់ព្រាហ្មណ៏សាសនា និយម ឥសូរ ជាធំ។ ព្រះអង្គ ទ្រង់ បានចាត់ចែងអោយអញ្ជើញ ព្រាហ្មណ៏ដ៏ប្រសើរម្នាក់ ឈ្មោះ ហិរណ្យនាម ជាអ្នកប្រាជ្ញ ចេះចប់ ត្រៃវេទ មកជួយរៀបចំធ្វើពិធី ទេវរាជ

(culte du roi-dieu) ដើម្បីប្រកាសឯករាជ្យ ដល់ប្រទេសកម្ពុជា ហើយធ្វើ ព្រះរាជាអោយទៅជា ព្រះរាជចក្រវាលនៅលើភ្នំគូលែន។ ព្រះអង្គ អោយគេសាង លិង្គ ព្រះឥសូរតំកល់ក្នុងប្រាសាទភ្នំទុកជាទីគោរព។ នៅសតវត្សទី៩ (គ.ស. ៨៨៩) ព្រះបាទ យសោវរ្ម័នទី១ ទ្រង់បានឡើងសោយរាជ្យបន្តទៀត ហើយ ទ្រង់ប្រកាន់ព្រហ្មណ៍សាសនា និយមព្រះឥសូរ ជាធំ ប៉ុន្តែ ព្រះអង្គ ទ្រង់ប្រោសប្រាណពុទ្ធសាសនាដែរ ជាភស្តុតាង ព្រះអង្គ បានសាងអាស្រមជាច្រើនកន្លែង សំរាប់ អោយអ្នកកាន់សាសនាទាំងបីប្រភេទ (ពុទ្ធសាសនាហីនយាន ពុទ្ធសាសនាមហាយាន និង ព្រាហ្មណ៍សាសនា) ទៅរៀនអំពីសាសនា នារហូតដល់ទៅទស្សនវិជ្ជានៅទីនោះ។

លុះដល់ ស.វ.ទី១២ ក្នុងរាជ្យ ព្រះបាទ សុរិយាវរ្ម័នទី២ (គ.ស. ១១១៣) មានការប្រែប្រួលខ្លះក្នុងព្រហ្មណ៍សាសនា គឺព្រះព្រះរាជាអង្គនេះ ជាព្រាហ្មណ៍សាសនិក គោរពព្រះវិស្ណុជាធំ។ នៅចុង ស.វ.ទី១២ គេបានសង្កេតឃើញ មានការមករកកាន់ពុទ្ធសាសនា។ មកដល់ ស.វ.ទី១៣ ពុទ្ធសាសនា ចំរើនលូតលាស់ម្តងវិញ។ ព្រះបាទ ជ័យវរ្ម័នទី៧ ជាពុទ្ធសាសនិកដ៏ឆ្នើម ទ្រង់កាន់ ពុទ្ធសាសនាមហាយាន គោរពព្រះពោធិសត្វ លោកកេស្វរៈ និង ប្រាជ្ញាបារមិតា តាមព្រះប្រពៃណី ព្រះវរបិតា។ ព្រះអង្គទ្រង់ផ្លាស់ប្រពៃណី ដែលធ្លាប់គោរពទេវរាជ តាំងពី ព្រះបាទ ជ័យវរ្ម័នទី២ មក ហើយ

គោរព ពុទ្ធរាជ (culte du roi-Bouddha) វិញ។ ទោះបី ព្រះអង្គ ជា ពុទ្ធសាសនិក មុតមាំក៏ដោយ ក៏ព្រះអង្គ នៅតែប្រោសប្រាណ ព្រាហ្មណ៍សាសនាដែរ។ ព្រះអង្គ បានសាងប្រាសាទជាច្រើន ដើម្បី ឧទ្ទិសថ្វាយ ព្រះពុទ្ធសាសនា មានប្រាសាទ បាយ័ន ជាដើម ហើយ គេបានសាង ពុទ្ធបដិមាជាតួអង្គ ពុទ្ធរាជ តាំកល់ក្នុងប្រាសាទ បាយ័ន។ ដើម្បីតំណាង ព្រះអង្គ កាលទ្រង់ចូលទិវង្គតទៅ។ តែក្រោយរជ្ជកាល ព្រះបាទ ជ័យវរ្ម័នទី៧ ព្រះរាជា ដែលសោយរាជ្យ ជាតំណរាជវង្ស ត្រឡប់មកកាន់សាសនាព្រាហ្មណ៍ គណៈឥសូរវិញ។ គេឃើញមានប្រតិកម្ម នៃ ព្រាហ្មណ៍សាសនា ដោយមានការបំផ្លាញព្រះពុទ្ធរូប (វាយបំបែក ខ្លះរើដាប់យកពុទ្ធរូបចេញ)។ លុះមកដល់ចុង ស.វ. ទី១៣ ពុទ្ធសាសនាមហាយាន ក៏សាបរលាបទៅ ហើយមកដល់ ស.វ. ទី១៤ ព្រាហ្មណ៍សាសនា ក៏បាត់បង់ទៅទៀត នៅសល់តែ ពិធីខ្លះក្នុងរាជវាំង។ ចំណែកឯ ពុទ្ធសាសនា ភាសាបាលី (ដែលនាំចូលមកនៅ ស.វ. ទី១២) ក៏បានលូតលាស់ដុះដាលចំរើន យ៉ាងក្រៃលែង រហូតមកដល់សម័យបច្ចុប្បន្ននេះ។

អាស្រ័យដោយខ្មែរ បានទទួល កាន់សាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ ច្រើនសតវត្សមកហើយ ហើយទោះបី ព្រាហ្មណ៍សាសនា និង ពុទ្ធសាសនាមហាយាន សាបរលាបទៅវិញក៏ដោយ ក៏ឥទ្ធិពល នៃ សាសនាទាំងនោះ បានចាក់ឫស យ៉ាងមាំក្នុងសន្ដានចិត្តខ្មែរ ក្នុងសង្គមខ្មែរ។ ពុទ្ធ

សាសនា ថេរវាទ (និកាយហិនយាន) ប្រជួស និកាយមហាយាន ចាប់ពីសតវត្ស ទី១៤មក ហើយ និកាយថ្មីនេះ មិនគ្រាន់តែជា សាសនា ចំពោះ ពុទ្ធសាសនិក ប៉ុណ្ណោះទេ គឺបន្តក្រោយមក ក្លាយ ទៅជា របបជីវិត សំរាប់ការរស់នៅតែម្តង។ ក្រោយមកទៀត ពុទ្ធសាសនាថេរវាទ នៅស្រុកខ្មែរ បែកជាពីរគណៈ: ធម្មយុត្តិកនិកាយ និង មហានិកាយ រហូតមកដល់សព្វថ្ងៃ។

## ភាសាខ្មែរ

ជនជាតិខ្មែរ មានភាសា សំរាប់ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក នៅក្នុងសង្គមជាតិខ្លួន តាំងពីកំណើតជាតិសាសន៍ខ្មែរមកម្លេះ (៣០០០ ឆ្នាំ មុន គ.ស.)។ នៅក្នុងសាកលលោកសព្វថ្ងៃ មាន អំបូរភាសាធំៗ ចំនួន២០។ ភាសាវិទូ បានបញ្ចូលភាសាខ្មែរ ទៅក្នុងអំបូរ ខ្មែរ-មនដែលជាអំបូរភាសាធំមួយជាងគេក្នុងបណ្តា ភាសាអាស៊ីភាគខាងត្បូង ដូចយ៉ាង អបូរភាសា អូស្រ្តៀអាស៊ី, ម៉ាឡាយូ-ប៉ូលីនេស៊ី និង អបូរភាសា ថៃ-វៀតណាម។ ភាសាខ្មែរមានវិវត្តន៍ បីកាលធំៗ : ភាសាខ្មែរបូរាណ (តាំងពីកំណើតមកដល់សតវត្សទី១៥ - ភាសាខ្មែរកណ្តាល (ស.វ. ទី១៦ ដល់ ស.វ. ទី ១៩) - ភាសាខ្មែរបច្ចុប្បន្ន។ លក្ខណៈពិសេសនៃភាសាខ្មែរ ទៅនឹងភាសាខ្លះទៀត ជាពិសេសភាសាបាលី-សំស្រ្កឹត គឺនៅត្រង់ភាសាខ្មែរ ពុំមានសម្លេងឡើងចុះ ឬ

លើកដាក់ខ្ពស់ទាប ទៅតាមសញ្ញាដាក់ពីលើពាក្យ ដែលនាំអោយផ្លាស់ប្តូរន័យ របស់ពាក្យនោះទេ។ នេះជាចំណុចសំខាន់មួយ ដែលបង្ហាញនូវសភាពប្លែកគ្នារវាងភាសាខ្មែរ-មន និងក្រុមភាសា ចិន-យួន-សៀម-លាវ ដែលជាភាសាភ្ជាប់ងាយទៅនឹង សម្លេងខ្ពស់ទាប ឬ ចុះឡើង (langues toniques)។ ចំណុចពិសេសនេះ ក៏អាចបញ្ជាក់ថា ភាសាខ្មែរ មានលក្ខណៈពិសេសខ្លួន ពោលគឺ ពុំមែនកើតចេញអំពី ភាសាណាមួយឡើយ។ ទំនាក់ទំនង រវាងខ្មែរនិងបរទេសធ្វើអោយមានល្បាយភាសាបរទេសក្នុង ភាសាខ្មែរពិតមែនហើយ ក៏ប៉ុន្តែ ការទទួលឥទ្ធិពល ភាសាបរទេសនេះ តែងប្រព្រឹត្តទៅដោយ ការប្រែសំរួលអោយស្របស្រួល ទៅនឹង ភាសាជាតិ ជាដរាប តួយ៉ាងដូចជា ខេមរនីយកម្ម ចំពោះភាសាបាលី-សំស្រ្កឹត។

## អក្សរខ្មែរ

អក្សរខ្មែរ ដែលខ្មែរយកគំរូតាមអក្សរឥណ្ឌាខាងត្បូងមកប្រើប្រាស់ ក្នុងសម័យបូរាណ ពុំដូចគ្នានឹង អក្សរសម័យបច្ចុប្បន្ននេះទេ គឺត្រូវបានកែប្រែទ្រង់ទ្រាយចំនួន១០ដងរួចមកហើយ ទើបបានជារូបរាងពិតប្រាកដ ដូចតួអក្សរដែលខ្មែរប្រើប្រាស់សព្វថ្ងៃ។ អក្សរខ្មែរ ក៏ពុំមែនជា សញ្ញាដាច់ចេញពីគ្នា ដែលគេ ចេះតែយកមក កត់សំគាល់សម្លេង នោះឡើយ។ តែជាអក្សរ មានកម្រង សញ្ញាដែល

ទាក់ទងគ្នាជាក្បួន ទៅលើ មូលវិធីពិតប្រាកដ។ ខ្មែរបាន យកលំនំតាម អក្សរតណ្ឌា មកប្រើប្រាស់ ជាលើកដំបូង ក៏ពិតមែន ក៏ប៉ុន្តែបន្ទាប់មក ខ្មែរមាន ទេពកោលសល្ប ខាងឆ្នៃ អោយបានសមសួន ខាងបង្កើតថ្មី អោយសម្បូរ គ្រាប់គ្រាន់ ព្រមទាំងអោយ មានក្បួនខ្នាត មានវិធីច្បាស់លាស់ សំរាប់ជាតិខ្មែរ យកទៅ ប្រើការបាន យ៉ាងងាយ ក្នុងការ កត់ត្រាគំនិត សញ្ចេតនា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ល។ ខ្មែរបង្កើតវចនានុក្រម នៅឆ្នាំ ១៩១៥[30] ដើម្បី សម្រួល នូវការសរសេរ ជាផ្លូវការ អោយឈ្មោះថា វចនានុក្រមខ្មែររបស់រាជការ ប៉ុន្តែកាលដែលបោះពុម្ពគ្រាទី១ ជាដំបូងបង្អស់ អស់លោកកុង្សីយ៍សេនាបតី ក្នុងសម័យនោះ សុំថាអោយដាក់ឈ្មោះត្រឹមតែ វចនានុក្រមភាគទី១ ភាគទី២ កុំដាក់ពាក្យថា របស់រាជការ ព្រោះបើដាក់ឈ្មោះថា របស់រាជការ ក៏ទៅជាបង្ខំអោយគេប្រើតាមទាំងអស់គ្នា ដោយដាច់ខាត, ដោយហេតុនេះ ត្រូវទុកឱកាសអោយគេទៅសិន បើអ្នកណាគេមិនត្រូវការប្រើតាម

30 ជាស្នាដៃរបស់គណកម្មការមួយក្រុមធំ អោយរៀបចំ។ គណកម្មការនោះបានប្រឹក្សាយ៉ាងយូរ ក៏មូលមតិគ្នាជាឯកច្ឆន្ទ ក្នុងការសេសេរអក្សរខ្មែរ ជាផ្លូវការ។ ក្រោយមក មានការស្នើ សុំការឧបត្ថម្ភ សំរាប់បោះពុម្ពគ្រាទី៥ ពីគណកម្មការ នៃ ពុទ្ធសាសនាបណ្ឌិត្យ ដល់ សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជួន ណាត ជោតញ្ញាណោ អោយព្រះអង្គជួយកែសម្រួលអោយបានគ្រាន់បើជាងពីមុនដោយអន្លើងៗ ព្រោះ វចនានុក្រមនេះ ជាស្នាដៃថ្មីគំនិតចាស់របស់ព្រះអង្គ។

កំពុតមាន កំហុសអ្វីឡើយ, យូរៗទៅគង់តែនឹងប្រើតាមទាំងអស់គ្នាឯងៗទៅទេ។

## អក្សរសិល្ប៍ខ្មែរ

គេស្គាល់ អក្សរសិល្ប៍ខ្មែរ គឺចជាង សិល្បៈខ្មែរ ទោះបី មានកំណើត ក្នុងពេវេលា ជាមួយគ្នាក្តី។ គ្រប់មហាក្សត្រ ស្ថាបនិកមហានគរខ្មែរ ព្រះអង្គបានចារទុក អត្ថបទ ជាច្រើន លើផ្ទាំង ប្រាសាទ លើ ស្លឹកភ្នល់ ជាហូរហែ បន្តគ្នាមាននៅក្នុង មហារយៈពេល នៃប្រវត្តិសាស្ត្រខ្មែរដែល ជាការបញ្ជាក់ នូវអត្ថិភាព នៃអក្សរសិល្ប៍ខ្មែរ ទោះបី អក្សរសិល្ប៍ទាំងឡាយនោះ គ្មានរូបី ជា **ទិស្សមាន**[31] ដូច មហាប្រាសាទអង្គរ ដែល ទាក់ទាញ អារម្មណ៍ អ្នកសិក្សាវិជ្ជាខាងបូព៌ាប្រទេស តែចំណារ ដែល មានចារទុក ជាទូទៅនោះ អាចជា ជំនួយ សំរាប់ បំភ្លឺ នូវ ប្រវត្តិសាស្ត្រ វប្បធម៌ និងអារ្យធម៌ ខ្មែរ បានដូច រូបភាពនៃប្រាសាទ នោះដែរ។

ហេតុដូច្នេះ មន្ទិល អំពី អត្ថិភាព នៃអក្សរសិល្ប៍ខ្មែរ ទុកជា មោឃភាព។ តែ បញ្ហា នៅមានចោទ គឺថិននៅលើសំណួរសួរថាតើ អក្សសិល្ប៍ខ្មែរ ជា វិទ្យាស្សង្ស ដែរឬទេដែលមានចារទុកក្នុង ប្រវត្តិសាស្ត្រ របស់ខ្លួន។ តែប្រវត្តិសាស្ត្រ អក្សរសិល្ប៍ខ្មែរ ជា វិទ្យាសង្ស មិនដូចជា វិទ្យាសង្ស ដែលគេយកមកសិក្សា នៅមស្ទឹមប្រទេសនោះឡើយ។ ហើយចុះបើ វិទ្យាសង្ស នៃ អក្សរសិល្ប៍នេះទៀត ទើបតែចាប់ផ្តើម

[31] ទិស្សមាន= អាចមើលឃើញ ; visible។

មានក្រោយ កំណើត នៃ អត្ថបទចំណារ រឿងនិទាន រឿងព្រេង កំណាព្យអណ្តែតអណ្តូង អត្ថបទ ជា ឧបទេសរឿងល្ខោនប្រលោមលោក សសេរសាកល្បង មាន លក្ខណៈ ជា សាសនា ក្តី ជាទស្សនវិជ្ជាក្តី បញ្ចេញ ចេះដឹង នូវ មនោសញ្ចេតនា របស់ខ្មែរ តាំងពីយូរយារមកហើយ។

អក្សរសិល្ប៍ មានកំណើតស្មើនឹងប្រវត្តិសាស្ត្រខ្មែរដែរ ព្រោះគេបានដឹង តាំងពីយូរលង់ ណាស់មកហើយនូវការរស់នៅរបបគ្រប់គ្រង ព្រឹត្តិការណ៍ផ្សេងៗ នៃសង្គមជាដើម ក៏ដោយសារ អត្ថបទសេសេរ ឬ ចារទុកតាំងពីពេលនោះម្លេះ។ ជាភស្តុតាង គឺអត្ថបទចារលើផ្ទាំងសិលា ដែលមានចំណាស់ៗហើយ ដែលសរសេរសល់ គង់វង់រហូតមកដល់សព្វថ្ងៃនេះ។ ក្រៅពីសិលាចារឹក នៅមានអត្ថបទអក្សរសិល្ប៍ ជាច្រើនទៀត ដែលកត់ត្រាបន្តបន្ទាប់នៅលើសម្ភារៈផ្សេងៗដូចជា : ស្បែកសត្វ ស្លឹករឹត ក្រាំង ក្រដាស។ អក្សរសិល្ប៍ ក៏ដូចអក្សរខ្មែរដែរ តែងបានទទួល ឥទ្ធិពលបរទេស ផ្សាយចូលមកជាហូរហែ។ ឯអក្សរសិល្ប៍បរទេសមានឥទ្ធិពលខ្លាំងជាងគេ គឺ អក្សរសិល្ប៍សាសនានិយមមាន អក្សរសិល្ប៍ ព្រាហ្មណ៍សាសនា និង អក្សរសិល្ប៍ ពុទ្ធសាសនានេះឯង។

ចំពោះ អក្សរសិល្ប៍ខ្មែរ គេសង្កេតឃើញថា មាន វិវត្តន៍យ៉ាងខ្លាំង ទៅតាមសម័យកាលធំៗ នាំប្រវត្តិសាស្ត្រ របស់

ប្រទេសខ្មែរ។ នៅសម័យអង្គរ គេបានដឹងច្បាស់ថា មហិទ្ធិឫទ្ធិខ្មែរ បានឡើងដល់កំរិតជាកំពូល ឬឯ អក្សរសិល្ប៍ក៏ រីកចំរើនខ្លាំងក្លាដែរ ប៉ុន្តែចុះថយវិញ នៅពេលដែលស្រុកខ្មែរ ត្រូវចឈ្លានពានពីសំណាស់បរទេស។ លុះមកដល់ ស.វ. ទី១៨ និង ១៩ ស្នាដៃអក្សរសិល្ប៍ក៏ស្ទុះងើបឡើងបន្តិច ប៉ុន្តែត្រូវថយឥទ្ធិពលម្តងទៀត នៅពេលដែលខ្មែរធ្លាក់ខ្លួន នៅក្រោម អាណាព្យាបាលបារាំង រួចទើបលូតលាស់ចំរើនឡើងជាថ្មី នាសម័យខ្មែរបានឯករាជ្យ។ នៅសម័យ ដឹកនាំដោយរបបកុម្មុយនិស្ត (ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩១) អក្សរសិល្ប៍ ចុះថយឥទ្ធិពលជាថ្មី រហូតមកដល់សព្វថ្ងៃ ព្រោះ ស្រុកខ្មែរ ទោះបីក្លាយមកវិញ ជា របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ តែពួកអ្នកដឹញនាំសព្វថ្ងៃ ជាពួកអតិតកុម្មុយនិស្ត ដដែល។ ជាពិសេស ស្រុកខ្មែរ សព្វថ្ងៃ រស់នៅក្រោម ឥទ្ធិពល ខ្លាំងក្លា យួន-ចិន ដែលពួកនេះ គេនាំចូលមកស្រុកខ្មែរ ទាំងប្រជាជនគេច្រើនក្រៃលែងផង និង អរិយធម៌ ខ្លាំងក្លា (civilisation puissante) របស់គេផង។ អក្សរសិល្ប៍ខ្មែរ សព្វថ្ងៃ ក្លាយជា អក្សរសិល្ប៍បន្ទាប់បន្សំ សំរាប់ខ្មែរ នៅក្នុងស្រុកខ្មែរ ដែលជា ផែនដី (espace) ដែល យួន-ចិន គេដណ្តើមបាន និង នៅក្នុងឥទ្ធិពល នៃ សាកលលោកូបរិយកម្ម នោះឯង។

## សិល្បៈខ្មែរ

ភស្តុតាង ជារូបភាពពិត នៃ ប្រាសាទ ដ៏វិចិត្រទាំងឡាយ បញ្ជាក់ នូវ ទេពកោសល្យ នៃ បុព្វបុរសខ្មែរ ដែល លោក ចែកជាកេរ្តិ៍ ដល់ ខ្មែរជំនាន់ក្រោយបន្តមក រហូតមកដល់ សព្វថ្ងៃ។ ដូចនេះ តើ ខ្មែរបច្ចុប្បន្ន មាន សមត្ថភាព អាច ថែរក្សា នឹង ធ្វើវិក្រិតការ នូវ មរតករូមទាំងនោះ បាន ដែរឬទេ ?

នៅទីនេះ យើងមិនយកផ្នែក សិល្បៈខ្មែរ មកពិពណ៌នា យ៉ាងពិស្តារនោះទេ ព្រោះ វាមានទំហំធំណាស់ ពោលថា បើ ចង់អធិប្បាយ ត្រូវសរសេរជា សៀវភៅមួយតែម្តង។ មួយ វិញទៀត ក៏ពុំមែនជា គោលដៅចម្បង របស់ការសាក ល្បង របស់យើង នោះដែរ។ តែបើ អ្នកអាន មាន ប្រស្នាល ក្នុងភូមិសិល្បៈខ្មែរ អាចអាន សៀវភៅជាច្រើន សរសេរ ដោយ ប្រវត្តិវិទូបរទេស និង ខ្មែរ ដូចយើងបញ្ជាក់ជូននៅ ក្នុង ឧបសម្ព័ន្ធ របស់យើងខាងក្រោមនេះ។

## ស្ថាប័នជាតិខ្មែរ

តាមអ្នកស្រាវជ្រាវ គេមិនឃើញមានលំអាន នៃ របៀប បកស្រាយ ជា ភាសាខ្មែរ ស្តីពី ក្បួននយោបាយឥណ្ឌា តែគេ ឃើញមានចំណារជាច្រើន ជា ភាសា សំស្ក្រឹត ក្នុង ចារិក សាស្ត្រខ្មែរ កំណត់ នូវ នយោបាយវិទ្យា ដូចយ៉ាងប្រើ

ពាក្យ : arthaçâstra, râjadharma, dandanîti, nîtiçastra, etc.

ព្រះមហាក្សត្រខ្មែរ ត្រូវសិក្សាច្បាប់ dandanîti ហើយយកគោលការណ៍ទាំងឡាយ របស់វា មកអនុវត្ត ក្នុងកិច្ចការរដ្ឋបាល ព្រោះថា ច្បាប់នេះ គឺជា មធ្យោបាយ សំរាប់ ព្រះអង្គ បំពេញករណីយកិច្ច របស់ព្រះអង្គ ជា មហាក្សត្រនោះឯង។ វិញ្ញាតិ râjavidyâ កំណត់ រាជ្យវិទ្យា (science royale) ដែលព្រះមហាក្សត្រខ្មែរទុកជាវិទ្យាគត (science héridіtaire) សំរាប់ ទាយាទ នៃ រាជ្យសម្បត្តិ។ nîtiçâstra ឬ វិទ្យាសីលគន្ធ (science conduite) ទំនងជា វិទ្យា មានប្រជាប្រិយភាពណាស់ ព្រោះ ប្រជារាស្ត្រ តែងតែ សរសើរលើកតម្កើង ព្រះមហាក្សត្រ អំពី ចរិយាសម្បត្តិ របស់ព្រះអង្គគឺថាព្រះមហាក្សត្រល្អ គឺព្រះមហាក្សត្រមានសីលគន្ធ។

គឺគ្មានអ្វី ជា មន្ទិល ថា រឿងវីរភាព (épopée) Mahâbhârata និង Râmâyana ឥណ្ឌូ គ្មាន អត្ថភាព នៅស្រុកខ្មែរ នោះឡើយ ព្រោះ គេឃើញមានចំណារលើសិលាចារិកមួយ នៅសតវត្សទី៦ ស្ដីពី អំណោយ សាត្រាស្លឹករឹត Sambhava ដល់ វិហារមួយ ឈ្មោះ ប្រាសាទ ព្រះថាទ និង ព្រាហ្មណ៍ Somaçarman នៅសតវត្ស ទី៧ ថ្វាយព្រះ នូវសាត្រា គ្រប់លេខ Mahâbhârata, Râmâyana និង Purânas សំរាប់ ទុកធ្វើ បាឋកថា រៀងរាល់ថ្ងៃ។ នៅ

ប្រាសាទ អង្គរវត្ត មាន ក្បាច់រំលេច រៀបរាប់ ពីរឿង Mahâbhârata, រឿង Harivamça និង រឿង ស្រដៀងគ្នានឹងរឿង Mahâbhârata។

ប៉ុន្តែ រឿងវីរភាព ឥណ្ឌូ មិនមែនមាន ទិដ្ឋភាព ត្រឹមតែជា ប្រលោមលោកមានិត នោះឡើយ គឺ នៅក្នុងសាច់រឿងវា ជា មូលដ្ឋានសំខាន់ នៃព័ត៌មាន លើប្រភពនៃស្ថាប័ននយោបាយ អធុនាគត[32]; វា បង្ហាញ នូវ ទស្សនៈ ឥណ្ឌូ ស្ដីពី រាជាធិបតេយ្យ ផងដែរ។ ដូច្នេះ សេវនៈ (familiarité) របស់ខ្មែរ ជាមួយ មហារឿងវីរភាព ទាំងពីរនោះ វារួមបញ្ចូលផងដែរ នូវ ចំណេះចេះដឹង ពិតប្រាកដ អំពី ស្ថាប័ន និង ចិត្តនាការ (pensée) នយោបាយ ឥណ្ឌា។ បុព្វបុរសខ្មែរ ច្បាស់ជាបានអានពី បរិយាយ អំពី រដ្ឋកាលគតិបណ្ឌិត របស់ ព្រះរាជា Dusyanta ដែល ទ្រង់ ចេះរក្សាសណ្ដាប់ធ្នាប់ នៃ វណ្ណៈសង្គម និង ការដឹកនាំនគរ តាមសិក្ខាបទ នៃ ធម៌។

បុព្វបុរសខ្មែរ ស្គាល់ផងដែរ dharmaçâstra ព្រោះ មានចារលើសិលាចារឹក នូវ សេចក្ដីសរសើរ ដល់ ព្រះមហាក្សត្រ សូរ្យវរ្ម័នទី១ (១០០២-១០៥០) ដោយ ប្រៀបប្រដូច បញ្ញា និង សពាង្គ របស់ព្រះអង្គ ផ្នែក អវៈយវៈ ជា វិទ្យាសាស្ត្រផ្សេងៗ ហើយ ព្រះកេសី ជា dharmaçâstra។ នៅ សតវត្ស ទី៧ ព្រា

[32] ស្ថាបន នយោបាយ អធុនាគត ; instutions politiques contemporaines.

ហ្មណ៍ Jaimini បង្កើត សាលា pûrvamîmâmsâ ក្នុងគោល បំណងសំខាន់គឺ ដើម្បី សិក្សាវែកញែក នូវ វិធាន នៃ dharmaçâstra។ អត្ថភាព នៃ សាលានោះ សអោយឃើញ ថា ការសិក្សា នៃ dharmaçâstra មាន ជម្រៅខ្លាំង ក្នុង សម័យ បុរាណខ្មែរ។ គួរកត់សំគាល់ថា នៅក្នុង dharmaçâstra មាន ខណ្ឌ អភិប្រាយ អំពី ព្រះរាជ ករណីយកិច្ច (râjadharma) និង រដ្ឋបាលនៃតុលាការ។

## ទ្រឹស្តី នៃ វត្ថុធាតុ ៧យ៉ាង ទុកជា បតិដ្ឋាប័ន នៃ រដ្ឋ

ទ្រឹស្តី នៃ វត្ថុធាតុ ៧យ៉ាង ទុកជា បតិដ្ឋាប័ន នៃ រដ្ឋ[33] មាន នៅក្នុង ទ្រឹស្តី ឥណ្ឌូ គឺ : svâmin (ប្រមុខរដ្ឋ), amâtya (នាយទាហាន), janapada (ប្រជាជន និង ផែនដី), durga (បន្ទាយបូរី), koça (ឃ្លាំងទ្រព្យ), danda (កងទ័ព) និង mitra (សម្ពន្ធមិត្ត)។ នៅក្នុងចំណារខ្មែរ ក៏ដូច នៅក្នុង ក្បួនឥណ្ឌូ គេកំណត់ វត្ថុធាតុ ទាំង៧យ៉ាង ក្នុងលក្ខខណ្ឌ ពាក្យ (termes) anga និង prakrti : លក្ខខណ្ឌពាក្យទី១ គឺ សំដៅលើ វត្ថុធាតុ៧យ៉ាង ទុកជា បតិដ្ឋាប័ន នៃ រដ្ឋ។ លក្ខខណ្ឌពាក្យទី២ គឺ មាន អត្ថន័យ ជាគំនិតល្អិតល្អន់ និង ជានិមិត្តហេតុ (nuancé) ដែល ព្រាហ្មណ៍ Aparâka ពន្យល់ថា ‹ចេញពី prakrti នេះឯង ដែលមាន សញ្ជាត

---

33 La théorie des sept éléments constitutifs de l'Etat.
*(note de bas de page - suite)*

អនុភាព[34] ជានិយតភាព ដូចជា មាស ដែល ជាងទង យកមកឆ្លាក់ ធ្វើជា ក្រវិល ដ៏សុវិចិត្រ។

ក្នុងចំណោម វត្ថុធាតុទាំង៧ ក្បួនខ្មែរ និង ឥណ្ឌា ទុក svâmin (ប្រមុខរដ្ឋ) ជា វត្ថុធាតុចម (pradhâna prakrti) ដូចមាននៅក្នុង ចំណេរ របស់ ព្រាហ្មណ៍ Kautilya : ‹ព្រះមហាក្សត្រ មាន អភិសមាចារ[35] អាចអោយ វត្ថុធាតុដទៃទៀត ដែល គ្មានការរីកចំរើន ក្លាយបាន ជា វត្ថុធាតុបំណិន..›។

មូលដ្ឋានសំខាន់ នៃ ចិត្តនាការ នៃ នយោបាយវិទ្យា ស្តីពី ទ្រឹស្តី នៃ វត្ថុធាតុ ៧យ៉ាង ជា បតិដ្ឋាប័ន នៃ រដ្ឋ មាននៅ ក្នុង បុព្វសម័យអង្គរ ដែល បុព្វបុរសខ្មែរ ចេះឆ្នៃជាជម្រៅ អោយក្លាយជា ទ្រឹស្តីខ្មែរពិត សំរាប់ ធ្វើជា ក្បួនសំខាន់ ដឹកនាំជាតិ។ ការបំប្លែកដ៏មានសម្ថភាពនេះឯង ដែល ទុកជា ទេពកោសល្យ នៃ បុព្វបុរសខ្មែរ។

តាមការសិក្សា របស់ លោក Jean IMBERT[36] ជនជាតិ បារាំង ជា អតិតព្រឹទ្ធសាស្ត្រចារ្យ មហាវិទ្យាល័យច្បាប់ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច នៅ ភ្នំពេញ លោក ចែក វិវត្តិន៍ នៃ ស្ថាប័នខ្មែរ ជា បី កាលះ

34 សញ្ញាតអនុភាព; អនុភាពដែលកើតឯង។
35 អភិសមាចារ គឺ មានមារយាទល្អក្រៃ ឬ ការប្រព្រឹត្តរៀបរយគួរអោយពេញចិត្ត។
36 Histoire des institutions khmères par Jean IMBERT (1961).

កាលទី១ : ចាប់ពី ឆ្នាំ ៨០២ គឺជា ឆ្នាំ ឡើងគ្រងរាជសម្បត្តិ ព្រះបាទ ជ័យវរ័ន្ទ ទី២ រហូត ដល់ឆ្នាំ ១៥៩៣ ជាឆ្នាំ សៀម វាយបែកបន្ទាយលង្វែក។ អំឡុងកាលនោះ ស្ថាប័នខ្មែរ មាន ចរិកលក្ខណៈ ជា ស្ថាប័នយុគកណ្ដាល។ មានការ រុងរឿង នៅសម័យមហានគរ តែចាប់ពី ប្រមាណ ឆ្នាំ ១៣០០ នៅក្នុង វស្សបរវត្តិខ្មែរ ចាប់មានការច្របូកច្របល់ ហើយ លែងស្របគ្នានឹង ឯកសារ ចិន និង សៀម។ ព្រឹត្តិការណ៍បី អាចនឹងពន្យល់បានអំពី បំលាស់ប្ដូរ នោះ៖

- តើមកពី ការរុករាន ប្រទេសសៀម មកក្នុង ស្រុកខ្មែរ និង វិវត្តន៍ នៃពុទ្ធសាសនា ដល់ការវិនាសនៃព្រាហ្មណ៍សាសនា មកពីឥទ្ធិពលសៀម ដែលជា នគរគោរពពុទ្ធសាសនាម៉ឹងម៉ាត់ ?
- តើមកពីការប្ដូរ សន្ដតិវង្ស មហានគរ មក តាត្រសក់ផ្អែម ជា រាស្ត្រសាមញ្ញ ជា ឧទ្យានបាល របស់ព្រះរាជា ដែលនាំអោយបាត់ នូវ កិត្យានុភាព នៃស្រុកខ្មែរ ?
- តើមកពីពលក្ការសៀម[37] កាន់តែខ្លាំងឡើងៗចំពោះ ស្រុកខ្មែ ដែលនាំអោយមហាក្សត្រខ្មែរ បោះបង់ ទីក្រុងមហានគរ មកតាំងនៅ ស្រុកស្រីសន្ធ បន្ទាប់មក នៅ ភ្នំពេញ (១៤៣៤ ឬ ១៤៤៦) ?

---

37 ពលក្ការសៀម, ការគំរាមសៀម ; menace thaïlandaise.

កាលទី២ : ពីឆ្នាំ ១៥៩៣ ដល់ឆ្នាំ ១៨៦៣ ឆ្នាំ ដែល បារាំង ទទួលការពារស្រុកខ្មែរ តាមការស្នើ ពីព្រះរាជាខ្មែរ នៅក្នុង ក្របខណ្ឌ កតិកាសញ្ញា អាណាព្យាបាល ខ្មែរ-បារាំង ដែល បារាំង គេតែទុកជា ការសង្គ្រោះប្រជាជាតិខ្មែរ ពីមហិច្ឆិត តាទឹកដី នៃប្រទេសជិតខាងខ្មែរ មាន សៀម និង យួន ដែល កំពុងនាំគ្នា ចែកទឹកដីខ្មែរជាពីរ។ អំឡុងពេលនោះ ស្រុកខ្មែរ ជួបប្រទះនឹង វិបត្តិធំចម្បងគឺ អស្ថិរភាព នយោបាយ ក្នុងប្រទេស ដែលនាំអោយ ស្រុកខ្មែរ លែង មានមុខមាត់ នៅអាស៊ីអាគ្នេយ៍។

កាលទី៣ : ចាប់ពីឆ្នាំ ១៩០៧ ឆ្នាំ ដែលចាប់មាន អនុភាព វិជ្ជមាន ពី ការកំណែទំរង់ របស់បារាំង នៅស្រុកខ្មែរ (១៨៨៤ និង ១៨៩៧) អោយមាន ស្ថាប័នទំនើបខ្លះៗ ទាំងផ្នែក រដ្ឋបាល និង យុត្តិធម៌ ដែលនាំអោយមានការ រីកចំរើនសេដ្ឋកិច្ច។ ក្រោយពី ស្រុកខ្មែរ ទទួលបាន ឯក រាជ្យបរិបូណ៌ នៅឆ្នាំ ១៩៥៣, ជាប្រទេស មាន ស្ថាប័ នទំនើប រួចខ្លះហើយ, អ្នកដឹកនាំខ្មែរ បន្តកែឆ្នៃ នូវ ស្ថាប័ នជាតិនោះ អោយ កាន់តែទំនើប និង កាន់តែប្រសើរ ដែលខ្លួនត្រូវការ សំរាប់ អភិវឌ្ឍន៍ គ្រប់វិស័យជាតិ។

ស្រុកខ្មែរ ចុះអន់ថយជាខ្លាំង បន្ទាប់ពី ប្រទេសសៀមវាយបែកបន្ទាយលង្វែក (១៥៩៣)។ លោក Jean IMBERT សរសេរថា រាជសន្តតិវង្សខ្មែរ ធ្វើអោយអំណាចខ្លួន រឹងមាំបានវិញ ដោយសារមានជំនួយពី ពួកពនេចរ បរទេសមួយក្រុម មករស់នៅស្រុកខ្មែរ មានជនជាតិ Portugais ឬ Espagnols។ ពួកនេះឯង, ដឹកនាំដោយ លោក ឌីអ៊ីគោ បែល្លូសូ (Diogo Belloso) និង ប្លាវិស (Blas Ruis), បានធ្វើគត ព្រះបាទ រាមាជើងព្រៃ ក្នុង គ.ស. ១៥៩៦។ កាលដែលកងទ័ពសៀម វាយក្រុងលង្វែងបែកហើយ មានជ័យជំនះខ្មែរ សៀមតាំងទ័ព អោយនៅត្រួតត្រា ដោយយកទីក្រុងឧត្តុង្គ ជាទីបញ្ជាការកងទ័ព។ ពេលនោះ ព្រះវង្ស រាមាជើងព្រៃ ជាមេទ័ពខ្មែរម្នាក់ បានភៀសខ្លួនចេញពីទីក្រុងលង្វែង ទៅគង់ក្នុងព្រៃ ហើយ កេណ្ឌទ័ពបាន ហើយ ទ្រង់លើកមកច្បាំង កំចាត់សៀម ទាល់តែបានឈ្នះ នៅឆ្នាំ ១៥៩៤ ហើយទ្រង់ ក៏ឡើង សោយរាជសម្បត្តិ ក្នុងឆ្នាំនោះ។ ក្រោយពីបានធ្វើគត ព្រះបាទ រាមាជើងព្រៃរួច ជនបរទេសទាំងពីរនាក់នោះ ក៏នាំគ្នា លើករាជសម្បត្តិ ថ្វាយព្រះថៅ ពញាតន់ ដែលត្រូវជា ព្រះរាជបុត្រ របស់ ព្រះ សត្ថាទី១ (១៥៦៧-១៥៧៥) មកគងមហាក្សត្រនៅទីក្រុងលង្វែក។

យើងត្រឡប់មកក្រោយបន្តិច ដើម្បី អធិប្បាយជាសង្ខេបមុនសម័យ ដែលសៀមវាយបែកបន្ទាយលង្វែក។ នៅឆ្នាំ

១៥៧៥ ព្រះបាទ សត្ថាទី១ ដាក់រាជសម្បត្តិ ថ្វាយព្រះរាជបុត្រច្បង របស់ព្រះអង្គ មានព្រះជន្ម ១០ ព្រះវស្សាប៉ុណ្ណោះ អោយគ្រងរាជ្យ បន្តពីព្រះអង្គ មានព្រះនាមរាជ្យ ព្រះបាទជ័យជេដ្ឋាទី១។ ទង្វើ គ្មានហេតុផលនេះ នាំអោយ ប្រជារាស្ត្រ និង នាម៉ឺនសព្វមុខមន្ត្រី មានសេចក្តីអាក់អន់ចិត្តជាខ្លាំង។ ដូចនេះ វានាំអោយ ស្រុកខ្មែរ មានកើតអសន្តិសុខ ដែលជាហេតុនាំអោយ សៀមលើកទ័ព មកវាយក្រុងលង្វែង តែពុំបានទទួលជ័យជំនះ ក៏នាំគ្នាដកទ័ពវិលត្រឡប់ទៅស្រុកវិញ។ តែក្រោយមកសៀមលើកទ័ពមកច្បាំងនឹងខ្មែរ ម្តងទៀត ហើយវាយ បែកបន្ទាយលង្វែក នៅឆ្នាំ ១៥៩៣ ដូចបានជំរាប់ខាងលើរួចមកហើយ។ ក្រោយពីបានទទួលជ័យជំនះ សៀមចាប់ ព្រះស្រីសុរិយោពណ៌, ជាព្រះអនុជ ព្រះបាទសត្ថា នូវជា ព្រះមហាឧបរាជ,និងរាជវង្សា ព្រមដោយមនុស្សពេញការចំនួន ៩ ម៉ឺននាក់ យកទៅស្រុកសៀម ហើយ បានដុតបំផ្លាញផ្ទះ និង ទ្រព្យសម្បត្តិជាតិខ្មែរ និង អ្នកស្រុកអស់ជាច្រើន។ ចាប់ពីសម័យនោះមក ដែលស្រុកខ្មែរ ត្រូវជួបនឹងវិបត្តិជាតិធំៗ។ ហើយនៅសតវត្សទី១៦ នេះដែរ ដែលជា ដំណើរនៃ ការរាតទឹកដីក របស់ជាតិសាសន៍យួន ចុះមកខាងត្បូង នៃដំបន់ឥណ្ឌូចិនសព្វថ្ងៃ។ នៅក្នុងអំឡុង សតវត្សទី១៥ ហួង នៃ នរប្រវេសន៍យួន មាន ទណ្ឌិត ដែលត្រូវបំបរបង់, ជនអនាថា, ទាហានរមត់ និង អ្នកគ្មានទី

លំនៅ ជនទាំងនោះ ដឹកនាំដោយ អតិតយុទ្ធជន នាំគ្នាគង្គាន ចូលទឹកដី នគរចំប៉ា (ដែនដី អណ្ណាម សព្វថ្ងៃ) ហើយ កាន់កាប់ ម្រឹទិនី (terre fertile) របស់ជនជាតិចាមជាម្ចាស់ស្រុក យកដីល្អនោះ មកធ្វើ ស្រែចំការ តាំងខ្លួនជាម្ចាស់ដី បង្កើតបានជាគ្រួសារ រួចនាំគ្នា ធ្វើបាបពួកអ្នកស្រុកដើម យ៉ាងសាហាវបំផុត នាំអោយពួកនោះភ័យក្លាចនាំគ្នារត់ទៅពួននៅក្នុងព្រៃអស់។ របៀតចាត់ការ របស់ពួកយួនឈ្លានពាន បែបនោះឯង ដែលជា កត្តា នៃ ការរលត់សូន្យ នៃ នគរចំប៉ា ដែលពីដើម ជា នគរមួយ ធ្លាប់មានឫទ្ធីមួយដែរ នៅដំបន់ឥណ្ឌូចិន។ ក្រោយពីបានទទួល វិជយ: លើនគរចាម ក្នុងឆ្នាំ ១៤៧០ ព្រះរាជា យួនព្រះនាម Lê Thanh Tôn ទុកស្តេចចាម អោយនៅគ្រងរាជ្យដដែរ ក្នុងទឹកដីមួយចំណែក របស់នគរចំប៉ា តែបើកសិទ្ធិអោយប្រជាជនយួន ចូលមករស់នៅ លើទឹកដីចំប៉ាតាមសេរី គឺទុកដូចជាទឹកដីយួនតែម្តង។ ក្រោយមកទៀត នគរចំប៉ា បានត្រូវយួនលេបទាំងមូល នៅក្នុងអំឡុង សតវត្ស ទី១៧ ដល់ ទី១៨ ហើយយួន អោយឈ្មោះថ្មីថា អណ្ណាម។ ឧទ្ទគ្គត នៃ នគរចំប៉ា នាំអោយ ស្រុកខ្មែរ និង ស្រុកយួន មានព្រំដែនជាប់គ្នា។ តែនៅពេលនោះ ស្រុកយួន មានកើតសង្គ្រាមស៊ីវិល រវាង ក្រុមទ្រិញ (ស្តេចត្រាញ់ខាងជើង) នឹង ក្រុមង្វៀង (ស្តេចត្រាញ់ខាងត្បូង) នៅក្នុងអំឡុង ឆ្នាំ ១៦២៧ ដល់ ១៧៧២។ នៅឆ្នាំ ១៩៧៧

ទ័ពយួនខាងជើង ដកទ័ពថយ ពីទឹកដីយួនខាងត្បូង។ ការដោះដៃនោះ ទុកជាជ័យជំនះ ដល់ ក្រុមយួនខាងត្បូង ដឹកនាំដោយ នាយកមេទ័ពឈ្មោះ Hiên Vuong។ ជននេះ តទៅមុខ ជាស្តេចត្រាញ់ យួនខាងត្បូងឯករាជ្យពេញលេញ ពុំអាចប្រកែកបាន ទោះបី ព្រះរាជាយួនខាងជើង ក្រោយពីបានដកទ័ពខ្លួនចេញពី យួនខាងត្បូងបានតែងតាំង មេទ័ពខ្លួន ឈ្មោះ Trinh Tac ជាមេទ័ពដឹកនាំ យុទ្ធការយោធានោះ ជាស្តេចសន្តិភាពូនីយកម្មនៅទិសខាងត្បូង។

ទោះបី មានសង្គ្រាមស៊ីវិល រវាងយួននឹងយួន យ៉ាងណាក៏ដើរ តែដំណើរ ទៅទិសខាងត្បូង នៃ ជនជាតិយួន នៅមានបន្តជានិច្ច ពីនគរចាម ហូរចូលមកក្នុងទឹកដីខ្មែរនៅ កូសាំងស៊ីន (កម្ពុជាក្រោម)។ នៅឆ្នាំ ១៦៥១ នៅស្រុកខ្មែរ មានកើតវិបត្តិផ្ទៃក្នុង រវាងខ្មែរនឹងខ្មែរ ពេលនោះរាជសន្តតិវង្សខ្មែរ បានសូមជំនួយពី ស្តេចយួន ឈ្មោះ ង្វៀង វឿង (Hiên Voung) ដើម្បី បង្ក្រាប រាជ្យភង្គ[38]ខ្មែរមួយអង្គ។ ពួកង្វៀង ប្រយាប់ប្រយ៉ាល បញ្ជូនកងទ័ពមកជួយច្បាំងរាជសន្តតិវង្សខ្មែរ តែក្រោយពីបានជ័យជំនះ ពួកគេ បង្ខំ ព្រះរាជាខ្មែរ អោយប្រគល់ខេត្តពីរ ដល់គេគឺ ព្រៃនគរអណ្តើត (Baria) និង ដូនណៃ (Biên Hoa) ជា

[38] រាជ្យភង្គ, ក្សត្រដណ្តើមរាជ្យ ; usurpateur។

សគុណ នៃ ជំនួយនោះ។ នៅឆ្នាំ ១៦៩៦ យួនចូលមកនៅពេញខេត្ត ព្រៃនគរ ហើយបន្តវាតទីកដី មកដល់ទន្លេមេគង្គ នៅចុងសតវត្សទី១៧ គឺថា យួនខាងត្បូង ត្រួតត្រា លើខេត្តខ្មែរទាំងឡាយ នៅ បូព៌ាកូសាំងស៊ីន។ តាមឯកសារបរទេស ថា នៅក្នុងដំបន់នោះ មាន គ្រួសារខ្មែរ រស់នៅចំនួន ប្រមាណ ៤ម៉ឺនគ្រួសារ តែប៉ុណ្ណោះ ហើយដើម្បី ធ្វើប្រជាភិវឌ្ឍន៍ ត្រូវចាំបាច់បញ្ចូលប្រជាជនយួន មករស់នៅទីនោះ។

ជាឱកាស ដោយក្រដាយ មួយទៀត ដល់យួន ក្នុងការចូលមកកាន់កាប់ ខេត្តខ្មែរ ជាច្រើនថែមទៀត នៅមស្ទឹមកូសាំងស៊ីន (ខេត្ត ពាម (Ha Tiên) និង ក្រមួនស (Rach Gia) តាមឆ្នេរសមុទ្រសៀម គឺ ដោយសារ ជនចិនម្នាក់ ឈ្មោះ Mac Cuu រត់ចេញពីប្រទេសចិន នៅពេលដែល ពួក Tsing ឈ្នះសង្គ្រាមនៅស្រុកចិន មករស់នៅ ក្នុងតំបន់ខាងនិរតី នៃ ស្រុកខ្មែរ បង្កើតបានជា ក្រុងដុះដាលមួយ ឈ្មោះ កំពត ហើយនៅទីនោះ បានទាក់ទាញ ជនជាតិចិន-យួន ជាច្រើន មករស់នៅ។ តែនៅឆ្នាំ ១៧១៥ ទ័ពសៀម ចូលមកវាយកំពត ជនចិន Mac Cuu នោះ បានបញ្ជូន កម្មការខ្លួនពីរនាក់ ទៅសូមជំនួយពី ព្រះចៅក្រុងអណ្ណាម អោយតែងតាំងខ្លួនជា ចៅហ្វាយខេត្ត ខេត្តពាម ដើម្បី កេណ្ឌទ័ព ច្បាំងទប់ទល់នឹងសៀម។ ព្រះចៅ Minh Voung យល់ព្រម ទទួលយកការស្នើរនោះ ហើយ

បញ្ជូនកងទ័ពមកជួយ ជនចិន Mac Cuu វាយយក ក្រុង កំពត ពីសៀម បានវិញ។ នៅឆ្នាំ ១៧៣៥ បន្ទាប់ពី Mac Cu បានលាលោកទៅ ព្រះចៅ Minh Voung តែងតាំងកូន ប្រុស Mac Cuu ឈ្មោះ Mac Thien Tu ជាចៅហ្វាយខេត្ត ពាម ជំនួស សពឪពុក។ ព្រះរាជាខ្មែរ ពុំសុខចិត្ត ក៏លើក ទ័ពទៅច្បាំងនឹង Mac Thien Tu នៅឆ្នាំ ១៧៣៩ តែពុំ បានទទួល ជ័យជំនះនោះទេ។ ព្រះចៅ ក្រុងអណ្ណាម កោត សរសើរ ដល់ស្នាដៃ Mac Thien Tu ដែលបានច្បាំងឈ្នះខ្មែរ ហើយ តែងតាំង ជននោះ ជា ឧត្តមសេនីយ។

នៅពេលដែលយួនជួយ ជនចិន Mac Cuu បន្ទាប់មក Mac Thien Tu យួន បានច្បាំងនឹងខ្មែរផ្ទាល់ នៅដំបន់ម ផ្សឹម កូសាំងស៊ីន ដែរ មានកាលខ្លះថា ជួយខ្មែរ ច្បាំងនឹង សៀម មានកាលខ្លះថា សងសឹកនឹងខ្មែរ ដែលបាន សម្លាប់ប្រជាជនយួន។ ដូចនេះ នៅឆ្នាំ ១៧៣១ យួន ឈ្នះ ខ្មែរ រួចចូលមក ត្រួតត្រា ខេត្តខ្មែរ ជាច្រើនទៀត ដូច យ៉ាង មេ-ស (Mytho) និង លង់ហោរ (Vinh Long) បន្ទាប់ មក ខេត្ត ផ្សារដែក (Sa Dec) និង មាត់ជ្រូក (Chau Doc) នៅឆ្នាំ ១៧៥៧។ ការណ៍ដែលគួរកត់សំគាល់ គឺ ក្រោយពី ព្រះចៅ Vo Voung សោយព្រះទិវង្គត នៅឆ្នាំ ១៧៦៥ ទឹក ដី កូសាំងស៊ីន ត្រូវបានយួន កាប់កាប់ទាំងអស់ទៅហើយ លើកលែងតែ ខេត្ត ទ្រាំ (Soc Trang) និង ជ្រោយទឹកខ្មៅ (Camau) ដែលធ្លាក់ទៅក្នុង កណ្តាប់ដៃយួន ក្រោយគេ

បំផុត គឺ នៅឆ្នាំ ១៨៤០។ ពីពេលនោះមក ប្រវត្តិសាស្ត្រ ដែនដី កម្ពុជាក្រោម ដូចជាប្រវត្តិសាស្ត្រ នៃ នគរចំប៉ា ដែរ ក៏រលាយចូលជាមួយនឹង ប្រវត្តិសាស្ត្រ នៃ ប្រជាជាតិ យៀកណាម រហូតមកទល់ថ្ងៃនេះ។

ក្នុងរាជ្យព្រះបាទ មិញ ម៉ាង (Minh Mang) (១៨២០-១៨៤១) ស្រុកខ្មែរ ទាំងមូល ត្រូវចែកជាពីរភាគ ដែលមានទល់ដែន នៅត្រង់ខ្សែបន្ទាត់ខ័ណ្ឌខែត្រពោធិសាត់ និង បាត់ដំបង ហើយខ្សែនេះឆ្លងបឹងទន្លេសាប ឡើងទៅដល់ម្លូព្រៃ មុននឹងតម្រង់ ឆ្ពោះទៅស្ទឹងត្រែង ទៅដល់ព្រំប្រទល់ខ្មែរវៀតណាមសព្វថ្ងៃនេះ។ ដូចនេះ ដីមួយភាគបី នៃកម្ពុជា ភាគខាងជើងទន្លេសាប ក្លាយទៅជា អាណាខែត្រសៀម។ ពីរភាគបី នៃ ប្រទេសកម្ពុជាក្រោម ខ្សែបន្ទាត់ដដែលនោះ ក្លាយទៅជា អាណាខែត្រយួនឈ្មោះ ត្រាន តាយ ថាញ់ (Trân Tay Thanh) ដែលមានស្តេចត្រាញ់តាំងជានីនៅ ណាំ យ៉ាង ជាឈ្មោះយួន (ភ្នំពេញ)។ លោក នួន ឃឿន សរសេរនៅក្នុងសៀវភៅលោក មានចំណងជើងថា ‹ដំណើរឆ្ពោះទីទិសខាងកើត - ឥណ្ឌូចិនឆ្នាំ២០០០ ថា ព្រឹត្តិការណ៍នេះ មានលក្ខណៈជា ‹ដំណើរឆ្ពោះទៅទិសខាងលិច› វិញ នៃជនជាតិយួន ដោយហេតុ ‹ដំណើរសំរុកចុះមកក្រោម› បានសំរេច ដល់ទីដៅ ចុងក្រោយហើយ ព្រោះជ្រោយ ទឹកខ្មៅ (Camau) ដែលជាដែនដីខាងត្បូង បំផុត នៃ ឥណ្ឌូចិន អតីតបារាំងសែស បានត្រូវធ្លាក់ទៅ

ក្នុកណ្ដាប់ដៃយួន ជាស្រេចទៅហើយ។ តែអាណាខែត្រថ្មី ត្រានតាយថាញ់ នេះ ពុំមានអាយុយឺនយូរទេ ព្រោះការ អនុវត្តន៍នយោបាយតឹងរ៉ឹង បញ្ចូលខ្មែរអោយទៅជាយួន (politique d'assimilation forcée) បណ្ដាលអោយមាន ប្រតិកម្មយ៉ាងខ្លាំង ពីសំណាក់មហាជនខ្មែរ។ ការបេះបោរ ប្រឆាំងបំបាត់យួនជិះជាន់ បានផ្ទុះឡើង ដឹកនាំដោយ ព្រះអង្គឌួង ដោយមាន ជំនួយសៀមផង បានធ្វើអោយ អំណាចយួន មានការខូចខាត យ៉ាងច្រើន ហើយ ទ្រឹង មិញ យ៉ាង ក៏ដកទ័ពថយទៅនៅ អាន យ៉ាង (Ang Giang) ក្នុងឆ្នាំ ១៨៤១។

គួរកត់សំគាល់ថា បន្ទាប់ពីការភ្ជាប់កូសាំងស៊ីន ទៅវៀត ណាម ដែល ប្រទេសបារាំង បានសំរេច នៅថ្ងៃទី២១ ឧស ភា ១៩៤៩ ជនជាតិខ្មែរ នៅកម្ពុជាក្រោម បានក្លាយទៅ ជា ប្រជាពលរដ្ឋយួន ដើមកំណើតខ្មែរ ក្នុងភាសាយួន ថា ‹វៀតហ្គុកមៀន›។ កាលយួនចូលកាន់កាប់ស្រុកខ្មែរ នៅ អំឡុងឆ្នាំ ១៩៧៩ ដល់ ១៩៨៩ យួន គេដាក់ឈ្មោះជាផ្លូវ ការអោយ ជនជាតិខ្មែរ ថា ជនកម្ពុជា ដើមកំណើតខ្មែរ ព្រោះ ក្នុងពាក្យកម្ពុជានោះ យួនគេបញ្ចូល ជនជាតិយួន ដែលមករស់នៅក្នុងស្រុកខ្មែរ ថាជា ជនកម្ពុជា ដែរ តែ មាន ដើមកំណើតជា វៀតណាម។ នយោបាយនេះ ខុសពី នយោបាយ ធ្វើអោយខ្មែរទៅជាយួន លើកនេះគឺ ធ្វើអោ យយួន មករស់នៅស្រុកខ្មែរ ទៅជាម្ចាស់ នៃ ស្រុកខ្មែរ

ដោយទុកជនជាតិខ្មែរ ជាពលរដ្ឋបន្ទាប់បន្សំ (citoyen de second zone)។

លោក នួន ឃឿន ស្មានទុកតាំងពីឆ្នាំ ១៩៧០ ថា ដល់ឆ្នាំ ២០០០ យួនអាចនឹង សំរេចបាន នូវ ដំណើរឆ្ពោះទៅទិសខាងកើត ដោយលើកយក កត្តាជាគ្រោះថ្នាក់ ជាច្រើន ដល់ប្រជាជាតិខ្មែរ មកសំអាង ជាប្រស្នាផង និង ជាចម្លើយផង ចំពោះមុខ គ្រោះថ្នាក់នោះ។ តើខ្មែរត្រូវធ្វើដូចម្តេច ? ចម្លើយនេះអាចធ្វើបាន ស្រេចទៅលើការស្គាល់លទ្ធភាព ឬ សមត្ថភាព នៃប្រជាជាតិខ្មែរនេះឯង។

**ឯណាគ្រោះថ្នាក់ សំរាប់ប្ជាជាតិខ្មែរ ?**

លោក នួន ឃឿន រាប់រៀប កត្តាជាគ្រោះថ្នាក់ធំបីយ៉ាង ដូចជា កម្លាំងនយោបាយ - គុណសម្បត្តិនៃប្រជាជន - ការវិវត្តន៍នៃបណ្តាជន ដែល ជនជាតិវៀតណាម មានទាំអស់ ដោយឥតបើប្រកែកបាន។ តើ អរិយធម៌ខ្មែរ និង យួន មាន វិវត្តន៍ ផ្ទុយគ្នា ពោលថា អរិយធម៌យួនចេះតែមានការចំរើនឡើង រីឯ អរិយធម៌ខ្មែរ មានការរលត់សូន្យទៅវិញ ?

បារាំងសែសម្នាក់ ឈ្មោះ អ.បូឌួរ សរសេរក្នុង ឆ្នាំ ១៩០០ សៀវភៅមួយ មានចំណងជើងថា ‹ឥណ្ឌូចិន› ថា : ‹*ប្រជាជននៅកម្ពុជា ប្រហែលជាខ្លាំងតាមផ្លូវកាយ ជាងប្រជាជន អណ្ណាមមែន ប៉ុន្តែខ្វះថាមពល ខ្វះសមត្ថភាព។ ការ*

*រៀបចំលើផ្ទៃសង្គម នៅរាក់កំភែល ហើយស្រដៀងនឹងរបៀបព្រៃ។ គ្មានការបណ្ដុះបណ្ដាល គំនិតប្រាជ្ញាឡើយ (ក្នុងពេលដែលនៅអណ្ណាមយួនក្រយ៉ាងណាក៏ដោយ ហើយគ្រួសារខ្លួនតូចតាច យ៉ាងណាក៏ដោយ ក៏នៅតែមានការអប់រំលឹកតែគ្រប់គ្នា។ ភូមិយួនទាំងអស់ មានសាលារៀនបង្រៀនឥតយកថ្លៃ បើមិនចង់ថា គេតម្រូវអោយកូនក្មេងទៅរៀនគ្រប់គ្នា) រីឯ ភូមិខ្មែរ គ្មានសាមគ្គីធម៏តាមផ្លូវចិត្តឡើយ ហើយដោយហេតុនេះ ឥតមានមនោសញ្ចេតនាជាតិបន្តិបន្តួច ឥតមានថា មាតុភូមិជាអ្វីឡើយ។ ជនខ្មែរ អន់ជាង ជនយួនយ៉ាងឆ្ងាយ ក្នុងគ្រប់ផ្នែកទាំងអស់។ ប៉ុន្តែ បើខ្មែរគ្មានគុណសម្បត្តិយួន ខ្មែរមានគុណវិបត្តិយួន រហូតដល់ទៅ ប្រាក់ចំណូលមែនទែន នៃស្ដេចខ្មែរ មកតែពី ការយកពុង លើបនល្បែងស៊ីសង ដែលចិនកាន់ ហើយដែលផ្ញើអោយ ប្រទេស ហិនហោច.... ពាណិជកម្មទាំងមូល នៅក្នុងដៃបរទេស : យួន ចិន ចាមជ្វា›*[39]។

គំនន់អប្បិយបែបនេះ (cette remarque désagréable) មាននៅក្នុងសៀវភៅ ‹ទំលាប់ និង ទំនៀម នៃ ខ្មែរ› ចេញនៅឆ្នាំ ១៩៣៨ សរសេរដោយ លោក និង លោកស្រី ហ្គីប៉ូរ៉េ

[39] ដកស្រង់ទាំងស្រុងពីឯកសារ សរសេរដោយ លោក ចាន់ ដារា និង ប៉ែន នារាវី មានចំណងជើងថា : កម្ពុជា និង សហព័ន្ធឥណ្ឌូចិន - បោះពុម្ពនៅម៉ុងរេអាល កាណាដា ក្នុងខែ មេសា ឆ្នាំ ១៩៨៣។ ឯកសារនេះ ដំកល់ទុកតាមច្បាប់ នៅបណ្ណាល័យជាតិ នៃ កេបិក លេខ D8300817។

និង អេរ៉ុលីន ម៉ាស្ស៊ែរ៉ូ មានសេចក្តីដូចតទៅ: « ខ្មែរ ទាំងឡាយ ដែលថា លូតលាស់ច្រើន តែមិនសូវប្រាជ្ញា មិន សូវ ចេះដឹងអ្វីទេ ហើយឥតយកចិត្តទុកដាក់ លើអ្វីទាំងអស់។ តាមពាក្យនិយាយ របស់សិស្សក្មេងម្នាក់ នៃវិទ្យាល័យ ស៊ីសុវត្ថិ ថា ‹មួយពួកជាក្របីអត់ឃ្លាន› ដែលស៊ីប្រទេស ឯង, ‹មួយពួកទៀតជា ពពែល្វីល្វើ› ដែលចេះតែស្រែកតែ ពីសតែពាស ឥតដឹងខុសត្រូវ។ ពួកទី១ បើខ្លួនមានបង ប្អូន ឬ អ្នកគាំពារធំធំ បានមុខងារ ‹ខ្លាញ់› ជាអ្នករាជការ ហើយទាញយកកំរៃអោយអស់ពីដៃ។ ឃើតស្ទឹក ប្រាជ្ញាទាល ប៉ុន្តែស្មានតែខ្លួនវៃឆ្លាត, ពួកនេះមើលងាយ ជួនកាល ជនជាតិអ៊ឺរ៉ុប ក្នុងនាមនៃប្រពៃណីអាថ៌កំបាំង អ្វីម្យ៉ាង ដែលយើង ទៅមិនដល់ឡើយ ហើយដែលនៅក្រោយនោះ គេលាក់បាំងការល្ងង់ខ្លៅរបស់គេ ជួនកាល បងប្អូនរួម ជាតិឯង ដែលគ្នាក្រីក្រហើយមិនលូតលាស់។ ការសំខាន់ ចំពោះ អស់លោកទាំងនេះ គឺមិនបាច់ធ្វើអ្វី មាន បានន្ទរសក្តិមួយ (បណ្ណទូតក្នុងរដ្ឋការ សឹងតែជាងារអភិ ជនមួយហើយ) វាយឫក ‹ពូជអង្គរវត្ត› នៅមុខពួកអ៊ឺរ៉ុប ធ្វើគ្រាប់តាមជនជាតិអ៊ឺរ៉ុប ដើម្បីអោយអ្នកនៅក្រោម បង្គាប់ខ្លួនកោត ហើយនឹង ស្ទាបអង្អែលសន្ទឹកប្រាក់នៅ គ្រប់ពេលណា បើឱកាសអោយ។ ត្រង់កន្លែងនេះ ពួកនេះ ធ្វើតាមប្រពៃណីមួយ យ៉ាងចាស់យូរមកហើយ ហើយខ្ញុំ យល់ថា កិច្ចការ នៃជីដូនជីតាពួកនេះ ក្នុងសម័យអង្គរ

*នៅត្រឹមតែ ត្រង់ភារៈ យ៉ាងធ្ងន់ នៃ អ្នកទាលុយ។ ‹ក្រុមទីពីរ ពួក ពពែ ដែលមានចំនួនធំជាងគេ មានច្រើនតែអ្នករងគ្រោះ។ ពិតហើយ ពួកនេះ ចង់បានជោគជ័យ ដូចពួកទីមួយដែរ ប៉ុន្តែ គ្មានដឹងខ្លួនថា អស់កម្លាំងពេក ដើម្បីទៅដល់នោះរួច។ តាមសំដីពួកនេះ ការខឹតខំ នៃជីដូនជីតាខ្លួន ដែលជាជាង (កសាងអង្គរ) និងជាអ្នកច្បាំងបានធ្វើអោយខ្លួនហេវហើវហៃ។ ខ្លួនមិនអាចទៅជា វេជ្ជបណ្ឌិតកើតទេ-សាស្ត្រាចារ្យក៏មិនកើត-គិលានុបដ្ឋាកក៏មិនកើត-អ្នកជំនួញក៏មិនកើត - និយោជិកក៏មិនកើត-កម្មករក៏មិនបាន-អ្វីក៏មិនបានដែរ ក្រៅពីនាម៉ឺន ឬមួយ បណ្ឌិតទូត* »។

ចំណែកលោក ប៉ូល ឌូបែរ គូរ៍វន៏រ ហ្សេណេរ៉ាល់[40] នៃឥណ្ឌូចិន ពីឆ្នាំ ១៨៩៧ ទៅ ១៩០២ បានសរសេរ រហូតដល់ការជេត្មះ ដល់ជនជាតិខ្មែរតែម្តង ក្នុងសៀវភៅមួយឈ្មោះ ‹ឥណ្ឌូចិន បារាំង› ចេញនៅឆ្នាំ ១៩០៥ ដែលមានសេចក្តីថា : « *តើសាសន៏ខ្មែរ នេះ មាននៅសល់ទេ ? សាសន៏នេះបានឃើញការចុះអាប់អោននៃខ្លួនទេ ? ជនានុជនកម្ពុជាសព្វថ្ងៃ តើសៀមជាកូនរបស់ខ្លួនឬទេ ? មិនមែនទេ។ ពួកអ្នកឈ្នះ មិននៅត្រឹមតែយកទ្រព្យសម្បត្តិទេ គេបានទាំង កំទេចសាសន៏នេះ លប់ចេញពីបញ្ជីមនុស្សរស់។ ភស្តុតាងគឺ នៅក្នុងជនានុជនកម្ពុជា គ្មានសល់ប្រពៃណី*

[40] គូរ៍វន៏រ ហ្សេណេរ៉ាល់, អគ្គអភិបាល។

អ្វីមួយ អនុស្សាវរីអ្វីបន្តិច នៃភាសាខ្មែរ។ យើងបានឃើញ ពួកនេះ ឈរជាទស្សនិកជន ព្រងើយកន្តើយ និង គត យល់អ្វី នៅមុខអច្ឆរិយភាព នៃស្ថាបត្យកម្មបុរាណ គត ដឹងយល់អ្វីទាំងអស់ អំពីអក្សរចារិកលើថ្ម នៃសំណល់ ប្រាសាទ ដ៏ឆ្នើមទាំងនេះ, គឺជាបរទេស ដូចយើងដែរ ចំពោះមុខមនុស្សដែលរស់នៅក្នុងទីនេះ មុនខ្លួន ក្នុង ជីវិតមួយ ដែលខ្ពស់ជាង។ គ្មានប្រជាជនណាមួយឡើយ ហើយសឹងតែគ្មានបុគ្គលណាម្នាក់ផង ដែលអាចអួតខ្លួន ថាមានមានពូជអំបូរជាខ្មែរ។ ករណីជាតិខ្មែរនៅអាស៊ី គឺ ដូចជាករណីជាតិក្រិក និង រ៉ូម៉ាំង នៅអ៊ឺរ៉ុបដែរ។

សេចក្តីស្លាប់ បានផ្តេចជីវិត មនុស្សទាំងឡាយដែរ ក្នុង ពេល ក្នុងពេលជាមួយគ្នា ដែលខ្លួន បានផ្តាច់ជីវិតប្រជា ជាតិទាំងពួង។ ក៏ប៉ុន្តែ មានភូមិពីរ ដ៏ឆ្ងាយពីគ្នាដាច់ ស្រយាល ក្នុងកម្ពុជា កប់បាត់ ក្នុងព្រៃស្រោងជំ ចូលមិន ចុះ ដែលមាន បណ្តាជន ក្នុងសាសន៍មួយ ខុសពីសាសន៍ កម្ពុជា ហើយដែល និយាយ នៃភាសាបុរាណ លែងពីរោះ អស់ហើយ រយើករយាកអស់ហើយ ប៉ុន្តែដែលគេស្គាល់ភ្លាម។ តើមនុស្សក្រុមតូចនេះ មានខ្មែរ ដ៏ឧត្តម ជាបុព្វការីឬ ? ការណ៏នេះ អាចពិតដែរ។ គ្រួសារ មួយ ពីរ បី មិនដឹង ប្រហែលជា បានបានផុតខ្លួនពី ការបំផ្លេចបំផ្លាញ ដែល បានត្រូវធ្វើឡើងកាលពី ប្រាំ ប្រាំមួយ សតវត្សរ៍មុន ហើយ នៅរស់រានមានជីវិត បន្ទាប់ពីបានភៀសខ្លួន ទៅនៅទី

*ដំបន់ព្រៃភ្នំ ហើយបន្ត ពូជរៀងរហូតមក ក្នុងភាពគោកយ៉ាក និង ភាពអាប់អោន នៃការភ័យខ្លាច ជានិច្ចនិរន្តរ៍។ តើមនុស្សរហេមរហាមទាំងនេះ ជាកូនអ្នកចំបាំងដ៏ហំ ជាកូន នៃសិល្បករដ៏ឧត្តម នៃរាជាណាចក្រ ដែលរលាយបាត់នោះឬ ? ការណ៍នេះ អាចពិតដែរ។ ប៉ុន្តែ បើដូច្នេះមែន មិនដឹងជាឱពុកខ្លួន ដែលមើលឃើញកូន ពីលើឋានសួគ៍ព្រះពុទ្ធនោះ ឈឺចិត្តចុកចាប់ ក្នុងខ្លួនយ៉ាងណាទេ, ច្បាស់ជាគាត់ ចង់អោយការសម្លាប់រង្គាល (ដែលបានយកជីវិតគាត់នោះ) កុំទុកកូនគាត់ អោយនៅសល់ម្នាក់ ជាជាងទុក អោយសល់ លើដី នូវអនុស្សាវរីយ៍ របស់គាត់របៀបនេះ អោយសល់ដំបូន្មានរបៀបនេះ ដល់ប្រជាជនទាំងឡាយ ដែលបោះបង់ខ្លួនចោល»។* (ដកស្រង់ចេញពីឯកសារ របស់លោក ចាន់ ដារា និង ប៉ែន នារវី)។

ជនជាតិខ្មែរ មានចំនួនតិចតួចណាស់ ដឹងអំពី សំណេរខាងលើនេះ ព្រោះ ជាសៀវភៅបរទេស សរសេរជាអក្សរបរទេស ហើយ ពួកអ្នកចេះដឹងខ្មែរ មិនសូវអានផង តែបើសិនជាបានអាន ក៏គ្មានអ្នកណា យកមកបកប្រែជាភាសាជាតិ ដើម្បី ផ្សាយដាស់តើន សតិសម្បជញ្ញៈខ្មែរ អោយបានដឹង អំពី ការយល់ឃើញ ជា ការវិនិច្ឆ័យរួចស្រេច នៃ ពួកបារាំងសែស មួយក្រុម ដែលជា ចៅហ្វាយខ្មែរផង ជាគ្រូខ្មែរផង លើ គុណវិបត្តិ របស់ខ្លួន ទុកជា ប្រជាជន

ល្ងង់ខ្លៅ បើប្រៀបធៀបទៅនឹង ប្រជាជនយួន ដែលពួកគេ ទុកស្មើនឹង ប្រជាជនជប៉ុន លើឋានប្រាជ្ញា។

ការពោលអះអាង ដោយឥតបើប្រកែកបាន នៃ វិសិដ្ឋភាព របស់អរិយធម៌យួន លើ ចាម គឺស្ថិតនៅលើ ជ័យជំនះជាស្ថាពរ របស់វៀតណាម លើ នគរចំប៉ា និង ស្រុកខ្មែរ នៅលើទឹកដី កម្ពុជាក្រោម នោះឯង។ *ប្រវត្តិសាស្ត្រ នៃជនជាតិយៀកណាមនេះ ជាប្រវត្តិសាស្ត្រនៃសង្គ្រាមដែលប្រជារាស្ត្រយៀកណាម បានធ្វើដោយឥតស្រាកស្រាន្ត ជាមួយនឹង បរទេស នៅជិតខាងខ្លួន និង រវាងគ្នានិងគ្នា ខាងជើង ទល់នឹង ខាងត្បូង* (នួន ឃឿន)។

## វប្បធម៌ នៃអព្យាគម

ការនេះជាការពិត របស់ជាតិសាសន៍យួន រួចហើយ បង្កបង្កើត នូវ វប្បធម៌ នៃអព្យាគម (culture guerrière) នាំអោយ ប្រជារាស្ត្រយៀកណាម មានសេចក្តីក្លាហាន និងពិសេសបំផុតចិត្តតស៊ូខ្ជាប់ខ្ជួន។ វប្បធម៌សង្គ្រាមនេះឯងលើកទឹកចិត្ត ប្រជាជនយួន ទោះបីជា ជនអនាថា ក្រលំបាកតោកយ៉ាក, អ្នកទោស ដែលគេដេញពី ប៉ែកខាងលើ អោយចុះមករកទីតាំងថ្មី នៅភូមិភាគខាងក្រោម។ មុនដំបូង មកតាំងនៅដោយស្ងៀមស្ងាត់ រួចហើយក៏តាំងបង្ករឿងហេតុ គ្រប់បែបយ៉ាង ទោះបី ត្រូវធ្វើសង្គ្រាមក្តីទាល់តែម្ចាស់ដី ដកខ្លួន ពីទីតាំងរបស់ខ្លួន ឬ សុខចិត្តរស់នៅ នៅក្រោមឥទ្ធិពលយួន។ ការនេះ កំពុងមានជាថ្មី

ឡើងវិញហើយនៅលើដែនដីកម្ពុជាសព្វថ្ងៃ ដែល លោក នួន ឃឿន បានស្មានទុក តាំងពីឆ្នាំ ១៩៧០ មកម្លេះ, ពោលថា ប្រវត្តិសាស្ត្រ បន្ទួនខ្លួនឯង ចំពោះប្រជាពលរដ្ឋ ខ្មែរ ដែលកំពុងរស់ នៅក្នុង ភាពមិនដឹងខ្លួន ថា ការនេះ វាជា ការធ្វើអត្តឃាតកម្ម តែម្តង។ ត្រូវដឹងថា ទោះបីសព្វថ្ងៃនៅលើពិភពលោក មាន ស្ថាប័នអន្តរជាតិ ជាច្រើន សំរាប់ការពារ នូវ ការរំលោភ ដណ្តើមទឹកដី អំពីសំណាក់ជាតិមួយ ទៅលើជាតិមួយទៀតក៏ដោយ ក៏វៀតណាម នៅតែធ្វើបានសំរេច ស្រួលបំផុត មកលើជាតិ ខ្មែរ និង លាវ ដែលជាជាតិមាន អរិយធម៌រួម។ វៀតណាម បង្កើត សន្តិភាពត្រជាក់ (paix froide) សំរាប់ជាតិ ខ្មែរ និង លាវ នៅក្នុងនោះ ជាតិទាំងពីរនេះ ត្រូវរស់ ដោយទទួលស្គាល់វៀតណាម ជា ប្រមុខ របស់ខ្លួន ពុំអាចប្រកែកបាន ទោះបីខ្លួនចង់ ឬ មិនចង់ក៏ដោយ។ ពាក្យ សង្គ្រាមត្រជាក់[41] មានន័យថា ‹ជាការពិបាក ក្នុងការរួមរស់ ជាមួយគ្នា› (difficile coexistence) រវាង ជាតិសាសន៍ពីរ។ រីឯ ពាក្យថា សន្តិភាពត្រជាក់ ជាពាក្យបង្កើតដោយ លោក Boris Eltsine ដើម្បី អោយលក្ខណៈ នូវ ការទំនាក់ទំនង ទៅថ្ងៃមុខ រវាង ប្រទេស រ៉ូស៊ី នឹង មស្ទីមប្រទេស ដែល មិនសូវ

[41] សង្គ្រាមត្រជាក់ (guerre fria) ជាពាក្យបង្កើតឡើង ដោយ ជនជាតិ អេស្ពាញ្ញូល (Espagnols)នៅសតវត្សទី១៩ ក្នុងន័យថា ជនជាតិខ្លួន មានការពិបាក ក្នុងការរួមរស់ជាមួយ ជនជាតិ អ៊ីស្លាម នៅ ដំបន់ សមុទ្រមេឌីទែរ៉ាណេ។

មានការទុកចិត្តគ្នា និង មិនសូវមានមិត្តភាព។ សន្តិភាព ត្រជាក់ រវាង ជាតិសាសន៍ យួន ជាមួយ ខ្មែរ នឹង លាវ គឺ នៅក្នុង លក្ខណៈ : គ្មានការទុកចិត្តគ្នា និង គ្មានមិត្តភាព គឺមានតែ កំហឹង នៃ ជាតិសាសន៍ទុនខ្សោយ ចំពោះ ជាតិ សាសន៍ ខ្លាំងក្លា តែប៉ុណ្ណោះ។

## វប្បធម៌ នៃការដឹកនាំជាតិ

ការនេះ បញ្ជាក់បង្ហាញថា ជាតិសាសន៍យួន មិនត្រឹម តែ មាន វប្បធម៌ នៃសង្គ្រាម នៅក្នុងសន្តានចិត្តតែប៉ុណ្ណោះ ទេ គឺមាន វប្បធម៌ នៃការដឹកនាំជាតិ[42] ថែមទៀត។ ពួក វិទូអក្សរសាស្ត្រ (les lettrés) ពេលប្រឡងជាប់ជា *ឧត្តមម ន្ត្រីរដ្ឋ (mandarins) ទទួលតំណែង នៅក្នុងគ្រប់ទីកន្លែ ក្នុងព្រះរាជាណាចក្រ ក្នុងឋានៈជា តំណាង រាជរដ្ឋាភិបាល ចំពោះប្រជារាស្ត្រ ហើយប្រជារាស្ត្រនេះឯង ជាប្រភពកំណើ តេរបស់ខ្លួន។ ដូច្នេះ ប្រជារាស្ត្រ គោរព អ្នកបំរើ រាជការ គឺ ដូចជា គោរពព្រមគ្នា ខ្លួនឯងផង, គោរព រាជរដ្ឋាភិបាល តែមួយ, គោរព ច្បាប់រដ្ឋតែមួយ ដែលមាន ព្រះមហាក្សត្រ ជា បុត្រា នៃ សុលាល័យ (មេឃ) ទទួលអំណាច ពី ឋាននោះ សំរាប់ធានា នូវ យុត្តិធម៌ ដល់ប្រជារាស្ត្រ ដែលជា តនុជ (កូនប្រុសស្រី) របស់ពសុភា។ ទោះបី ពួក វិទូអក្សរសាស្ត្រ ទាំងនោះ ចូលធ្វើ ឧត្តមមន្ត្រីរដ្ឋ ចេញពី គ្រប់ស្រទាប់ សង្គម យ៉ាងណាក៏ដោយ តែ នៅពេល ក្លាយជា ឧត្តមមន្ត្រី

42 វប្បធម៌ នៃការដឹកនាំជាតិ ; culture du gouvernement national។

រដ្ឋ គឺរស់នៅក្នុងលក្ខណៈ ជា ជន មាន វណ្ណៈ ដោយសារថា ការប្រឡងចូល វាពិបាកក្រៃលែង ហើយ សំរាប់តែ ពួកវិទូ អក្សរសាស្ត្រ ដែលមានមូលដ្ឋាន ចំណេះចេះដឹង, និយាយ ភាសា, គំនិត, កង្វល់, គតិ ដូចគ្នា។ ឯកភាពនេះឯង បង្កើតជា ការសមគំនិត សុក្រិត ដែលជា វណ្ណៈសង្គម។

ទស្សនៈ របស់អ្នកប្រាជ្ញចិន ឈ្មោះ កុង ជឺ (៥៥១-៤៧៩ ក.គ.ស.) មិនដែលប្រើពាក្យថា អាទិទេព នៅឋានលើ ម្ដង ណាឡើយ តែបើគាត់ ចង់និយាយអំពី លោកធាតុ (univers) គឺគាត់ប្រើពាក្យ មេឃ ហើយ គាត់តែងតែ ពន្យល់ថា មិនមែនជា កបិចិត្ត (caprice) ឬ កំហឹង ឬ ហិតកម្ម[43] នៃ អាទិទេព នោះទេ ដែល ដឹកនាំលោកធាតុ តែជា អំពើ នៃកម្លាំង មិនចំពោះមុខ ឬ អបុគ្គលិក (forces impersonnelles) ដែល អត្តកម្មរបស់វា ជា អ្នក ទទួលខុសត្រូវ នូវ គ្រប់ធាតុភូត និង ការផ្លាស់ប្ដូរសព្វសារពើ។ ទស្សនៈនេះ គេអាចទុកជា គំនិតដើមដំបូង នៃ វិទ្យាសាស្ត្រ។ ដូចនេះ កុង ជឺ ថ្លែងថា ‹*ជនណា មិនចេះបំរើ មនុស្សលោក ដូចម្ដេច នឹងអាច បំរើ ព្រលឹងបាន ? ជនណាមិនស្គាល់ មនុស្សនៅមានជីវិត ដូចម្ដេច នឹងអាច ស្គាល់ ព្រលឹង នៃមនុស្សស្លាប់បាន ?*›។

---

[43] ហិតកម្ម ជាអំពើធ្វើផលប្រយោជន៍អោយ ; bienfaits។ ហិតករ គឺជាធ្វើអំពើនោះ។

គោលការណ៍ នៃ ការដឹកនាំជាតិ របស់វៀតណាម គឺផ្អែកលើ កុងជឺនិយម (Confucianisme) ដែលជាមាតា នៃវប្បធម៌ របស់ជាតិសាសន៍យៀកណាម។ គោលការណ៍នោះ គឺមូលវិធី ព្រមគ្នា នៃ របៀបរបប នៃបញ្ញា, នយោបាយ និង សង្គមកិច្ច។ ក្រុមអ្នកដឹកនាំជាតិ ជា វណ្ណៈបញ្ញវន្ត (intelligentsia) ចេញពី ពួកវិទូអក្សរសាស្រ្ត ជាអ្នកសង្វាតរៀនសូត្រ ដើម្បី ប្រឡងថ្នាក់ជាតិ តឹងរឹងបំផុត ចូលធ្វើជា អ្នករាជការ ដើម្បី បំរើប្រជារាស្ត្រ ដែលជាប្រភព នៃកំណើតរបស់ខ្លួន។ ការណ៍នេះ តើអាចនឹងទុកជា គោលការណ៍ នៃ រដ្ឋាភិបាល នៃប្រជារាស្ត្រ, ចេញពី ប្រជារាស្ត្រ និង ដើម្បី ប្រជារាស្ត្រ បានដែរឬទេ ? តួនាទី នៃ ព្រះមហាក្សត្រ នៅក្នុងគោលការណ៍នេះ ជា សមតា នៃ ប្រព័ន្ធដឹកនាំ ឬ Yin (ឆាយា ឬ អ្នកទ្រទ្រង់នៃស្រមោល) និង Yang (សូរ្យ ឬ វិភាករ គឺអ្នកធ្វើនូវពន្លឺ)។ Yin និង Yang ជាទិដ្ឋភាព ផ្ទុយគ្នា តែវា បង្គ្រប់គ្នា និង ប្តូរគ្នាមិនចេះចប់ នាំបញ្ចេញនូវថាមពល នៃ លោកធាតុ។ ភាសិតមួយពោលថា :ម្តង yin, ម្តង yang គឺថា ជា ឯកភាព នៃ Tao។ Tao នេះ ជា គោលការណ៍ នៃ ការផ្លាស់ប្តូរ ខ្លួនឯង ហើយ ក៏ជាឯកភាព នៃ គ្រប់ភាវៈ និង គ្រប់ការវិវត្តន៍។ អញ្ចឹងឯងមនុស្ស ជា អ្នកបំបង់ នូវ វិបរិត (perturbation) សព្វសារពើ ឬក៏ ជា វិបរិត នៃរូបវន្ត ដូចយ៉ាង ការរញ្ជួយដី, ទឹកលិច... ឬក៏ ជា នរវិបរិត ដូចយ៉ាង ឧទ្ទាមកម្ម, គ្រោះសា

ធារណៈ,ទុរភិក្ស...។ តែបន្តមកទៀត ពួកសាសនិក នៃ កុងជឺនិយមថ្មី គេ បន្ថយអំណាច នៃវិបរិត របស់មនុស្ស ដល់ខ្លួនឯង។ ដូចនេះ ដោយខ្វះគុណធម៌ហ្នឹងឯង មនុស្ស ផ្តន្ទាទោសខ្លួនឯង អោយទៅជា មនុស្ស ទ្រុស្តសីល។ គឺ ក្នុងនាយកគំនិតនេះ បាន ជា ជាតិសាសន៍ ចិន និង យួន ពុំទុក ព្រះមហាក្សត្រខ្លួន ជាអាទិទេព ទេ តែជា អាណត្តិគាហក នៃ សុលាល័យ (mandataire du ciel) ព្រោះ ព្រះមហាក្សត្រ ក៏ជាមនុស្ស ដូច្នេះ បើ ព្រះអង្គ គ្មានសីលធម៌ ទ្រង់នឹងក្លាយទៅជា មនុស្ស ទ្រុស្តសីល ដែល ប្រជារាស្ត្រ អាចទំលាក់ ព្រះអង្គ ពីរាជបល្ល័ងបាន ទៅតាម របៀបរបប នៃសុលាល័យ។ តាម គំនិតនេះ កុងជឺនិយម ជាក្បួនខ្នាត នៃ ជីវិត មាន សីលធម៌ ឈមទៅរក ដល់រក្សានូវ របៀបរបប និង ឋានានុក្រម នៅក្នុងសង្គម និង រដ្ឋ, ហើយជា ក្បួន ប្រឆាំងខ្លាំងនឹង អ្នកអនាធិបតេយ្យ នៃ បញ្ញា, នៃសង្គម, នៃច្បាប់។ ប្រយោគពិស្សតមួយ សំគាល់ នូវ លក្ខណៈ នៃ ការដឹកនាំល្អ ថា : *សូមអោយ ស្តេច ស្ថិតនៅជាស្តេច, សូមអោយរាស្ត្រ ស្ថិតនៅជារាស្ត្រ, សូមអោយបិតា ស្ថិតនៅជាបិតា, សូមអោយកូន ស្ថិតនៅជាកូន* !

## វប្បធម៌ នយោបាយ

ទំហំនយោបាយ នៃ អ្នកដឹកនាំយួន គឺ ការរក្សា នៃ សមតា នៅក្នុង នគរ និង សង្គម ដើម្បី អោយមាន ឯកភាព ទៅតាម *អវកាសនយោបាយ (espace politique)។ នៅ

ក្នុង សម័យបុរាណ ឯកភាពនោះ គឺ ស្ថិតនៅលើ រាជាធិរាជាណាចក្រ ដែលមាន ព្រះមហាក្សត្រ ប្រកបដោយ ទសពិធរាជធម៌។ ការបះបោរ នៃ ប្រជារាស្ត្រ គឺទុកជា សញ្ញាដែលវានឹងមកដល់ នៃ ការរលំ ព្រះចៅអធិរាជ្យ។ បុរាណវាទ ថា: ‹សុលាល័យ មើលឃើញ ដូច ប្រជារាស្ត្រ ដែរ›! ដូច្នេះ ការប្តូរ នៃ រាជសន្តតិវង្ស ជា ការចាំបាច់ សំរាប់រក្សា ឯកភាពជាតិ និង សង្គម បើរាជសន្តវង្សនោះ លែងមានការទុកចិត្តពី សុលាល័យ។ ក្នុងចំណុចនេះ វប្បធម៌នយោបាយយួនបុរាណ ក៏ដូច ចិន ដែរ គឺ ទុក បដិវត្តន៍ជា ការប្រែប្រួល ចេញពី បំណង សុលាល័យ ពោលថា ពីប្រជារាស្ត្រ ព្រោះ ‹សុលាល័យ មើលឃើញ ដូច ប្រជារាស្ត្រដែរ›!

## តើអ្វីទៅ ជា នយោបាយដឹកនាំជាតិ ?

នយោបាយដឹកនាំជាតិ បុរាណ ក៏វាមិនខុសគ្នាអ្វីនឹងសព្វថ្ងៃនោះដែរ។ ទទួលបន្ទុក នូវ កិច្ចការរដ្ឋសព្វសារពើ, យុត្តិធម៌ និង ការពារប្រជាជាតិ។ ដូច្នេះ រដ្ឋត្រូវមានមធ្យោបាយ ដើម្បី សាង ហេដ្ឋារចនាសម្ព័ន្ធ គ្រប់បែបយ៉ាង និង ធ្វើយុទ្ធការយោធា ជាយថាហេតុ សំរាប់ការពារជាតិ។ មធ្យោបាយនោះ គឺ ពន្ធដារ នោះឯង។ ដូច្នេះ តួនាទី នៃ នយោបាយដឹកនាំជាតិ គឺ ប្រើមធ្យោបាយ ដើម្បីកែ ធម្មជាតិកំណាច (corriger la nature cruelle), បង្ការនូវ មហន្តរាយ គ្រប់បែបយ៉ាង។ ជាសង្ខេប គឺ រក្សារ៉ាប់រង

នូវ ដំណើរការល្អ ដល់ សង្គមគ្រប់វិស័យ ដែលជាអាយុជីវិតសំរាប់ជាតិ ពោលថា អោយមាន ស្ថិរភាព នៃ សេដ្ឋកិច្ច, រដ្ឋ និង អរិយធម៌។

កិច្ចការទាំងអស់នោះហើយ ដែលត្រូវចាំបាច់មាន រដ្ឋខ្លាំង ដឹកនាំដោយពួកមន្រ្តីចេះដឹង មានមនសិការជាតិ។ ឃ្លាពិសេសមួយ របស់អ្នកប្រាជ្ញចិន ឈ្មោះ Mencius († ៣១៤ ម.គ.ស.) ថា : ‹*ធុរៈ នៃ មនុស្ស មាន គុណសម្បត្តិ ពុំដូច មនុស្ស សាមញ្ញនោះទេ។ មាន អ្នកខ្លះ ធ្វើកិច្ចការដោយប្រើ បញ្ញា, អ្នកខ្លះទៀត ធ្វើ ការហត្ថកម្ម, តែ អ្នកប្រើ បញ្ញានេះឯង ជា អ្នកដឹងនាំ អ្នកដទៃ, អ្នក ធ្វើការហត្ថកម្ម ត្រូវអ្នកដទៃដឹកនាំ*›។

ត្រីវប្បធម៌ ដែលបានរៀបរាប់ខាងលើនេះ ជាកម្លាំង ទឹកជំនន់ ប្រកបដោយឋាមពល លង់លិច ក្រឡាប្រឹថពីខ្មែរ និង លាវ ដោយ ផ្តេកភ្លាម ដល់ ប្រជាពលរដ្ឋ ទាំងពីរ។ តើអ្នកណាមួយ អាចទឹកស្មានបានថា ហេតុការណ៍បែបនេះ អាចនឹងមានកើតឡើងបាន នៅ វិភាគកាល (aube) នៃ សតវត្ស ទី២១ ដែលប្រជាពលរដ្ឋនិមួយ ស្គាល់តែ ពិភពលោករបស់ខ្លួន សាងលើច្បាប់អន្តរជាតិ និង សិទ្ធិប្រជាពលរដ្ឋ និង សិទ្ធិមនុស្ស ដែលជា ខែលសំរាប់ការពារ គ្រប់អំពើឈ្លានពាន ពីសំណាក់ប្រទេសមួយ ទៅលើប្រទេសមួយទៀត, បុគ្គលមួយ ទៅលើបុគ្គលទៀត។

តែ លោក នួន ឃឿន បានស្មានទុក តាំងពី ទស្សវត្សរ៍ ៧០ ថា : ‹*ប្រជាជាតិយៀណាម ជាប្រជាជាតិមួយ ដែលគេចាត់ទុក ដោយគ្មានលាក់លៀមថា ថាមពល មានគុណសម្បត្តិខាងផ្លូវបញ្ញា គ្រប់គ្រាន់។ សេដ្ឋកិច្ចប្រទេសយៀកណាមក្រោយសង្គ្រាម ជាសេដ្ឋកិច្ច ដែលមាន កម្លាំងក្លៀវក្លាស្របជាមួយនឹង កំរិតដ៏ខ្ពស់ ខាងការអប់រំវិទ្យាសាស្ត្រ និង បច្ចេកទេស នៃជនជាតិនេះ។ ម្យាងទៀត ខាងផ្លូវនយោបាយប្រទេសយៀកណាមនឹងមាន កងទ័ពខ្លាំងពូកែ ក្នុងចំណោម ប្រជាជាតិទាំងឡាយ នៅជ្រោយឥណ្ឌូចិន និង ក្នុងអាស៊ីភាគអាគ្នេយ៍នេះ។ តើកម្លាំង*ទាំងអស់នេះ ពុំមែនជាការគំរាមកំហែងទៅលើប្រជាជាតិខ្មែរជិតខាងទេឬ ?›។

ខ្មែរភាគច្រើន ជាពិសេសយុវជន ជំនាន់នោះ បានអានដោយថៅរ៉ៅ និង ពិច័យ[44] នូវ សៀវភៅ របស់លោក នួន ឃឿន នៅក្នុងបរិបទ ពិតប្រាកដមួយ គឺ ការឈ្លានពានដោយ កម្លាំងទ័ពយួនកុម្មុយនិស្ត មកលើប្រជាជាតិខ្មែរនៅឆ្នាំ ១៩៧០។ សួរថា តើចម្លើយខ្មែរ មានអ្វីខ្លះ នៅចំពោះគ្រោះថ្នាក់ពិតប្រាកដនេះ ដែលជាគ្រោះថ្នាក់មួយយ៉ាងធំ ដល់អាយុជីវិតប្រជាជាតិខ្មែរ ក្នុងបច្ចុប្បន្ន និងអនាគតជាតិខ្មែរ ? ដូច្នេះហើយវាសនាប្រជាជាតិខ្មែរ ក្នុង

[44] បានអានដោយថៅរ៉ៅ និង ពិច័យ ; ils ont lu avec empressement et ont l’examiné avec soin។

អនាគត ស្រេចទៅលើចម្លើយ ដែលខ្មែរ បានឆ្លើយរួច ហើយ និង បំរុងនឹងឆ្លើយបន្តទៀត តបទៅនឹង សំនួរ ជាអាយុជីវិត។

## ឯណាចម្លើយ នៃ ប្រជាជាតិខ្មែរ ?

តាំងពី សតវត្សរ៍ទី១៧មក ប្រជាជាតិខ្មែរ ប្រឈម នូវ វប្បធម៌ នៃ អព្យាគម របស់ប្រជាជាតិយៀកណាម បន្តពីប្រជាជនចាម។ ការប៉ះទង្គិច ចំនេះ សំដែងអោយឃើញអ្វីខ្លះ អំពី គុណសម្បត្តិ និង គុណវិបត្តិខ្មែរ ? សម័យមហានគររុងរឿង គឺស្ថិតនៅត្រឹមតែ ជា កម្រងអនុស្សវរីយ៍ស្រពេចស្រពិល នៅក្នុង សតិអ្នកដឹកនាំខ្មែរ ហើយ លុបបាត់អស់ពី សតិប្រជាពលរដ្ឋខ្មែរ។

លោក ចាន់ ដារា និង ប៉ែន នារវិ កត់ថា : ‹*តាំងពី សតវត្ស ទី១៥ (ពីគ.ស. ១៤៧៤ ការប្រជែងត្រីភាគី រវាង ស្តេចរាមាធិបតិ-ធម្មោរាជា-សូរិយោទ័យ) ដល់ទី ១៩ ជារយៈពេលខ្មៅគគ្រេច នៃ ប្រវត្តិសាស្ត្រខ្មែរ។ គឺជាសម័យ នៃការដណ្តើមរាជ្យគ្នា រវាង ក្រុមញាតិស្តេច, នៃការធ្វើយាងនយោបាយនៃការសម្លាប់រង្គាល, ក្នុងពេលដែលទឹកដីកម្ពុជា ចេះតែរបេះរបោចទៅ ក្រោមការរុញច្រាន នៃ សៀម និង យួន។ ពួកអ្នកចង់បានស្វេតឆ័ត្រ ខ្លះហៅសៀមមកជួយ ខ្លះហៅយួនមកពួតដៃ ក្នុងសង្គ្រាមភាតរឃាង ដើម្បីអំណាច។*

នៅពាក់កណ្តាលសតវត្សរ៍ទី១៧ ជនជាតិយួន ចូលមកកាន់កាប់ទឹកដីខ្មែរនៅកម្ពុជាក្រោមកាន់តែច្រើនឡើង។ ក្រោយពី ព្រះបាទ ជ័យជេដ្ឋាទី២ (១៦២៩-១៦២៧) ចូលទិវង្គត នៅទីក្រុង ឧដុង្គ ដែលព្រះអង្គ យកមកធ្វើជា រាជធានី ដោយគ្មានហេតុផលអ្វីសំខាន់សោះ ក្នុងនគរ មានកើត ជម្លោះអារុជ រវាង អភិមនិក នៃរាជបល្ល័ង្ក ហើយនៅរយៈនោះ ខេត្តព្រៃនគរ ធ្លាក់ទៅក្នុង កណ្តាប់ដៃយួន ហើយយួនដូរឈ្មោះ ហៅថា សេហ៊ូង (១៦៩៨)។ ហើយដំណើរយួន ចុះទៅទិសខាងត្បូង មាន ល្បឿនកាន់ តែលឿនឡើងៗ គ្មាន កម្លាំងខ្មែរ ណាមួយ អាចទប់ស្កាត់ បាន នោះឡើយ។

គួរបើកវង់ក្រចក ដើម្បី អធិប្បាយ ជាសង្ខេប អំពី រាជឃាត មាននៅក្នុង រាជវង្សានុវង្ស បន្ត ពី រជ្ជកាល ព្រះបាទ ជ័យចេស្តា ឬ ជ័យជេដ្ឋាទី២ ដែលជារជ្ជកាលមានទំនាក់ទំនងផ្ទាល់ជាមួយនគរយួន។

ជ័យជេដ្ឋាទី២ ជាបុត្រា របស់ព្រះបាទ ស្រីសុរិយោព័ណ៌។ ព្រះអង្គ មាន ព្រះអគ្គមហេសី ព្រះនាម ព្រះភគវតីអង្គចូវ ជាបុត្រីព្រះចៅអណ្ណាមកុកបុរី។ ជ័យជេដ្ឋាទី២ មាន ព្រះរាជបុត្រា ជាមួយព្រះនាងចូវ មួយព្រះអង្គ ព្រះនាម បញ្ញាតូ តែព្រះអង្គ ក៏មាន ព្រះរាជបុត្រាបុត្រី ជាមួយ អ្នកម្នាងដទៃទៀតដែរ ដូចជា អ្នកអង្គ ទេពបញ្ញាក្សត្រី, នូក្សត្រា,

ចន្ទរតិក្សត្រី និង ពញាចន្ទក្សត្រា។ ព្រះអង្គតូ ជាបុត្រាច្បង ដូចនេះ ព្រះអង្គ ជា រាជានុសិទ្ធិ។

ពេលដែលនគរយួន មានទំនាស់ជាមួយ នគរចិន ព្រះចៅអណ្ណាមកុក បានស្នើរសូម ព្រះជ័យជេដ្ឋា ជា កូនប្រសារ សូមខ្ចីតែ៥ឆ្នាំទេ ខេត្តកោះក្របិព្រៃនគរ ដើម្បីបង្ហាត់សេនាទាហាន។ ព្រះចៅខ្មែរ យល់ព្រម នូវសំណើរនោះ ដោយយល់ឃើញថា ព្រះចៅអណ្ណាម ជា ព្រះបិតាក្មេងព្រះអង្គ ហើយក៏ជា តំណាំង (gage) សម្ពន្ធមិត្ត ទប់ទល់ នូវការកំហែង ដោយថាហេតុ ពីសំណាក់សៀម។ ក្នុងរជ្ជកាលព្រះបាទ ជ័យជេដ្ឋា សៀមលើក ទ័ពមកច្បាំងនឹងខ្មែរ បីដង។ ទីមួយ នៅឆ្នាំ ១៦៣២ ព្រះចៅថៃណា[45] ជាព្រះរាជាក្រុងទេពបុរី ស្រីអយុធ្យា ដឹកនាំទ័ពដោយខ្លួនឯង មានរេហ៍ពល ចំនួន ១០ម៉ឺននាក់ ចូលវាយស្រុកខ្មែរ តាមចុងដែនស្រុកលាវ ចុះតាមប្រង់ចូលក្នុងស្រុកខ្មែរ មកក្រុងម្លូព្រៃ ជាំក្សាន្ត ជ្រៃសំបូរ កំពូលពេជ្យ។ តែត្រូវទ័ពខ្មែរ វាយបែកនាំគ្នារត់ទៅស្រុកសៀមវិញ។ មេទ័ពខ្មែរជំនាន់នោះ ឈ្មោះ ឧកញ៉ា តេជោបុរារាជមាស។ លើកទី២ មួយឆ្នាំក្រោយមក

[45] ចៅថៃណានេះ ដើមឡើយជារាស្ត្រទេ ហើយបានបួសជាភិក្ខុ មានងារជាមហាវិមល។ ថ្ងៃក្រោយមក ព្រះចៅនរេន្ទ្រសូរ ដែលស្តេចគ្រងរាជ្យសៀមបានវាយបន្ទាយលង្វែកខ្មែរបែក ពេលព្រះអង្គសុគតទៅព្រះចៅឯកាទសរដ្ឋ ជាព្រះអនុជឡើងគ្រងរាជ្យស្នងព្រះជេដ្ឋា។ ទទួលពេលនោះ ព្រះមហាភិមលនោះ បានសិស្សគុណច្រើន ក៏ចាកសិក្ខាបទហើយយកជាទ័ព លើកមកផ្ចិតតព្រះឯកាទសរដ្ឋៅ រួចឡើងសោយរាជ្យតាំងខ្លួនជាព្រះចៅថៃណាឡើង។

គឺឆ្នាំ ១៦៣៣ ព្រះចៅណាថៃ អោយកេណ្ឌរេហ៍ពល ៥ម៉ឺននាក់, ដឹកនាំដោយ ព្រះចៅវាំងណម ជា មហាឧបរាជ, អោយលើក កងទ័ពជើងទឹក មកវាយស្រុកខ្មែរ ម្តងទៀត។ ទ័ពសៀម រុលចូលស្រុកខ្មែរ តាមខេត្តកំពត តែត្រូវទ័ពខ្មែរ, ដឹកនាំដោយ ព្រះបរមរាជា មហាឧបរាជ ទ្រង់ព្រះនាម ព្រះឧទ័យ ដែលជា ព្រះអនុជ របស់ព្រះចៅខ្មែរ, វាយបែកនាំគ្នាដកថយទៅស្រុកសៀមវិញ។ លើកទី៣ ទ័ពជើងទឹកសៀម ដឹកនាំដោយ ព្រះរាជបុត្រ ព្រះចៅថៃណាព្រះនាម ព្រះជេដ្ឋា មានរេហ៍ពលចំនួន ៥ម៉ឺននាក់ លើកទ័ពមកដល់ស្រុកចន្ទបុរី ហើយ ចូលមកដល់ខេត្តកំពត។ ក្រោយពេលព្រះអង្គដឹងថា ទ័ពខ្មែរដឹកនាំដោយ ព្រះមហាឧបរាជឧទ័យ មានចំនួន ពលទាហាន និង អាវុធយុទ្ធភ័ណ្ឌ ច្រើនជាងទ័ពសៀម ក្រៃពេក ក៏សំរេចចិត្ត ដកទ័ពថយទៅវិញ។

នៅក្នុងប្រទេស ព្រះបាទ ជ័យជេដ្ឋា នៅឆ្នាំ ១៦៣២ ជួបប្រទះនឹងវិបត្តិ នៃ ការប៉ះបោរ ប្រឆាំងនឹងរាជ្យរបស់ព្រះអង្គ គឺ មានរាស្ត្រម្នាក់ នៅស្រុកក្រាំងសម្រែ ក្នុងខេត្តបរិបូណ៌ ឈ្មោះ សំ ចេះសិល្ប៍ ចេះមន្តអាគម ពូកែណាស់ មានរាស្ត្រ ខ្លបខ្លាចខ្លួន ហើយ ចុះចូលនឹងខ្លួនជាច្រើន ក៏តាំងខ្លួនជាស្តេចសម្រែ ប្រកាសនាមខ្លួន ជា ព្រះសម្រែរាជាធិរាជ តាំងព្រះនគរកំផែងវាំង នៅភូមិស្វាយអំពា ដែនមឿងកំពង់ហៅ (ក្នុងខេត្តកំពង់ឆ្នាំង)។ បន្ទាប់មក ស្តេច

សម្រែ ចាញ់ឧបាយកល អ្នកជំនាវ មហាទេវី នារីសោភ័ណ ដែលជាភរិយា ឧកញ៉ា តេជោបុរារាជ ត្រូវសេនា អ្នកជំនាវ ចាប់ខ្លួនបាន យកទៅប្រហារជីវិត។ ម្តងទៀត ព្រះបាទ ជ័យជេដ្ឋា ជួបប្រទះ នូវ ការប៉ះបោរ ពីសំណាក់ឈ្លើយស ង្គ្រាមសៀម ដែលខ្មែរចាប់បាន កាលជំនាន់ សៀមចូល វាយស្រុកខ្មែរ។ ពួកឈ្លើយទាំងនោះ វាប្រមូលគ្នាពីខេត្ត ទីទៃ បង្កើតបានជាកងទ័ពតូចមួយ នៅក្នុងខេត្តពោធិ សាត់ រួចវាយដេញចៅហ្វាយស្រុក ពោធិសាត់ ក្រគរ ខ្លុង ក្រង និង រលាប្អៀ។ ចៅហ្វាយស្រុកទាំងនោះ ទ្រាំតស៊ូពុំ បាន ក៏នាំគ្នារត់មកក្រុងឧដុង្គមានជ័យ។ ទើបព្រះរាជា ជ្រើសតាំង ឧកញ៉ា តេជោយ៉ត[46] ដែល ធ្លាប់ជា ដៃស្តាំ ទ័ព សព ឧកញ៉ា តេជោ បុរារាជ អោយនាំរេហ៍ពល ទៅបង្ក្រាប ពួកឈ្លើយសៀម បានសំរេច ដូចបំណងព្រះអង្គ។

លុះដល់ គ.ស. ១៦៣៧ ព្រះបាទ ជ័យជេដ្ឋា ទ្រង់ ព្រះឈួន ហើយក៏ទ្រង់ក៏សោយព្រះទីវង្គត ក្នុងព្រះជន្មវស្សា ៤៩ឆ្នាំ។ ពេលនោះ ចៅពញាតូ ជាព្រះរាជានុសិទ្ធិ ទ្រង់គង់ នៅក្នុង ព្រះផ្នួស ជាភិក្ខុ នៅនគរវត្ត ខណៈនោះ ព្រះបរមរាជវង្សា នុវង្ស និង នាម៉ឺន សព្វមុខមន្ត្រី ជំនុំព្រមយល់ថា សម្តេច ចៅពញាតូ ជាព្រះរាជបុត្រច្បង ដែលត្រូវទទួលរាជសម្បត្តិ

46 តេជោយ៉ត មានដើមកំណើត ជាពួង ជាមេទ័ពខ្មែរមួយ មានឈ្មោះល្បី ល្បាញណាស់។ ឧកញ៉ានេះ ហ៊ានកាត់-ក អ្នកម្នាង របស់ព្រះរាជា ព្រោះយល់ ឃើញថា អ្នកម្នាងនោះ ហ៊ានប្រឆាំងខ្លួន ជាអ្នកកាន់ ព្រះរាជអាជ្ញាសឹក ដើម្បីនឹងប្រាបប្រាមសត្រូវផែនដី។

នោះ ទ្រង់នៅព្រះផ្នួសនៅឡើយ បើយើងនឹងអញ្ជើញស្តេច ចាកសិក្ខាបទមក ក៏ពុំទាន់ ហើយព្រះរាជហឫទ័យ ក៏កំពុងតែស្រឡាញ់ អាល័យសីលផ្នួសនោះ ពន់ប្រមាណ បើយើងនឹងអញ្ជើញព្រះអង្គនួ ឬ ព្រះអង្គចន្ទ ជាអានុជ អោយទទួល រាជសម្បត្តិនោះ ឃើញថាខុសនឹង ច្បាប់រាជសម្បត្តិ។ ដូច្នេះ គួរយើង អញ្ជើញសម្តេចព្រះឧទ័យ បរមរាជាមហាឧបរាជ វិញ ដ្បិតថា សម្តេចព្រះបិតុលា (មាខាងឪពុក) ធ្លាប់កាន់កាប់កិច្ចការរាជការមកស្រាប់។ ព្រះរាជបុត្រា ពីរព្រះអង្គ យល់នាម៉ឺនសព្វមុខមន្ត្រី គិតព្រមគ្នាដូច្នេះហើយ ក៏នាំគ្នា អញ្ជើញ ព្រះមហាឧបរាជ អោយឡើងគ្រងរាជសម្បត្តិបន្តពី សពព្រះជេដ្ឋាព្រះអង្គទៅ។ ព្រះឧទ័យយល់ព្រម តាមអង្គប្រជុំ នៅក្នុងបរិបទពិសេសមួយ តែពុំទទួលងារ ជាព្រះមហាក្សត្រនោះឡើយ ព្រោះ មិនចង់ក្បត់ព្រះរាជហឫទ័យ សពព្រះជេដ្ឋា ដែលបំរុងទុក រាជសម្បត្តិថ្វាយ ព្រះអង្គតូ។ ព្រះអង្គ គ្រាន់តែឡើងជា សម្តេចព្រះឧភយោរាជធំ ដើម្បីរក្សារាជសម្បត្តិទុកសិន ទម្រាំ សម្តេចព្រះអង្គតូ ចាកសិក្ខាបទមក។ ពេលវេលា កន្លងមកទៀត ព្រះអង្គតូ តែងតែ បដិសេធ ជាច្រើនដង ច្រើនគ្រានូវ ការអញ្ជើញទ្រង់ ពីសំណាក់ មន្ត្រីភិលៀង អោយ ចាកសិក្ខាបទ មកទទួលរាជសម្បត្តិ។ កាលព្រះបិតា គង់ព្រះជន្មាយុនៅឡើយ ទ្រង់បម្រុងទុកថ្វាយ ព្រះអង្គតូ នូវ បុត្រីម្តាយផ្សេងគ្នា ព្រះនាម ចន្ទវតី អោយធ្វើជាអគ្គមហេសី។

តែ អវត្តមាន ពន្យារ នៃ ព្រះអង្គតូ នៅក្នុង ព្រះរាជវាំង នាំអោយ ព្រះឧទ័យ ភ្លាត់ស្មារតីលួចស្រឡាញ់ ព្រះអង្គចន្ទវតី ហើយស្វែងរក គ្រប់មធ្យោបាយ ដើម្បី យកព្រះនាង ធ្វើជាព្រះទេពី ទោះបីដឹងថា សាមីខ្លួន គេប្រកែកដាច់អហង្ការ ក៏ដោយ។ តែ ការព្យាយាម លួចស្នេហា របស់ព្រះអង្គ ទទួលបាន នូវ ជ័យជំនះ ស្រេចដូចបំណងមែន។

ចំណែក ពួកមន្ត្រី ភិលៀង រាប់អាន ព្រះអង្គតូ ចេះតែនាំគ្នាទៅតឿនរំលឹកជារឿយៗ សូមអោយព្រះអង្គតូ ចាកសិក្ខាបទ ដោយលើកយករឿង ព្រះបិតុលាធិរាជ ស្តេចប្រលោម យកព្រះអង្គចន្ទវតី ជាគូផ្សំផ្គុំ របស់ព្រះអង្គតូស្រេចទៅហើយ។ តែ ទមិឡ (argument) មានប្រសិទ្ធិភាពខ្លាំង ដែលអាចធ្វើអោយព្រះអង្គតូ ទន់ព្រះទ័យ ដូរព្រះរាជហឫទ័យ សុំចាកសិក្ខាបទ គឺ ការប្រៀបធៀប នៃ ការពុំព្រម សឹក ទៅនឹង អកតញ្ញូធម៌ ចំពោះមាតា ព្រោះថា តើ ព្រះអង្គតូមាន អំណាចអ្វី នឹងថ្វាយមុខនាទីជា ព្រះវររាជមាតា (reine mère) ដល់ព្រះមាតាបាន ដែលព្រះនាវបំណាច់ ស្តេច លះបង់ស្រុកយួន មករស់នៅស្រុកខ្មែរ ឆ្ងាយពីគ្រួសារព្រះអង្គ។ សម្តេចព្រះមហាឧភយោរាជ ព្រះអង្គសុខចិត្ត ថ្វាយរាជ្យទៅព្រះអង្គតូ ដោយគ្មានសេចក្តីសាញបន្តិចបន្តួច នោះឡើយ។

ដូចនេះ ព្រះអង្គតូ ឡើងសោយរាជសម្បត្តិ នៅឆ្នាំ ១៦៣៦ ជ្រើសរើស ព្រះនាមរាជ្យ ព្រះស្រីធម្មរាជា (១៦៣៦-១៦៤០)។

ព្រះចៅថ្មី តែងតាំង ព្រះអនុជ ព្រះអង្គនូ ជា ឧបរាជ។ ដឹងដំណឹងល្អនេះ នាំអោយ ព្រះចៅក្រុងអណ្ណាមកុក មាន សេចក្តីរីករាយផង និង បារម្ភផង ព្រោះរយៈពេលខ្ចីដី ព្រៃនគរ វាចប់ស្រេចបាច់ទៅហើយ ដូច្នេះ ការប្តូរ រជ្ជកាល ថ្មី នៅស្រុកខ្មែរ វានឹងអាចនាំអោយមាន ការផ្លាស់ប្តូរ នៃ ការប្រាស័យទាក់ទង រវាង នគរ យួន នឹង ខ្មែរ។ ដូច្នេះ ព្រះ អង្គ ត្រូវចាំបាច់ ពង្រឹងអំណាចដ៏ខ្លាំងក្លា បុត្រីព្រះអង្គ គឺ ព្រះអង្គចូវ ដែលជាមាតា របស់ព្រះមហាក្សត្រថ្មីខ្មែរ។ ឈ្លា នឱកាស នៅពេលបុណ្យ រាជាពិសេក ព្រះអង្គតូ ដែលត្រូវ ជាចៅ របស់ព្រះអង្គ ទ្រង់ បញ្ជូន រេហ៍ពល ៥០០ នាក់ នាំ ព្រះរាជបណ្ណការ ទៅថ្វាយ ព្រះចៅខ្មែរ ហើយ ស្នើរសូមអោ យ រេហ៍ពល ទាំងនោះ នៅបំរើផ្ទាល់ នៅស្រុកខ្មែរតែម្តង ព្រះអង្គចូវ ដែលក្លាយ ជា ព្រះវររាជមាតា ព្រះសម្តេច ព្រះ ទាវធីតា មហារាជជននី ទេវីក្សត្រីបរមពិត្រ។ ទ័ពយួន នោះ ដឹកនាំដោយ មហាមន្ត្រីយួន ពីរនាក់ ហើយរាល់ឆ្នាំ តែងតែមាន រេហ៍ពលថ្មី មកផ្លាស់ប្តូរ ជានិច្ច។ ចាប់ពី ពេលនោះមកព្រះអង្គចូវមានអំណាចណាស់នៅស្រុកខ្មែរ។ ព្រះអង្គតែងតែ អោយរើសរកប្រុសៗ ចូលគាល់តាមវេន ជាអចិន្ត្រៃយ៍ តែមហាតលិកទាំងនោះ ពេលណា ស្តេចពុំ សូវគាប់ព្រះទ័យនោះ ស្តេចក៏ត្រាស់អោយបណ្តេញចេញ ឬ អោយសម្លាប់ចោល ដើម្បីបំបាត់មាត់។ ព្រះស្រីធម្មរាជា (តូ) ទ្រង់ជ្រាប នូវកិច្ចការអាថ៌កំបាំង របស់មាតា ហើយ

ទ្រង់ពុំ សព្វព្រះរាជហឫទ័យរឿងនេះ ទ្រង់ក្រែងរង្កៀសក្នុងចិត្តព្រះបិតុលា អំពីរឿងនេះ ដែលនាំអោយព្រះអង្គពុំចង់គង់នៅក្នុងក្រុងឧដុង្គមានជ័យ ជាមួយនឹងស្តេចទាំងពីរព្រះអង្គនេះឡើយ។ នៅឆ្នាំ ១៦៣៨ ព្រះអង្គសម្រេចចិត្តទៅសាងរាជធានីថ្មីនៅស្រុកទន្លធំ នៅកោះឃ្លោក (ក្នុងស្រុកខ្សាច់កណ្តាល)។ ព្រះស្រីធម្មរាជា មានប្រាជ្ញា ជាជំនាញ ខាងគតិលោក ស្លោក និង គតិធម៌ និង សិល្ប នៃកំណាព្យឃ្លោង និង សាស្ត្រាបាលី។ ព្រះអង្គ នេះហើយ ដែលជាអ្នកតែង ច្បាប់កុមារ កុមារី ច្បាប់ហៃសាធុជន អោយឈ្មោះហៅថា ច្បាប់ត្រៃនេត្រ។

នេះនឹងនិយាយ អំពី ព្រះអង្គចូវ ព្រះអង្គ មានកាមរោគកើត តម្រេកត្រេកត្រអាល ពន់ប្រមាណ។ ថ្ងៃមួយ ស្តេចយាងទៅប្រពាតព្រៃ ខណៈនោះ មានបុរសម្នាក់ ជាកូនពញាសេនាធិបតី ចៅហ្វាយស្រុកខេត្តបរិបូណ៌ ឈ្មោះ ពញាធំ កំពុងឡើងបេះផ្លែដូងផ្លែ ហើយរបូតសំពត់ លេចចេញប្រដាប់ខាងក្នុងវែង។ ព្រះអង្គចូវ ក្រឡេកឃើញ ក៏ពេញព្រះទ័យពេកណាស់។ លុះដល់ថ្ងៃល្ងាច បញ្ញាធំ ដឹងថា ព្រះវរោជមាតា យាងមកកំសាន្តព្រៃ នៅក្នុងស្រុកខ្លួន ហើយឃើញព្រះភក្ត្រព្រះអង្គ លួចមានចិត្តស្នេហា ចង់ជួបប្រតិព័ទ្ធនឹងព្រះអង្គចូវ ក៏ដើរបរបាញ់សត្វ ដើម្បី នាំសត្វនោះ ជាលេសទៅថ្វាយព្រះនាវ ដែលជាវិធវា (ស្ត្រីមេម៉ាយ)។ សម្តេចព្រះនាវ ឃើញបញ្ញាធំ មកដល់ហើយ ក៏នឹងឃើញ

ប្រដាប់វែង ក៏រឹតតែពេញប្រទ័យទាំងកាយា ស្នេហាណាស់។ ក្នុងរាត្រីនោះ ព្រះទាវធីតា ក៏អោយ ភិលៀង ទៅហៅ អទារជន (កម្លោះ) នេះ ចូលក្នុងវេនយាម រួមរ័ក្ស ហើយ ទ្រង់ស្កប់ស្កល់ ពេញព្រះទ័យ ពន់ប្រមាណ។ តាមប្រវត្តិសាស្ត្រ, ចាប់ពីថ្ងៃនោះមក ព្រះអង្គចូវ និង ពញាធំ រួមរស់ ជាគូសាងនឹងគ្នា ប្រកបដោយ សុភមង្គល រហូតទ្រង់ចូលទីវង្គតក្នុងព្រះជន្មាយុ ៦១ វស្សា។

និយាយពី ព្រះស្រីធម្មរាជា (តូ) នៅពេលចូលគាល់ ព្រះបិតុលា នៅក្រុងឧដុង្គមានជ័យ ទតឃើញ ព្រះអង្គចន្ទវតី ដែលធ្លាប់ជា គូទំនុកបម្រុង ទ្រង់ក៏នឹកភ្នក ព្រះរាជហឫទ័យស្នេហា ស្តាយអាល័យណាស់ នាំអោយភាំងភាន់ ព្រះស្មារតី ហើយពេលនោះ ព្រះអង្គចន្ទវតី ក៏បញ្ចេញ អាការមេត្រីស្នេហាទៅវិញដែរ។ អាកប្បកិរិយា ស្នេហាទៅវិញទៅមកនេះ នាំអោយ សាវឡឹក ពីរនាក់ ឈ្មោះ ចាន់ និង ចម[47] របស់ព្រះអង្គចន្ទវតី ចាប់អារម្មណ៍ ជឿជាក់ថា ព្រះអង្គទាំងពីរ មានបំណង ចង់ភ្ជាប់មេត្រីនឹងគ្នាណាស់។ នាងទាំងពីរ ក៏មានគ្រោងការណ៍ អប្បល័ក្ខណ៍ ដើម្បី ទាញយករង្វាន់ ពីព្រះរាជា ជួយនាំការណ៍ព្រះអង្គទាំងពីរ អោយបានសម្រេចគោលបំណងស្នេហា។ ព្រះអង្គតូ ក៏ចាប់អោ

47 នាង ចាន់ និង ចម ធ្លាប់បានជួយយករង្វាន់ ព្រះមហាឧកយោរាជ (ឧទ័យ) យក ព្រះអង្គចន្ទវតី ធ្វើជាព្រះទេពី កាលពីព្រះអង្គតូ ពុំទាន់ចាកសិក្ខាបទ។

យត្រៀមទាហាន និង គ្រឿងសស្រ្តាវុធ អោយបានស្រេច ព្រោះ យល់ដឹងថា បើដណ្តើម ព្រះចន្ទវតី ពី ព្រះបិតុលា នឹងមានសង្គ្រាមជាពុំខាន។ រីឯ ព្រះអង្គចន្ទវតី ខំរកកល ឧបាយគ្រប់បែបយ៉ាង ដើម្បី រត់ចេញពីក្រុងឧជ្ជេនី មក រស់នៅជាមួយ ព្រះគូស្នេហ៍។ ដោយមានជំនួយពី នាង ចា ន់ និង ចម ព្រះអង្គ បោះបង់សីល៥ សីល៨ រត់ចោលស្វាមី មកក្រុងឃ្លោក ដើម្បី មកជួបគូស្នេហា។ ព្រះឧទ័យ ទ្រង់ ជ្រាបរឿងអាស្រូវនេះ ទ្រង់បញ្ជាអោយ លើកទ័ព ដែលជា ពលទាហាន របស់ជនព័រទុយហ្គេស៍ ទៅច្បាំងនឹង ក្តួយតូ ព្រោះ ព្រះរាជានេះ ហ៊ានលួចព្រះទេពី របស់ព្រះអង្គ។ រីឯ ពលទ័ព របស់ហ្លួងរាជ្យ វិញ ដឹកនាំដោយ នាយទាហាន ចិនបួនរូប។ ទ័ព របស់ព្រះរាជា ច្បាំងចាញ់ ទ័ព ព្រះមហា ឧភយោរាជ ពេលនោះ ព្រះអង្គតូ ក៏រត់ចោលព្រះអង្គចន្ទវ តី ទៅតាមទន្លេធំ។ ទាហាន របស់ លោក កាឡាទីយោ (ឈ្មោះ ព័រទុយហ្គេស៍) និង ទាហាន ២៤នាក់ ដេញតាម ជាប់ ហើយ បាញ់ព្រះអង្គស្លាប់ នៅពេលដែលទ្រង់ទៅពួន លើដើមត្នោត។ រីឯ ព្រះអង្គចន្ទវតី និង សាវឡឹក នាងចា ន់ និង ចម ត្រូវ តុលាការសឹក កាន់ទោសប្រហាជីវិត តាម ច្បាប់។

ព្រះឧភយោរាជា ឧទ័យ បន្ទាប់ពី បានឈ្នះសង្គ្រាមនឹង ព្រះអង្គតូ ហើយ ស្តេចចាញ់សង្គ្រាមនេះ ក៏សុគត់ទៅ ទ្រង់ ស្មើដល់ ព្រះរាជវង្សានុវង្ស និង អង្គអគ្គសេវកា សេនាបតី

អោយ ព្រះអង្គនូ ជា ព្រះអនុជ របស់ព្រះអង្គតូ អោយឡើងគ្រោងរាជសម្បត្តិ បន្តពីព្រះជេដ្ឋា។ ដូច្នេះ ព្រះអង្គនូបានឡើងសោយរាជ្យ នៅឆ្នាំ ១៦៥៦ មានព្រះនាមរាជ្យព្រះរាមាធិបតី។ នៅក្នុងរជ្ជកាល របស់ព្រះអង្គនូ ទ្រង់ជាប់ប្រទះនឹង រាស្ត្រពីរនាក់ ឈ្មោះ រ័ត និង ពេជតែងតាំងខ្លួន ជាស្តេចឈ្មោះ បល្ល័ង្ករ័ត និង បល្ល័ង្កពេជ។ឧទ្ទាម ទាំងពីរ បានសង្កត់ខេត្ត សំរោងទង និង លង្វែកថែមទាំងបានសម្លាប់ចៅហ្វាយខេត្តទាំងពីរនោះទៀត។
បន្ទាប់ពីសេនាបតី ទូលថ្វាយព្រឹត្តិការណ៍ ដល់ព្រះរាជានូព្រះអង្គ បានចាត់តាំង ព្រះអនុជពៅ គឺ ព្រះអង្គចន្ទ ជាមេទ័ព នាំរេហ៍ពលចេញទៅកម្ចាត់សត្រូវរាជ្យ ជាប្រយាប់។ព្រះអង្គនេះ បានរៀនចេះស្ទាត់ ព្រះកម្មដ្ឋាន និង ហាត់ថ្មីក នូវ ក្បួនពិជ័យសង្គ្រាម អាចទុកជា វិភារី (អ្នកចេះប្រាកដ)។ ក្នុងប្រវត្តិសាស្ត្រ គេស្គាល់ព្រះអង្គ ក្នុងបរមនាមផ្សេងមួយទៀត ថា ព្រះសត្ថា។ ព្រះអង្គ បង្ក្រាប ពួកឧទ្ទាមបានដូចប្រថ្នា ហើយត្រាស់ អោយប្រហារជីវិត មួយរំពេញ មេពួកវា ទាំងទ្វេ ហើយ ចាប់អស់ ញាតិកាសាលោហិត មកដាក់ ជាពល សម្រាប់ព្រះស្រីរតនត្រ័យ។
បន្ទាប់ពីនគរមានស្ថិរភាពនយោបាយវិញ នៅឆ្នាំ ១៦៤៩ព្រះរាមាធិបតី(នូ) មានបំណងនឹងទាមទារ ខេត្តព្រៃនគរដែលបិតារបស់អង្គ កាលនៅមានព្រះជន្ម អោយព្រះចៅក្រុងអណ្ណាមកុកខ្ចី ក្នុងរយ់ពេល៥ឆ្នាំ ហើយរយៈពេលនោះ

វាហួសសន្សា ច្រើនមកហើយ តែបំណងនេះ ត្រូវសម្តេចព្រះទាវធីតាចូវ ជាមាតាចុង របស់ព្រះអង្គ សុំអង្វរកុំអាលធ្វើសិន ព្រោះ ស្រុកយួន នឹង ចិន នៅមានកើតសង្រ្គាមនឹងគ្នានៅឡើយ។ ព្រះអង្គចូវ សូមធានា យកជីវិតថ្វាយ បើសិនជា បិតា របស់ព្រះអង្គ (ព្រះចៅអណ្តាមកុក) មិនប្រគល់ ព្រៃនគរ មកអោយស្រុកខ្មែរវិញ ដោយប្រការដូចម្តេចក៏ដោយ។ ព្រះចៅនូ ឮសំដីព្រះទាវចូវហើយ ក៏ទ្រង់សណ្ឋិតនៅស្ងៀមទៅ ដ្បិត ញញើត នូវ អំណាច ព្រះទាវចូវនៅក្នុងក្រុងឧដុង្គ ដែលមានទាហានយួន ៥០០ នាក់ការពារ ជាអចិន្រ្តៃយ៍។ ព្រះរាជានូ ចម្រើនជន្មបាន ២៧ឆ្នាំ គម្រប់រាជ្យបាន ៥ឆ្នាំ ទ្រង់ប្រឈួន ជាទម្ងន់ ក៏សុគតទៅ។ សម្តេចព្រះឧទ័យបរមរាជា កោះប្រជុំ ព្រះរាជវង្សានុវង្ស និង អង្គអគ្គសេវកា សេនាបតី ជុំនំព្រឹក្សារាជសម្បត្តិលើកព្រះអង្គនន្ទ ជាព្រះរាជបុត្រាច្បង របស់ ព្រះឧទ័យមហាឧភយោរាជា អោយឡើង គ្រងរាជសម្បត្តិ បន្តពីមតក (défunt) ព្រះរាជានូ ជំនួស ព្រះអង្គចន្ទ ឬ សត្ថាដែលជា វង្សបន្តរាជ្យ។ ការណ៏នេះ នាំអោយ ព្រះអង្គចន្ទតូចព្រះទ័យណាស់ ហើយ ទ្រង់ មានក្តីពិរោធ ពេកពន់ប្រមាណណាស់។ ទ្រង់តាំងចិត្តនឹង យករាជ្យ ដែលជារបស់ទ្រង់ ដោយសិទ្ធិ អោយបានជាដាច់ខាត។ ព្រះអង្គរៀបផែនការកលល្បិច ជាសម្ងាត់ ជាមួយមន្ត្រី និង សេនាឯកដែលស្មោះនឹងព្រះអង្គ អស់រយៈពេល ៣ឆ្នាំ។ លុះមាន ខិ

កាសជាទំនួលហើយ វេលាយប់អធ្រាត្រស្ងាត់ ព្រះអង្គចន្ទ អោយសេនា ទៅលុកចូលក្នុងព្រះរាជវាំង ធ្វើគត់ព្រះមហាឧភយោរាជា (មានព្រះជន្ម ៥៣ឆ្នាំ) និង ព្រះហ្លួងទ្រង់រាជ្ជ (មានព្រះជន្ម ២២ឆ្នាំ) បានសំរេចដូចប្រាថ្នា។ ព្រឹកឡើង ព្រះអង្គចន្ទ កោះប្រជុំ ព្រះរាជវង្សានុវង្ស និង អង្គអគ្គសេវកា សេនាបតី ដើម្បី ប្រាប់ពីហេតុផល ដែលទ្រង់ធ្វើឃាត ព្រះបិតុលា និង ព្រះអង្គនន្ទ ថា ព្រោះ ព្រះអង្គទាំងពីរ បំពានច្បាប់រាជសម្បត្តិ លើ ព្រះរាជានុសិទ្ធិ គឺ ព្រះអង្គ ដែលជាក្សត្រ ត្រូវស្នងរាជ្យបន្តពី មតកព្រះជេដ្ឋាន្ទ។ ស្ដេចមានតម្រាស់ត្រាស់ ចប់សព្វគ្រប់ហើយ ទ្រង់សួរ ទៅអង្គប្រជុំថា : រាជសម្បត្តិនេះ ត្រូវបានទៅនរណា ? ដោយភ័យខ្លាច អំណាចព្រះអង្គចន្ទ ដែលមាន សេនា ប្រដាប់គ្រប់អាវុធសឹក ឈរអម អង្គប្រជុំ ក៏នាំគ្នាឆ្លើយថា ព្រះអង្គនេះឯង ជាស្ដេច ត្រូវបានបន្តសោយរាជសម្បត្តិ ពេញច្បាប់ តាំងពី មតកព្រះរាជាន្ទ មកម្លេះ។ ដូច្នេះឯង ព្រះអង្គចន្ទ ឬ សត្ថា ឡើង ប្រាប្ដាភិសេក ជា ឯកឧត្ដិយាមហាក្សត្រ នៅឆ្នាំ ១៦៥៣ ក្នុង ព្រះជន្មាយុ ២៣ ឆ្នាំ។ ដូច មតកព្រះជេដ្ឋន្ទដែរ ព្រះរាជាចន្ទ មានបំណង ទាមទារខេត្តព្រៃនគរពី ព្រះចៅអណ្ណាអកុកវិញ តែលើកនេះ ព្រះទាវធីតាច្ងវ សូមអង្វរជាថ្មី ថា សូមទុកព្រៃនគរ អោយយួនសំណាក់អាស្រ័យសិន គ្រាន់ទុក ចំណែកដាច់មុខ ឬ សួយ (apanage) របស់ទ្រង់ ទម្រាំទ្រង់អស់ជីវិត ដោយប្ដូរនឹង

សួយខេត្ត៥ ដែលជា ចំណែកដាច់មុខ របស់ទ្រង់សព្វថ្ងៃ ថ្វាយជូនព្រះរាជា ជាអម្ចាស់ជីវិតលើត្បូង ពោលថា ព្រះទាវច្ចូវ សូមថ្វាយសួយ សម្រាប់ព្រះអង្គ ទាំង៥ខែត្រ ទៅព្រះឃ្លាំងហ្លួង ហើយព្រះទាវ ទុកតែ ព្រះសួយ ខែត្រព្រៃនគរ តែមួយគត់ រហូតដល់ស្លាប់។ សំណើរនេះ ធ្វើអោយ ព្រះអង្គចន្ទទញ់ទល់ ក៏បង្អង់សេចក្តី ដែលនឹងត្រូវ តឹងទារនោះរៀងមក។ ក្រោយបន្តិចមក ព្រះទាវជីតាច្ចូវ សូមអនុញ្ញាត ពីព្រះរាជា យាងទៅគង់នៅ ស្រុកភ្នំពេញ ដោយនាំ ព្រះអង្គសួ និង តន់ ដែល ជាបុត្រា សពព្រះឧភយោរាជាឧទ័យ ទៅជាមួយផង។ ព្រះអង្គចន្ទ មិនហ៊ានរឹកទទឹងនឹងព្រះសវនីយ៍ ព្រះទាវច្ចូវឡើយ ដោយតបឆ្លើយថា : សូមស្តេចយាងតាមសព្វព្រះរាជហឫទ័យចុះ។

ថ្ងៃមួយ ព្រះរាជា អង្គចន្ទ (សត្ថា) ទ្រង់ភ្នកព្រះរាជហឫទ័យចង់យាងក្រសាលសប្បាយ នៅស្រុកទន្លេធំ។ ពេលត្រឡប់យាងចូលក្រុងឧដុង្គវិញ លុះយាងមកដល់ភូមិកំពង់លួងតាមដងទន្លេ ព្រះអង្គទតឃើញ ស្ត្រីចាមម្នាក់កំពុងដួតទឹក មានរូបរាងល្អ ទាំងឫកកិរិយា ក៏ឆើតឆាយ ល្អទៀត។ ព្រះអង្គលួចប្រតិព័ន្ធស្រីល្អនេះណាស់ ទ្រង់ត្រាស់អោយហៅពួក ចៅថៃ ‹ព្រះវង្សស្តេចចាម› មកសួរ ហើយឲជួយចូលថៃចូវ មាតា-បិតា កញ្ញាស្នេហ៍ ឈ្មោះ នាង វ៉ះ មកធ្វើជាព្រះស្នំ។ មាតា-បិតា កញ្ញា វ៉ះ ដាក់លក្ខខណ្ឌ ដល់ព្រះរាជាថា បើព្រះអង្គសុខចិត្តចូលសាសន៏ចាម ទើបអាចថ្វាយ

បាន។ ហេតុតែ ស្រឡាញ់ក្នុងចិន្ដា ហើយ ចង់ សេវនៈ[48] នាងវ៉ះ ព្រះរាជា យល់ព្រមតាមលក្ខខណ្ឌ ដោយគិតថា នឹងបានពួកចាមជ្វា ធ្វើជាសម្ពន្ធមិត្ត ទុកជា កម្លាំងទ័ពបម្រុង ការពារព្រះរាជបល្ល័ង ទល់នឹង គ្រប់ការបះបោរ ជាពិសេស ពីសំណាក់ បុត្រ សព្វព្រះបិតុលាឱទ័យ។ លេសមួយទៀត ថា ព្រះអង្គ អាចលាងបាបបាន ដ្បិត តាមធម៌ ព្រះមហាហ្ម័ត បើនរណា បានចូលសាសនាគាប់គុណហើយ ព្រះមហាហ្ម័ត ទទួលជួយបានទាំងអស់ ពុំឲជនទាំងឡាយដែលជា សទ្ធិវិហារិកនោះ មានបាប មានទោសឡើយ ដូចយ៉ាង ព្រះអង្គបានធ្វើឃាត ព្រះបិតុលា និង ព្រះរាជានន្ទ។ លេសនេះ វាត្រូវឱកាស ចំពោះករណី របស់ព្រអង្គចន្ទ ជាងធម៌ ព្រះពុទ្ធសាសនា។ តាមការពន្យល់ របស់សម្ដេចព្រះសុគន្ធា សង្ឃរាជា ដល់ព្រះអង្គថា : ‹*បុណ្យ និង បាប មានតែដោយចំណែកពីគ្នា, ថាបើទ្រង់បានធ្វើបុណ្យច្រើន គទៅនឹងបាន សោយសុខជាមុន បើទ្រង់បានធ្វើបាបច្រើនទ្រង់ ទៅសោយទុក្ខ ជាមុនប៉ុណ្ណោះ គ្មានក្នុងព្រះពុទ្ធប្បញ្ញតិ ឬ ពុទ្ធនុញ្ញាត ឲកាត់កងសងគ្នា នោះឡើយ*›។

ក្រោយពីព្រះអង្គចន្ទ បានចូលសាសនាព្រះមហាហ្ម័តមកទ្រង់ លើកពួកចាមជ្វា ដែលជាញាតិនឹងព្រះស្នំឯកវ៉ះ ទាំងប៉ុន្មាន ជាមន្ត្រីទាំងអស់ ហើយបើ នាម៉ឺនខ្មែរណា ចង់ឡើងបុណ្យសក្ត័ រហ័សតាមបំណង ត្រូវនាំគ្នាចូលសាសនា

48 សេវនៈ ឬ សេវនា : ការសេពគប។

ព្រះមហាហ្ស៊ុត។ អំពើផ្ដេសផ្ដាសនោះ នាំឲមន្ត្រី និង ប្រជារាស្ត្រខ្មែរជាច្រើន មាន បដិយៈ[49] ពេញផ្ទៃនគរ។ ស្ថានការណ៍នេះ ជា លាភជ័យ ដល់ ព្រះ អង្គ សូ និង តន់ ដែលជា ព្រះបុត្រ សពព្រះឧភយោរាជាឱទ័យ ត្រូវព្រះអង្គចន្ទធ្វើឃាត។ ព្រះអង្គទាំងពី បានទៅរស់នៅ នៅស្រុកភ្នំពេញ ជាមួយព្រះទាវធីតាចូវ ក៏បញ្ជាជាសម្ងាត់ ឲមន្ត្រីខ្លួន ទៅបញ្ចុះបញ្ចូលរាស្ត្រខាងកើត តាំងពីខេត្តស្រីសន្ធទៅត្បូង បានជាច្រើន, រៀបចំជាកងទ័ព, បោះបន្ទាយជ័យ នៅក្នុងខេត្តសំរោងទងមួយ និង នៅព្រែកព្នៅមួយទៀត នៅឆ្នាំ ១៦៥៧។ ដូចនេះ ស្ដេចទាំងពីរព្រះអង្គ ស្នើសូមឲ ព្រះទាវធីតាចូវ សូមជំនួយកងទ័ព ពី ព្រះចៅក្រុងហ្វេ ដើម្បីពង្រឹងកម្លាំង តទល់នឹង ព្រះចៅក្រុងឧដុង្គ។ ព្រះចៅក្រុងហ្វេ យល់ព្រមតាមសំណើរ បានបញ្ជូន ទ័ព មានសេនាទាហាន ៥.000 នាក់ ដឹងនាំដោយ មេទ័ពយួនឈ្មោះ អុងភូបៀ លើកមកស្រុកភ្នំពេញ ដើម្បីជួយ ព្រះអង្គសូ និង តន់។ ចំណែក ព្រះចៅខ្មែរ ដឹងដំណឹងនោះភ្លាម ក៏ប្រញាប់ រៀបទ័ព ចាម-ខ្មែរ ដើម្បី ប្រាបប្រាម ទ័ពក្បត់នឹងព្រះអង្គ។ ពួកសេនាបតីខ្មែរ មិនសូវ មានទឹកចិត្តខ្លាំងក្លា ចង់ជួយ ព្រះអង្គចន្ទ ដោយហេតុថា ទ្រង់បោះបង់ពុទ្ធសាសនា និង លើកដំកើង ពួកចាមឲមានអំណាច កំហែងគម្រាម លើមន្ត្រីខ្មែរ។ ព្រះអង្គចន្ទ តាំង

49 បដិយៈ : មិនសប្បាយចិត្ត និង ខឹងផង។

ព្រះអង្គអិម ដែលជាព្រះរាជបុត្រ មួយអង្គដែរ របស់ព្រះឱទ័យ ជាមេទ័ពមុខ ឯចំណែងព្រះអង្គ ទ្រង់ដឹកនាំផ្ទាល់ទ័ពហ្លួង ដែលមានទាហាន សុទ្ធតែជនជាតិចាម។ ដោយគ្មានការគាំទ្រពេញទំហឹង ពី មន្ត្រីខ្មែរ នូវរេហ៍ពល មិនតែប៉ុណ្ណោះ នាំគ្នារត់ចោលទ័ពថែមទៀត។ ការណ៍នេះ នាំឲព្រះអង្គចន្ទ ចាញ់សង្គ្រាម ហើយត្រូវយួន ចាប់ខ្លួនព្រះអង្គបានទៀត។ ឯចំណែក ព្រះអង្គអិម វិញ ទ្រង់បានស្លាប់ក្នុងសមរភូមិ ក្នុងជន្មាយុ ២៩ឆ្នាំ។ ទ្រង់ត្រូវទ័ពយួន បាញ់ធ្លាក់ទឹក ហើយរកសព ពុំឃើញឡើយ។ មេទ័ពយួន អុងភូបៀ កាលចាប់ព្រះអង្គទ្រង់រាជ្យខ្មែរបាន មិនបញ្ជូន ទៅឲព្រះអង្គសូ និង តន់ បែរជាយកទ្រង់ ទៅដាក់ក្នុងទ្រុងដែក រួចបញ្ជូន ទៅស្រុកយួនតែម្តង។ ព្រះអង្គសូ ដឹងដំណឹងនេះកាលណា នាំឲទ្រង់គ្នាន់ខ្នាញ់ ក្នុងព្រះហឫទ័យព្រោះ ទ្រង់យល់ឃើញថា យួន ប្រមាថមើលងាយព្រះអង្គដូច្នេះ ច្បាស់ជាយួនមានបំណងអ្វីអាក្រក់បន្តទៀតជាពុំខាន។ ព្រះអង្គ រៀបជើងព្រួល ទុកជាមុន ដោយមិនអោយ ព្រះទាវធីតាចូវ ដឹងផែនការណ៍ របស់ទ្រង់។ រួចស្រេចហើយ ព្រះអង្គសូ និង តន់ លើកទ័ពចេញពីភ្នំពេញ ដោយនាំ ព្រះទាវចូវ ទៅជាមួយ ឆ្ពោះទៅភ្នំពេញយ៉ាងប្រយាប់ដើម្បី បង្រួបបង្រួម ទ័ពព្រះអង្គ ជាមួយ ទ័ពខ្មែរ នៅក្រុងឧដុង្គ។ អស់នាម៉ឺនសព្វមុខមន្ត្រី និង អាណាប្រជានុរាស្ត្រ នៅឧដុង្គ នាំគ្នាមកចុះចូលព្រះអង្គទាំងពីរ ជាច្រើ

ន។ តាមពិត អុងភូបៀ មានគំរោង ចាប់ ស្តេចខ្មែរ ទាំងពីរ យកទៅស្រុកយួនមែន ហើយ វាយយកស្រុកខ្មែរ ដាក់ជា នគរចំណុះយួនតែម្តង។ បានដំណឹង ថា ព្រះអង្គសូ និង តន់ យាងទៅក្រុងឧដុង្គបាត់ហើយ គាត់ ក៏ខំរកល្បិច ចូលចាប់ ស្តេចខ្មែរ នៅទីនោះតែម្តង តែស្រកោក (en vain) ក៏សម្រេចចិត្ត លើកទ័ពវាយ បន្ទាយរាជធានីខ្មែរតែម្តង។ ខណៈនោះ ខ្មែរមានសាមគ្គីភាព ចេញច្បាំងតទល់នឹងទ័ពយួន វាយបែកទ័ពយួនខ្ចាត់ខ្ចាយ នាំគ្នារត់ទៅស្រុកយួនវិញអស់ ដោយនាំព្រះអង្គចន្ទ ទៅជាមួយផង។ អុងភូបៀ ចូលគាល់ ព្រះចៅអណ្ណាមកុក រៀបរាប់ អំពីដំណើរ នៃ ព្រឹត្តិការណ៍ ក្រលៃយករូបខ្លួន អំពីបរាជ័យរបស់ខ្លួន។ ព្រះចៅអណ្ណាមកុក អោយដោះលែងព្រះអង្គចន្ទ ហើយ អោយនាំទ្រង់ទៅស្រុកខ្មែរវិញ។ មានព្រះហទ័យបែបនេះ ប្រហែលជាព្រះអង្គ យល់ថា បុត្រី របស់ព្រះអង្គព្រះនាងចូវ ជាប់នៅស្រុកខ្មែរ នៅឡើយ ដូច្នេះ បើប្រគល់ព្រះអង្គចន្ទ ទៅឲព្រះអង្គសូ និង តន់ វាមានប្រយោជន៏ដល់ ព្រះនាងចូវ នៅវិញទេ ព្រោះ ខ្មែរអាចយល់ឃើញថានគរយួន មិនចង់ប្តូរ ការចងស្ពានមេត្រី រវាងនគរទាំងពីរ ទេ។ លុះទាហានយួន ជូនដំណើរ ព្រះអង្គចន្ទ ត្រឡប់មកស្រុកខ្មែរវិញ មកដល់ពាក់កណ្តាលផ្លូវ ទ្រង់មានកើតអហិវាតរោគ (រោគបណ្តាលឲច្មេះផង ក្អួតផង) ជាទម្ងន់

ទ្រង់សុគតអស់ព្រះជន្ម នៅស្រុក បត់ដញ្ជៀន ក្នុងព្រះជន្ម ៤១ឆ្នាំ ក្រោយពីបានសោយរាជ្យបាន ១៨ឆ្នាំ។

ព្រះអង្គសូ ឡើងគ្រោងរាជសម្បត្តិ បន្តពី ព្រះអង្គចន្ទ នៅឆ្នាំ ១៦៥៦ ក្នុងព្រះជន្មាយុ ២៩ឆ្នាំ។ ស្តេចទ្រង់សោយរាជសម្បត្តិបាន ១៦ឆ្នាំ ត្រូវបាន ព្រះរាជសុណិសា (កូនប្រសា) ធ្វើឃាតព្រះអង្គ ក្នុងជន្មាយុ ៤៤ឆ្នាំ ដើម្បី ដណ្តើមរាជ្យ។ ព្រះអង្គនេះ ព្រះនាម បទុមរាជា ជា ព្រះរាជបុត្រ មតក ក្សត្រនន្ទ ។ ព្រះអង្គគន់ ជា ឧភយោរាជា ទ្រង់លបយាងទៅស្រុកយួន ដើម្បី គេចពីរាជភ័យ បន្ទាប់ពីដឹងថា ព្រះបទុមរាជា សម្លាប់ព្រះរាជាសូ ជា ព្រះជេដ្ឋា របស់ព្រះអង្គ។

ព្រះបទុមរាជា ឡើងសោយរាជសម្បត្តិ បន្តពី ព្រះអង្គសូ នៅឆ្នាំ ១៦៧១ ក្នុងព្រះជន្មាយុ ៣៥ ឆ្នាំ។

ព្រះបទុមរាជា ទ្រង់សោយរាជសម្បត្តិបានតែមួយឆ្នាំ ត្រូវបាន ព្រះចមក្សត្រី ដែលជាអគ្គមហេសីស្តាំ របស់ព្រះអង្គ (ក្សត្រីនេះ ជា អតិតអគ្គមហេសី មតកហ្លួងសូ ដែល ព្រះបទុមរាជាធ្វើគតព្រះអង្គ) ចូលដៃជាមួយមន្ត្រីចាម លបលុកធ្វើគតព្រះអង្គ។ ដូចនេះ ទើប សេនាបតី មន្ត្រីរាជការ ទាំងពួង ប្រឹក្សាជំនុំ ព្រមថ្វាយរាជសម្បត្តិ ទៅសម្តេចព្រះកែវហ្វា[50] អង្គជី ដែលជាព្រះរាជបុត្រ មតកព្រះរាជាសូ។

[50] ព្រះកែវហ្វា : បរមងារ បន្ទាប់ពី ព្រះឧបរាជ។

មកដល់ត្រឹមនេះ យើងបិទវង់ក្រចក នូវ ការថ្លែងអន្លើៗ ខ្លះ អំពី ព្រឹត្តិការណ៏ នៃ រាជឃាត មាននៅក្នុង រាជវង្សានុវង្សខ្មែរ នៅ សតវត្ស ទី១៧ ដែលជា សតវត្សល្អចំពោះយួន ហុចឱកាសឲយួន ផ្តើមលុកលុយចូលស្រុកខ្មែរ ពី ទឹកដីព្រៃនគរ រួច រុលចុះបន្តៗជានិច្ច មកទិសខាងត្បូង។ បើមានឱកាសនៅថ្ងៃមុខ យើងនឹង សាកល្បង សរសេរ ជាវិភាគ ផ្តល់យោបល់ យ៉ាងពិស្តា អំពី សម័យ យួន យកព្រៃនគរ រហូតមកដល់ កាលសម័យ របស់មេទ័ពយួនឈ្មោះ ទៀង មិញយ៉ាង មកត្រួតត្រា ផ្ទាល់នៅស្រុកខ្មែរ ធ្វើនយោបាយ បង្ខំជនខ្មែរ អោយ រស់នៅ ក្នុង វប្បធម៏យួន។

អកុលខ្មែរ នៅចំពោះ វប្បធម៏យួន មានជម្រៅជ្រៅ ចាក់ជាឫសកែវ ជា ប្រភពអកុសល ចិញ្ចឹម នូវ អកុសល រាប់សតវត្សរ៏ មកហើយ។ គុណសម្បត្តិ ដែលខ្មែរ ធ្លាប់មាន នៅសម័យ មហានគរ វាមិនអាចយកធ្វើ ជាចម្លើយវិជ្ជមាននៅចំពោះមុខ វប្បធម៏យួន ឈានមុខជានិច្ច។ នៅពេលណា ខ្មែរ រស់ទទ្រម ម្តងៗ នៅចំពោះមុខវប្បធម៏យួន គឺជាដំណើរ ឥតអាចស្រោចស្រង់វិញបាននោះឡើយ។ ដូច្នេះកំហុសខ្មែរ គឺជា ប្រយោជន៏យួន ជានិច្ច។ ដូចនេះ ខ្មែរតែងតែខឹងនឹងយួន ទុកជា អ្នកឆ្លៀត, តែខ្មែរ មិនដែលខិតខំ ពិចារណា អំពី មូលហេតុ នៃ កំហុស របស់ខ្លួន ដែលអាចឲយួន ឆ្លៀតទាញគុណប្រយោជន៏ពីខ្លួននោះទេ។ អ្វីដែលជា ការរិះគន់ ដល់ខ្លួន ខ្មែរ ទុកវាជា ការមាក់ងាយ ឬ

ឈ្លានពាន ដល់ខ្លួន ឬ អាចទុក ជាក្បត់ជាតិតែម្តង បើរិះគន់ អ្នកដឹកនាំជាតិ។ ដូច្នេះ ការរិះគន់ ជា ទោស ដូចមានចែង នៅក្នុងច្បាប់ រាជនេតិ ថា : ‹*ទោសកើតដ្បិតពោល លួមមាត់*[51] *ឈ្លានពាន*›។ ដូច្នេះ ដើម្បី រស់បានសុខ គឺ ត្រូវ តែរស់នៅក្នុងផ្នត់ដំបូន្មានផ្សេងៗ ដូចយ៉ាង : *ចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស; ខ្លួនទាបកុំគោង ដៃខ្លីកុំឈោង ស្រវាអោបភ្នំ*។

គំនិតនេះ ជាពុម្ព នៃ ការអប់រំ បណ្ឌារាស្ត្រខ្មែរ នៅសម័យសក្តិភូមិ ដែលអ្នកដឹកនាំ គេយកមកធ្វើជា វប្បធម៌ នៃ ការដឹកនាំជាតិ ផ្ទុយពីវប្បធម៌យួន ផ្អែកទៅលើ កុងជឺនិយម ដែលយើង បានរៀបរាប់នៅខាងលើ។

វប្បធម៌ នៃ ការដឹកនាំ និង វប្បធម៌នយោបាយខ្មែរ ជាវប្បធម៌សក្តិភូមិ។ កាលសម័យ មហានគរ សក្តិភូមិនិយម វាអាចជា ចលករ នៃ ឯកភាពជាតិ ព្រោះអំណាចមជ្ឈឹមត្រូវការ អំណាចពួកស្តេចត្រាញ់[52] សំរាប់ ទូទ័រ អំណាចខ្លួនសព្វទិសទី នៅក្នុងនគរ។ អំណាចមជ្ឈឹមខ្មែរ ជារបបដឹកនាំបែប ស្តេច- អាទិទេព។ ដូចនេះ ការគោរព មហាក្សត្រ គឺជា ការគោរព អាទិទេព សុទ្ធសាធ ពោលថា អត្តភាព នៃ អាទិទេព ជា សច្ចៈភាព (vérité) ឬ ភារៈ អាស្រ័យហេតុ (raison d’être) នៃ អំណាច របស់ព្រះរាជា តែម្តង។

51 លួមមាត់ មានន័យថា ដែលចេះតែរអិលមាត់ថាទៅ។
52 ពួកស្តេចត្រាញ់ ; les seigneurs locaux។

ពិតប្រាកដណាស់ ថា ការបង្កើត ទ្រឹស្ដី ស្ដេច- អាទិទេព នៅសម័យកាលនោះ ជា ការបង្កើតមួយ ជាវិជ្ជមាន ព្រោះ សង្គមខ្មែរ ត្រូវចាំបាច់មាន រចនាសម្ព័ន្ធ នៃ គំនិតដឹកនាំ មជ្ឈិម ដើម្បី ឲ ប្រជារាស្ត្រ គោរព នូវ សណ្ដាប់ធ្នាប់សង្គម តែមួយ។ គឺថា នៅក្នុងលក្ខខណ្ឌតែមួយនេះឯង ដែលជា ដំណើរ នៃ ប្រជាជាតិខ្មែរ អាចបង្កើតបាន នូវ អរិយធម៌ ដ៏ខ្ពង់ខ្ពស់។ ទោះបីខុសពី ចំណង់ចំណូលចិត្ត យ៉ាងណាក្ដី គេទុក អរិយធម៌រុងរឿងនោះ ជាស្នាដៃ នៃ មហាក្សត្រ និង វេជី[53]ខ្មែរ ទាំងឡាយ នៅសម័យនោះ ព្រោះ ប្រជារាស្ត្រ ពុំអាច ទទួលរ៉ាប់រង នូវ មុខការ នៃ នយោបាយដឹកនាំ ជាតិបាន ដ្បិតកំរិត នៃ ការចេះដឹង នៅមានឋានៈទាប នៅឡើយ ទាំង ការចេះដឹងជាទូទៅ និង នយសាស្ត្រ[54]។ ដូច្នេះ វណ្ណៈក្សត្រ និង វណ្ណៈព្រាហ្មណ៍ មានតួនាទី ផ្ដាច់មុខ ជា ថ្នាក់អ្នកដឹកនាំជាតិ ដែលចេះដឹង នោះឯង។ តែចាប់ ពីសតវត្សរ៍ទី១៤មក ប្រជាជាតិខ្មែរ ជួបប្រទះនឹង វិបត្តិ នយោបាយ ជាច្រើន នៅក្នុង ថ្នាក់អ្នកដឹងនាំ ដែលនាំឲរ អឺលបន្ថិចម្ដងៗ ទៅក្នុង អត្តង្គត។ ហើយ ការទង្គិចនឹង បរាជ័យ[55] នៅចំពោះមុខ ប្រទេសជិតខាង មាន សៀម និង យួន គ្រាន់តែជា ការរុញបន្ថែម នូវ អត្តង្គតខ្មែរ

[53] ពាក្យ វេជី គឺខ្ញុំប្រើក្នុងន័យ អ្នកដឹកនាំ មានការចេះដឹង។ រីឯ ពាក្យ វរៈ ជន វិញ មានន័យ ជា អ្នកចេះដឹងទូទៅ។
[54] នយសាស្ត្រ ; science politique។ ពាក្យនេះបង្កើតដោយលោកអៀវកើស។
[55] ការទង្គិចនឹងបរាជ័យ ; le choc de la défaite។

ដែលវា ចាប់ផ្តើម មានរួចមកហើយ។ ដូច្នេះ អត្តង្គតខ្មែរ វាមាន មូលហេតុ ជ្រៅ ជាង បរាជ័យយោធា នៅក្នុងសង្គ្រាម រវាង ខ្មែរ ជាមួយនឹងប្រទេសជិតខាងខ្លួន។ សួរថា តើ ជា អត្តង្គត មាន មូលហេតុ នៃវប្បធម៌ និង សីលធម៌ ដែល ពុំចេះសម្របខ្លួន ទៅនឹង ការវិវត្តន៍ នៃ សង្គម និង បរិស្ថាន នៃ ភូមិសាស្ត្រ, នយោបាយជាតិ និង ដំបន់ ? ការប្រទល់មុខគ្នា រវាង អរិយធម៌ខ្មែរ នឹង អរិយធម៌យួន ចាប់ពី សតវត្សរ៍ ទី ១៧ មក ជាការបន្ត នៃ ការទង្គិចគ្នា ដែលខ្មែរ មិនទាន់រកឃើញនៅឡើយ នូវចម្លើយ ត្រឹមត្រូវមួយ ដែលអាចឲ ស្រុកខ្មែរសព្វថ្ងៃ ដែលជា ស្រុកសល់ពី ប្រវត្តិសាស្ត្រជាតិខ្មែរ ពុំអាចនឹងក្លាយជា កម្ពុជាក្រោមថ្មីមួយទៀត សំរាប់ ប្រជាជាតិយៀកណាម។ ដូចបាន រៀបរាប់ពីខាងលើរួចមកហើយ នៅ សតវត្ស ទី១៧ ប្រជាជាតិខ្មែរ រស់នៅក្នុង វិបត្តិ របស់អ្នកដឹកនាំ ហុញឱកាសឲ ប្រជាជាតិយៀកណាម ឆ្លៀតយកចំណេញជានិច្ច ក្នុងយុទ្ធសាស្ត្រច្បាស់លាស់ ដើម្បី ដណ្តើមទឹកដីខ្មែរ ឲបានជាដាច់ខាត។

សព្វថ្ងៃនេះ ការទំនាក់ទំនង រវាង ខ្មែរ-យួន គឺនៅ សភាព ជា ការទំនាក់ទំនង រវាង អ្នកចាញ់ នឹង អ្នកឈ្នះ។ យៀកណាម ចង់រក្សា នូវ អត្ថប្រយោជន៍ ជា អ្នកឈ្នះ ជានិច្ច គឺបង្ខំឲខ្មែរ ជាអ្នកចាញ់ ដឹងគុណខ្លួន គ្មានថ្ងៃបញ្ចប់ យកថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ជា និមិត្តរូប នៃ វិសិដ្ឋភាព នៃ

អរិយធម៌យួន លើ អរិយធម៌ខ្មែរ នៅក្នុង ស៊ុម នៃ សន្តិភាពមួយនៅស្រុកខ្មែរ ដែល យៀកណាម ជាម្ចាស់។ ការរក្សា វប្បធម៌ និង ប្រពៃណីខ្មែរ នៅលើទឹកដីខ្មែរ យៀកណាម អនុញ្ញាតឲ ជនជាតិខ្មែរ អាចរក្សាបាន ឲតែការរក្សានោះ វាស្ថិតនៅក្នុង ការទទួលស្គាល់ នៃ ជោគជ័យរបស់យៀកណាម នៅស្រុកខ្មែរ ពុំអាចបង្វិលវិញបាន។ គឺថា អ្វីដែល ប្រជាជាតិខ្មែរ មានបំណង ចង់ពិនិត្យឡើងវិញ បែបយ៉ាងណាក៏ដោយ គឺខ្មែរ ត្រូវយល់ដឹងថា ត្រូវតែដើរ តាមផ្លូវសង្រ្គាមជានិច្ច ព្រោះការណ៍នេះ ជាខ្លឹមសារនៃ អរិយធម៌យួន។ ដូច្នេះ សន្តិភាពនិយម របស់យៀកណាម នៅតណ្ឌូចិន ជា សន្តិភាពនិយម របស់ រាជាធិរាជាណាចក្រយួន ដែល ពួកអ្នកដឹកនាំខ្មែរសព្វថ្ងៃ គេយកមកគំរាមកំហែង ដល់ប្រជាពលរដ្ឋខ្មែរ ក្នុងឋានៈ ជា ឆ្នាំយួនរក្សាសន្តិភាពឲយៀកណាម ទោះបីសន្តិភាពនោះ ជាអកុសលសំរាប់ប្រជាជាតិខ្មែរក៏ដោយ៕

## សៀវភៅ និង ឯកសារជំនួយ និង ដកស្រង់


- Confucius et Mencius : Les quatre livres de philosophie morale et politique de Chine. Traduits du chinois par M.G. PAULTHIER – Paris 1846.
- Grammaire des civilisations : Fernand BRAUDEL – Edition Champs histoire.

- Histoire des Khmers : L'odyssée du peuple cambodgien par Thach Toan.
- Le Cambodge et la colonisation française par Alain Forest.
- Le Cambodge par Jean Delvert – Edition Que sais-je ?
- Histoire du Vietnam par André Masson – Edition Que sais-je ?
- Les institutions politiques et l'organisation administrative du Cambodge ancien (VI-XIII siècles) par Sachchinand SAHAI – thèse pour le doctorat du 3ème cycle.
- Quelques aspects de la littérature khmère par Keng Vannsak- Texte de conférence à la faculté des lettres et des sciences huamines de Phnom-Penh (novembre 1966).
- អរិយធម៌ ខ្មែរ-ឥណ្ឌា -សរសេរដោយ វិន័យបណ្ឌិតោ ភិក្ខុ ប៉ាង ខាត់។
- អរិយធម៌ខ្មែរ - សរសេរដោយ អ្នកស្រី ត្រឹង ងា។
- ព្រះរាជពង្សាវតា នៃ ប្រទេសកម្ពុជា - សរសេរដោយលោក រ.គោវិទ។
- ឯកសារមហាបុរសខ្មែរ ឬ ព្រះរាជពង្សាវតាខ្មែរ ស្រាវជ្រាវដោយ លោក អេង សុត។
- ដំណើរឆ្ពោះទៅទិសខាងលិច - ឥណ្ឌូចិនឆ្នាំ ២០០០ និពន្ធដោយ លោក នួន ឃឿន។
- ប្រទេសខ្មែរ ពីបុព្វសម័យរហូតដល់ការបោះបង់ចោលរាជធានីអង្គរ រៀបរៀងឡើងដោយ សមាគម Promo-Khmer។
- ភាសាខ្មែរ - និពន្ធដោយលោក អៀវ កើស។
- កម្ពុជា និង សហព័ន្ធឥណ្ឌូចិន និពន្ធដោយលោក ចាន់ ដារា និង ប៉ែន នារី។
- អរិយធម៌ខ្មែរ និពន្ធដោយលោក ទាវ ឆៃសុក។
- អរិយធម៌ខ្មែរ និពន្ធដោយលោក លី ឆាមតេង។